ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា



# ផែនការយុទ្ធសាស្ត្រវិស័យអប់រំ
# ឆ្នាំ ២០១៤-២០១៨

ខែ មីនា ឆ្នាំ ២០១៤

# ផែនការយុទ្ធសាស្ត្រវិស័យអប់រំ
# ២០១៤-២០១៨

ខែ មីនា ឆ្នាំ ២០១៤

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាមានមហិច្ឆតាក្នុងការផ្លាស់ប្តូរពីប្រទេស ដែលមានចំណូលមធ្យមកម្រិតទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ហើយបន្តក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ ២០៥០។ កំណើនសេដ្ឋកិច្ចនិងការប្រកួតប្រជែងនាពេលបច្ចុប្បន្ននិងពេលអនាគតរបស់កម្ពុជាដើម្បីសម្រេចបានមហិច្ឆតានេះ គឺពឹងផ្អែកទៅលើសមត្ថភាពរបស់ប្រជាជនក្នុងការក្រេបយកចំណេះដឹងសមស្រប និងជំនាញពាក់ព័ន្ធដែលអាចឆ្លុះបញ្ចាំងពីមរតកវប្បធម៌ និងសីលធម៌របស់ប្រទេសជាតិ។

វិស័យអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍជាតិ។ កុមារ យុវជន និងមនុស្សពេញវ័យត្រូវទទួលបានការសិក្សានិងការអប់រំពេញមួយជីវិត ដែលមានភាពពាក់ព័ន្ធនិងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារប្រកបដោយគុណភាពខ្ពស់។ ការអប់រំត្រូវផ្តោតលើការកសាងជំនាញនិងការផ្តល់ឱកាសដល់សិស្ស និស្សិតគ្រប់រូបក្នុងការទទួលបានជំនាញបច្ចេកទេសនិងជំនាញឯកទេសផ្សេងៗ ដើម្បីសម្រេចបានការអភិវឌ្ឍដែលផ្តល់អត្ថប្រយោជន៍ពេញលេញដល់ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈ និងគ្រប់ទីតាំងភូមិសាស្ត្រ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០១៨ ត្រូវបានរៀបរៀងឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនេះ និងដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់នូវទំនាក់ទំនងរវាងគោលនយោបាយជាតិ និងគោលនយោបាយវិស័យអប់រំ។ ផែនការនេះបង្ហាញពីទំនាក់ទំនងពិតប្រាកដ រវាងក្របខណ្ឌយុទ្ធសាស្ត្រ កម្មវិធី សកម្មភាព ព្រមទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ។ បទប្បញ្ញត្តិនានានឹងត្រូវបានរៀបចំឡើងសម្រាប់ពិនិត្យតាមដាននិងវាយតម្លៃ រួមផ្សំនឹងយន្តការសម្រាប់ផ្តល់ព័ត៌មានត្រឡប់និងកែតម្រូវប្រសិនបើចាំបាច់។

ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តផ្តល់អាទិភាពខ្ពស់ដល់ការផ្តល់សេវាអប់រំមូលដ្ឋានប្រកបដោយសមធម៌និងមានគុណភាពខ្ពស់។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០១៨ ក៏ផ្តោតការយកចិត្តទុកដាក់ខ្ពស់ផងដែរលើការពង្រីកការអប់រំកុមារតូច ការបង្កើនលទ្ធភាពទទួលបានការអប់រំនៅកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សាប្រកបដោយគុណភាព ព្រមទាំងការពង្រីកការងារអប់រំក្រៅប្រព័ន្ធ និងការអប់រំបច្ចេកទេស។ វិធានការជាក់លាក់មួយចំនួននឹងត្រូវយកមកអនុវត្តដើម្បីធានាបាននូវការអប់រំសម្រាប់កុមារនិងយុវជនដែលបាត់បង់ឱកាស។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំត្រូវបានរៀបចំតាមអនុវិស័យសំខាន់ៗចំនួនប្រាំពីរ ដែលរួមមាន ការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស ការអប់រំឧត្តមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍយុវជន និងការអប់រំកាយនិងកីឡា ដើម្បីផ្តល់ការយកចិត្តទុកដាក់លើការបំពេញការងារ គណនេយ្យភាព និងលទ្ធផលច្បាស់លាស់ ។

នៅក្នុងបរិបទនៃវិមជ្ឈការ ការផ្តល់ធនធាននិងយន្តការសមស្រប ដើម្បីតម្លាភាពការងារដល់ប្រព័ន្ធអប់រំ គឺជាកត្តាសំខាន់ក្នុងការលើកកម្ពស់លទ្ធផលនិងបច្ច័យនៃសកម្មភាពអប់រំ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០១៨ បានរួមបញ្ចូលទាំងវិធានការកែលម្អការគ្រប់គ្រងថវិកា ឱ្យមានប្រសិទ្ធភាពប្រសើរជាងមុនក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងលទ្ធផល និងធនធានហិរញ្ញវត្ថុ។ ការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកនៅគ្រប់កម្រិត ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាពធៀបនឹងស្តង់ដារច្បាស់លាស់ នឹងនាំមកនូវអភិបាលកិច្ចល្អ។ ដើម្បីគាំទ្រដល់ការងារនេះ ក្រសួងនឹងបន្តអនុវត្តការពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល សហគមន៍ មាតាបិតាសិស្ស ដៃគូអភិវឌ្ឍ វិស័យឯកជន និងបណ្តាអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០១៨ ត្រូវបានរៀបចំឡើងក្រោមបរិបទនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងជាការឆ្លើយតបទៅនឹងទំនួលខុសត្រូវរបស់វិស័យ រួមជាមួយការពិនិត្យឡើងវិញ និងការវិភាគលើផែនការយុទ្ធសាស្ត្រវិស័យអប់រំក្នុងពេលកន្លងមក។ ក្រុមការងារបានដឹកនាំដំណើរការនៃការរៀបចំផែនការនេះយ៉ាងហ្មត់ចត់ និងបានរៀបចំការពិគ្រោះយោបល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិយ៉ាងទូលំទូលាយ ដោយមានការចូលរួមពីបណ្តាភាគីពាក់ព័ន្ធជាច្រើន។

ក្រសួងអប់រំ យុវជន និងកីឡា សូមសម្តែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ដែលកន្លងមកបានខិតខំប្រឹងប្រែងក្នុងការជម្នះរាល់ការលំបាកនានានិងបានចូលរួមចំណែកយ៉ាងពេញលេញ ដើម្បីអនុវត្តកម្មវិធីកំណែទម្រង់វិស័យអប់រំ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់ដៃគូអភិវឌ្ឍទាំងអស់ ដែលតែងតែជួយគាំទ្រទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ និងលើកកម្ពស់ការអប់រំនៅកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

# មាតិកា


**ជំពូកទី ១ ៖ សេចក្តីផ្តើម និងការវិភាគការបំពេញការងារ ២០០៩-២០១៣**

១.១ សេចក្តីផ្តើម ៖ ការបំពេញការងារវិស័យអប់រំ ២០០៩-២០១៣ ១

១.២ ការវិភាគអំពីការចូលរៀន ៤

១.៣ ការវិភាគអំពីប្រសិទ្ធភាពផ្ទៃក្នុង ៧

១.៤ បញ្ហាប្រឈម ៩

**ជំពូកទី ២ ៖ អាទិភាពនៃការអភិវឌ្ឍជាតិ និង គោលនយោបាយអប់រំ ២០១៤-២០១៨**

២.១ បរិការណ៍នៃការអភិវឌ្ឍជាតិ ១៣

២.២ គោលនយោបាយនិងអាទិភាពសម្រាប់ការអភិវឌ្ឍជាតិ ១៣

២.៣ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ១៤

២.៤ គោលវិធីក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ១៥

២.៥ គោលនយោបាយ យុទ្ធសាស្ត្រ សូចនាករស្នូល និងចំណុចដៅអប់រំ ១៦

២.៥.១ គោលនយោបាយអប់រំ ១៦

២.៥.២ សូចនាករស្នូល ១៧

២.៥.៣ គោលការណ៍របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ១៧

២.៥.៤ កម្មវិធីអាទិភាព ១៨

**ជំពូកទី ៣ ៖ ផែនការតាមអនុវិស័យឆ្នាំ ២០១៤-២០១៨**

៣.១ អនុវិស័យ ការអប់រំកុមារតូច ២១

៣.២ អនុវិស័យ ការអប់រំនៅបឋមសិក្សា ២៦

៣.៣ អនុវិស័យ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស ៣៦

៣.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា ៤៧

៣.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ ៥៤

៣.៦ អនុវិស័យ ការអភិវឌ្ឍយុវជន ៥៨

៣.៧ អនុវិស័យ ការអប់រំកាយនិងកីឡា ៦២

**ជំពូកទី ៤ ៖ ផែនការហិរញ្ញប្បទាន ២០១៤-២០១៨**

៤.១ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៦៧

៤.២ ការព្យាករណ៍ថវិកាសម្រាប់វិស័យអប់រំ ៧០

៤.៣ ការព្យាករណ៍តម្រូវការហិរញ្ញវត្ថុ និងធនធានដែលមាន ៧២

**ជំពូកទី៥ ៖ ការគ្រប់គ្រងនិងការពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨**

៥.១ ការគ្រប់គ្រងនិងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ៧៣

៥.១.១ ការគ្រប់គ្រងបុគ្គលិក ៧៣

៥.១.២ ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន និងមន្ត្រីគ្រប់គ្រងអប់រំ ៧៥

៥.១.៣ ការគ្រប់គ្រងហិរញ្ញវត្ថុនិងថវិកា ៧៧

៥.១.៤ ការគ្រប់គ្រងកម្មវិធី ៧៧
៥.២ ការពិនិត្យតាមដាននិងវាយតម្លៃ ៧៩
៥.៣ នីតិវិធីក្នុងការពិភាក្សា ៨១
៥.៤ ការអភិវឌ្ឍភាពដឹកនាំនិងការគ្រប់គ្រងសម្រាប់វិស័យអប់រំ ៨២

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី ១ ៖ ការព្យាករណ៍ចំនួនសិស្ស និងតម្រូវការអប់រំ ៨៥
ឧបសម្ព័ន្ធទី ២ ៖ សូចនាករតាមអនុវិស័យ ៨៨
ឧបសម្ព័ន្ធទី ៣ ៖ ការព្យាករណ៍តម្រូវការហិរញ្ញវត្ថុ ៩១
ឧបសម្ព័ន្ធទី ៤ ៖ តារាងម៉ាទ្រិកសកម្មភាពគោលនយោបាយ ២០១៤-២០១៨ ៩៣
ឧបសម្ព័ន្ធទី ៥ ៖ តារាងសមហេតុផល ១០៧

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| AOP | Annual Operation Plan | ផែនការប្រតិបត្តិប្រចាំឆ្នាំ |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CDMP | Capacity Development Master Plan | ផែនការគោលអភិវឌ្ឍសមត្ថភាព |
| CFS | Child Friendly School | សាលាកុមារមេត្រី |
| CLC | Community Learning Centre | មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| DGHE | Directorate General of Higher Education | អគ្គនាយកដ្ឋានឧត្តមសិក្សា |
| DHE | Department of Higher Education | នាយកដ្ឋានឧត្តមសិក្សា |
| DOE | District Office of Education | ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ |
| DPs | Development Partners | ដៃគូអភិវឌ្ឍ |
| DSR | Department of Science Research | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ |
| DTMT | District Training and Monitoring Teams | ក្រុមបំប៉ននិងពិនិត្យតាមដានក្រុង ស្រុក ខណ្ឌ |
| ECCD | Early Childhood Care and Development | ការគាំពារនិងអភិវឌ្ឍកុមារតូច |
| ECCE | Early Childhood Care and Education | ការគាំពារនិងអប់រំកុមារតូច |
| ECE | Early Childhood Education | ការអប់រំកុមារតូច |
| EGMA | Early Grade Math Assessment | ការវាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង |
| EGRA | Early Grade Reading Assessment | ការវាយតម្លៃអំណានថ្នាក់ដំបូង |
| EMIS | Education Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| ESP | Education Strategic Plan | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| EU | European Union | សហភាពអឺរ៉ុប |
| EVEP | Elective Vocational Education Program | កម្មវិធីសម្រាំងអប់រំវិជ្ជាជីវៈ |
| FMIS | Financial Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ |
| GDP | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប |
| GER | Gross Enrolment Rate | អត្រារួមនៃការសិក្សា |
| GTHS | General and Technical High School | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស |
| HEI | Higher Education Institution | គ្រឹះស្ថានឧត្តមសិក្សា |
| ICT | Information and Communication Technology | បច្ចេកវិទ្យាសារគមនាគមន៍និងព័ត៌មាន |
| JTWG | Joint Technical Working Group | ក្រុមការងារបច្ចេកទេសចម្រុះ |
| LS | Lower Secondary | មធ្យមសិក្សាបឋមភូមិ |
| LSSC | Local School Support Committee | គណៈកម្មការទ្រទ្រង់សាលារៀន |
| MAP | Ministry Action Plan | ផែនការសកម្មភាពរបស់ក្រសួង |

| | | |
|---|---|---|
| MoEYS | Ministry of Education Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| NCDD | National Committee for Democratic Development | គណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ |
| NER | Net Enrolment Rate | អត្រាពិតនៃការសិក្សា |
| NFE | Non Formal Education | ការអប់រំក្រៅប្រព័ន្ធ |
| NIE | National Institute of Education | វិទ្យាស្ថានជាតិអប់រំ |
| NP-SNDD | National Program for Sub-National Democratic Development | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PB | Program Budget | ថវិកាកម្មវិធី |
| PEC | Provincial Education Congresses | សន្និបាតអប់រំ រាជធានី ខេត្ត |
| PESP | Provincial Education Strategic Plan | ផែនការយុទ្ធសាស្ត្រអប់រំ រាជធានី ខេត្ត |
| PFMR | Public Finance Management Reform | កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PISA | Program for International Student Assessment | កម្មវិធីវាយតម្លៃសិក្សាកម្រិតអន្តរជាតិ |
| POE | Provincial Office of Education | មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត |
| PTTC | Provincial Teacher Training College | សាលាគរុកោសល្យនិងវិក្រឹតការរាជធានី ខេត្ត |
| RTTC | Regional Teacher Training College | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ |
| RUPP | Royal University of Phnom Penh | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| SEAMEO | Southeast Asian Ministers of Education Organization | អង្គការរដ្ឋមន្ត្រីអប់រំនៃប្រទេសអាស៊ីអាគ្នេយ៍ |
| SIDA | Swedish International Development Agency | ភ្នាក់ងារអភិវឌ្ឍអន្តរជាតិនៃប្រទេសស៊ុយអែត |
| SNA | Sub-national Administration | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| STEAM | Science, Technology, Engineering, Arts and Mathematics | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា |
| SY | School Year | ឆ្នាំសិក្សា |
| TIMSS | Trends in International Mathematics and Science Study | ការសិក្សាលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រកម្រិតអន្តរជាតិ |
| TTC | Teacher Training College | មជ្ឈមណ្ឌលបណ្ដុះបណ្ដាលគ្រូបង្រៀន |
| US | Upper Secondary | មធ្យមសិក្សាទុតិយភូមិ |
| WASH | Water, Sanitation, Hygiene | ទឹកស្អាត សុខភាព និងអនាម័យ |
| WFP | World Food Program | កម្មវិធីស្បៀងអាហារពិភពលោក |



# ជំពូកទី ១

# សេចក្តផ្តើមនិងការវភាគការបំពេញការងារ ២០០៩-២០១៣

## ១.១ សេចក្តីផ្តើម ៖ ការបំពេញការងារវិស័យអប់រំ ២០០៩-២០១៣

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ ក្រសួងអប់រំ យុវជន និងកីឡា សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការបង្កើនឱកាសឱ្យកុមារកម្ពុជាគ្រប់រូបទទួលបានការអប់រំ ការលើកកម្ពស់គុណភាពនៃការរៀនសូត្ររបស់កុមារ និងការផ្តល់សេវាអប់រំប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ បានកំណត់គោលនយោបាយចំនួនបី គឺ

- គោលនយោបាយទី ១ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌
- គោលនយោបាយទី ២ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ
- គោលនយោបាយទី ៣ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ

នៅក្នុងផ្នែកខាងក្រោមមានរៀបរាប់ពីសេចក្តីសង្ខេបលទ្ធផលសម្រេចបាន ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ និងការកំណត់អំពីចំណុចផ្តោតសម្រាប់រយៈពេល ៥ ឆ្នាំបន្ទាប់ទៀត។ ការវិភាគអំពីលទ្ធផលសម្រេចបាននេះ ត្រូវបានដកស្រង់ចេញពីរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ ដែលបានបញ្ចប់ក្នុងឆ្នាំ ២០១២ លទ្ធផលនៃអង្គវិបស្សនាអប់រំប្រចាំឆ្នាំ និងការពិនិត្យឡើងវិញតាមអនុវិស័យក្នុងឆ្នាំ ២០១២ និង ២០១៣។

ដើម្បីពិនិត្យមើលវឌ្ឍនភាពក្នុងការអនុវត្តគោលនយោបាយខាងលើ សូចនាករស្នូលចំនួន ៦ ត្រូវបានកំណត់។ តារាងខាងក្រោមបង្ហាញវឌ្ឍនភាពនៃការអនុវត្ត៖

*តារាងទី ១ ៖ វឌ្ឍនភាពនៃសូចនាករស្នូល*

| សូចនាករស្នូល | ទិន្នន័យគោល ឆ្នាំ ២០០៨ | ជាក់ស្តែង ២០១២ | ចំណុចដៅ ឆ្នាំ ២០១៣ |
|---|---|---|---|
| គោលនយោបាយទី ១ : ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | | | |
| – ភាគរយកុមារអាយុ៥ឆ្នាំក្នុងការអប់រំកុមារតូចគ្រប់រូបភាព | ៣៩,៨% | ៥២,៧% | ៦០% |
| – ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សា យ៉ាងតិច ៨០ភាគរយ | ១០៦ | ១៣១ | ១២១ |
| គោលនយោបាយទី ២ : លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ | | | |
| – ចំនួនសាលារៀនបឋមសិក្សាគ្រប់កម្រិតដែលមានអត្រាត្រួតថ្នាក់តិចជាង ១០ភាគរយ | ៣ ៨៤៩ លើ ៥ ៤៦២ | ៤ ៦៧៥ លើ ៥ ៤៦២ | ៤ ៩៦៧ លើ ៥ ៤៦២ |
| – ស្តង់ដារជាតិវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | | | |
| ថ្នាក់ទី៣ | n.a | កំពុងអនុវត្ត | បញ្ចប់ |
| ថ្នាក់ទី៦ | n.a | មិនទាន់អនុវត្ត | បញ្ចប់ |

| | | | |
|---|---|---|---|
| ថ្នាក់ទី៨ | n.a | មិនទាន់អនុវត្ត | បញ្ចប់ |
| គោលនយោបាយទី ៣ : អភិវឌ្ឍស្ថាប័ននិងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ | | | |
| – ការដកសាច់ប្រាក់ទាន់ពេលនៃថវិកាកម្មវិធី | ៩៥% | ៩៣,៧២% | ៩៥% |
| – ផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ក្រោមជាតិត្រូវបានធ្វើ | n.a | ២៤ | ២៤ |

សូចនាករ ៥ ក្នុងចំណោមសូចនាករស្នូលទាំង ៦ របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ បានបង្ហាញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ សូចនាករស្តីពីស្តង់ដារជាតិវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី ៣ ទើបតែបញ្ចប់។ ការវាយតម្លៃសិស្សថ្នាក់ទី ៦ នឹងធ្វើឡើងក្នុងឆ្នាំ ២០១៤ និងសិស្សថ្នាក់ទី ៨ ក្នុងឆ្នាំ ២០១៥។

ដើម្បីពិនិត្យតាមដានវឌ្ឍនភាពរបស់កម្មវិធីនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ សូចនាករនិងចំណុចដៅបំពេញការងារចំនួន ២៤ ត្រូវបានកំណត់។ សូចនាករនិងស្ថានភាពជាក់ស្តែងនៃសូចនាករទាំងនេះ មានដូចខាងក្រោម៖

*តារាងទី ២ ៖ វឌ្ឍនភាពនៃសូចនាករនិងចំណុចដៅបំពេញការងារ*

*គោលនយោបាយទី ១ : ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

| លរ | សូចនាករ | ជាក់ស្តែង 2009-2010 | | ជាក់ស្តែង 2010-2011 | | ជាក់ស្តែង 2011-2012 | | ជាក់ស្តែង 2012-2013 | | ចំណុចដៅ 2012-2013 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | |
| 1 | ភាគរយកុមារអាយុ៥ ឆ្នាំក្នុងការអប់រំកុមារតូច | 39.8% | 40.5% | 46.0% | 51.0% | 52.7% | 49.8 | 56.5% | 49.5% | 55.0% | 55.0% | ↑ |
| 2 | អត្រាពិតចូលរៀនថ្មី | 93.8% | 93.5% | 93.4% | 94.2% | 94.1% | 94.0% | 94.3% | 94.2% | 98.0% | 98.0% | → |
| 3 | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | 95.8% | 95.5% | 96.1% | 94.4% | 96.4% | 96.1% | 97.0% | 97.0% | 97.0% | 97.0% | ↑ |
| 4 | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 58.1% | 57.1% | 56.6% | 56.1% | 55.0% | 55.0% | 53.6% | 54.2% | | | ↓ |
| | អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 31.9% | 33.7% | 33.9% | 36.1% | 35.1% | 37.4% | 37.8% | 40.2% | 47.0% | 47.0% | ↓ |
| 5 | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | 32.3% | 29.2% | 33.2% | 31.0% | 30.6% | 28.9% | 27.4% | 26.4% | | | → |
| | អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | 19.3% | 19.3% | 20.8% | 21.1% | 19.6% | 20.1% | 18.1% | 18.8% | 23.0% | 23.0% | → |
| 6 | ចំនួននិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណ: និងឯកជន | 145,265 | 51,596 | 173,264 | 70,954 | 207666* | 83,463 | 216,053* | 86,235 | 199,006 | 89,086 | ↑ |
| 7 | អត្រាអក្ខរភាពសរុបអាយុ ១៥-២៤ឆ្នាំ | 87.5%** | | 88.8%*** | | 89.0% | | 91.5%*** | | 91.0% | | ↑ |

↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

* តួលេខនេះ មិនរាប់បញ្ចូលនិស្សិតថ្នាក់បរិញ្ញាបត្ររង

** តួលេខជំរឿនប្រជាជន ២០០៨ (ក្រសួងផែនការ)

*** តួលេខរបស់វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (២០១២) និង អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជា ឆ្នាំ២០១០

## គោលនយោបាយទី ២ : លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ

| លរ | សូចនាករ | ជាក់ស្តែង 2009-2010 | | ជាក់ស្តែង 2010-2011 | | ជាក់ស្តែង 2011-2012 | | ជាក់ស្តែង 2012-2013 | | ចំណុចដៅ 2012-2013 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| 8 | ផលធៀបសិស្ស-ថ្នាក់នៅបឋមសិក្សា | 38.6 | | 38.0 | | 36.6 | | 36.9 | | 45.5 | | ↑ |
| 9 | ផលធៀបគ្រូ-ថ្នាក់ នៅបឋមសិក្សា | 0.78 | | 0.78 | | 0.77 | | 0.76 | | 0.95 | | ↑ |
| 10 | អត្រាត្រួតថ្នាក់ | | | | | | | | | | | |
| | បឋមសិក្សា | 8.9% | 7.8% | 7.1% | 6.2% | 5.8% | 5.0% | 5.3% | 4.5% | 6.0% | 6.0% | ↑ |
| | មធ្យមសិក្សាបឋមភូមិ | 2.3% | 1.5% | 2.0% | 1.3% | 1.8% | 1.2% | 1.5% | 1.0% | 1.4% | 1.2% | ↑ |
| | មធ្យមសិក្សាទុតិយភូមិ | 2.8% | 1.7% | 1.8% | 1.1% | 2.2% | 1.5% | 1.7% | 1.1% | 2.2% | 1.2% | ↑ |
| 11 | អត្រាបោះបង់ការសិក្សា | | | | | | | | | | | |
| | បឋមសិក្សា | 8.3% | 7.8% | 8.7% | 8.7% | 8.3% | 7.8% | 3.7% | 4.7% | 6.0% | 6.0% | ↑ |
| | មធ្យមសិក្សាបឋមភូមិ | 18.8% | 19.4% | 19.6% | 20.2% | 21.7% | 21.9% | 20.0% | 18.7% | 13.0% | 15.0% | ↓ |
| | មធ្យមសិក្សាទុតិយភូមិ | 11.2% | 10.8% | 11.8% | 10.7% | 13.7% | 13.1% | 10.1% | 9.8% | 9.0% | 8.0% | → |
| 12 | អត្រាបញ្ចប់ការសិក្សា | | | | | | | | | | | |
| | បឋមសិក្សា | 83.1% | 83.7% | 85.3% | 85.0% | 89.7% | 89.9% | 87.3% | 87.8% | 95.0% | 95.0% | → |
| | មធ្យមសិក្សាបឋមភូមិ | 48.6% | 44.2% | 44.4% | 44.2% | 42.1% | 41.6% | 40.6% | 40.3% | 52.0% | 51.0% | → |
| | មធ្យមសិក្សាទុតិយភូមិ | 25.9% | 22.4% | 28.5% | 25.2% | 27.8% | 26.1% | 27.0% | 25.2% | 30.0% | 28.0% | → |
| 13 | ចំនួនសិស្សចូលរៀនឡើងវិញនៅថ្នាក់ទី៣ដល់ទី៦ | 23,845 | | 28,195 | | 21,366 | | 21,189 | | 22,000 | | ↑ |
| 14 | ចំនួនសាលារៀនបឋមសិក្សាមិនគ្រប់កម្រិត | 1,203 | | | | 1,041 | | 952 | | TBD | | ↑ |
| 15 | ផលធៀប សៀវភៅ-សិស្សនៅថ្នាក់ទី១-៣ (១សម្រាប់មាន៣ក្បាល) | n.a | | 2.8 | | 2.70 | | 2.99 | | 3.00 | | ↑ |
| | ផលធៀបសៀវភៅ-សិស្សនៅថ្នាក់ទី៤-៦ (១សម្រាប់មាន៤ក្បាល) | n.a | | 3.6 | | 3.50 | | 3.85 | | 4.00 | | ↑ |
| 16 | ស្តង់ដាជាតិវាយតម្លៃលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាភាសាខ្មែរ | | | | | | | | | | | |
| | ថ្នាក់ទី ៣ | | | n.a | | 69% | | កំពុងអនុវត្ត | | បញ្ចប់ | | → |
| | ថ្នាក់ទី ៦ | | | n.a | | n.a | | មិនទាន់អនុវត្ត | | បញ្ចប់ | | ↓ |
| 17 | ស្តង់ដាជាតិវាយតម្លៃលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាគណិតវិទ្យា | | | | | | | | | | | |
| | ថ្នាក់ទី ៣ | | | n.a | | 62% | | កំពុងអនុវត្ត | | បញ្ចប់ | | → |
| | ថ្នាក់ទី ៦ | | | n.a | | n.a | | មិនទាន់អនុវត្ត | | បញ្ចប់ | | ↓ |
| 18 | ភាគរយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជនគោរពតាមលក្ខខណ្ឌតម្រូវនៃការបង្កើត | | | 70% | | 70% | | 70% | | 85% | | → |

↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

## គោលនយោបាយទី ៣ : អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ

| លរ | សូចនាករ | ជាក់ស្តែង 2009 | ជាក់ស្តែង 2010 | ជាក់ស្តែង 2011 | ជាក់ស្តែង 2012 | ចំណុចដៅ 2012 | |
|---|---|---|---|---|---|---|---|
| 19 | ថវិកាចរន្តសម្រាប់វិស័យអប់រំ (ថវិការដ្ឋ និងថវិកាផ្សេងៗទៀត)ធៀបនឹងថវិកាជាតិ* | 17.0% | 16.4 % | 16.6%* | 15.92%* | 20.0% | ↓ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 20 | ភាគរយចំណាយថវិកាកម្មវិធីជាក់ស្តែងធៀបនឹងថវិកាកម្មវិធីសរុប | 88.7% | 91.3% | 91.69% | 86.71% | 95.0% | → |
| 21 | ភាគរយអង្គភាពអនុវត្តថវិកាដែលត្រូវធ្វើសវនកម្មផ្ទៃក្នុងក្នុង១ឆ្នាំ | 16.7% | 33.2% | 64.8% | 76.1% | TBD | → |
| 22 | ភាគរយសាលារៀននិងគ្រឹះស្ថានសិក្សាដែលត្រូវធ្វើសវនកម្មផ្ទៃក្នុងក្នុង១ឆ្នាំ | 1.1% | 6.1% | 7.2% | 7.1% | TBD | ↑ |
| 23 | ជំនួយការបច្ចេកទេស(នាក់-ខែ) ជាតិនិងអន្តរជាតិ | 516 | 323.43 | 257 | 212 | 400 | ↑ |
| 24 | ភាគរយបុគ្គលិកអប់រំជាស្ត្រី | n.a | 38.88% | 39.73% | 41% | | ↑ |
| | បុគ្គលិកបង្រៀន | 43.4% | 39.82% | 43.54% | 44% | | ↑ |
| | មន្ត្រីគ្រប់គ្រងថ្នាក់មធ្យម(ប្រធាន អនុប្រធាននាយកដ្ឋាន មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត) | 10.3% | 11.88% | 10.5% | 10% | | ↓ |
| | ថ្នាក់ដឹកនាំ (ចាប់ពីអគ្គនាយករងឡើងទៅ) | 7.7% | 10% | 7.89% | 7% | | ↓ |

↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

* ថវិកាចរន្តសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា

ជាទូទៅ វឌ្ឍនភាពនៃសូចនាករបំពេញការងារមានភាពវិជ្ជមាន។ ទោះជាយ៉ាងណា សូចនាករមួយចំនួននៅទាបជាងចំណុចដៅដែលបានកំណត់ និងត្រូវបន្តដោះស្រាយ។ ជាងនេះទៅទៀត បញ្ហាប្រឈមទាំងនេះនឹងកាន់តែមានលក្ខណៈជាក់លាក់ នៅពេលដែលសូចនាករត្រូវបានពិនិត្យនៅកម្រិតខេត្ត និងកម្រិតស្រុក។ រាជធានី ខេត្តមួយចំនួន ទោះបីសូចនាករបង្ហាញពីវឌ្ឍនភាពកើនឡើងក៏ដោយក៏នៅតែទាបជាងចំណុចដៅដែលបានកំណត់។ សូចនាករស្តីពីការចូលរៀននិងបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សានៅទាបជាងចំណុចដៅ។ ក្នុងអំឡុងឆ្នាំ ២០០៩-២០១៣ សមត្ថភាពក្នុងការប្រមូលទិន្នន័យ និងសមត្ថភាពវិភាគកំពុងបន្តកែលម្អ និងភាពជឿជាក់ក៏ត្រូវបានបង្កើន កត្តានេះជួយដល់ការកំណត់អន្តរាគមន៍ជាក់លាក់។

## ១.២ ការវិភាគអំពីការចូលរៀន

រូបទី១ បង្ហាញថា កុមារក្នុងវ័យសិក្សានៅមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិនៅថេរ ចន្លោះពីឆ្នាំសិក្សា ២០០៨-២០០៩ ដល់ ២០១២-២០១៣ ប្រមាណជា ១ លាននាក់ ។ កុមារក្នុងវ័យសិក្សានៅបឋមសិក្សាថយចុះពី ១,៨៩៥,២០៩ នាក់មកត្រឹម ១,៧៦១,៨២៥នាក់។

ដោយសារនិន្នាការប្រជាជន អត្រារួមនៃការសិក្សានៅបឋមសិក្សាស្ថិតនៅថេរចាប់ពីឆ្នាំសិក្សា ២០០៨-២០០៩ ដល់ឆ្នាំសិក្សា ២០១២-២០១៣ (រូបភាពទី១)។ អត្រាពិតនៃការសិក្សាបានកើនឡើងនៅគ្រប់ភូមិសិក្សា។ អត្រាពិតនៃការសិក្សានៅបឋមសិក្សាបានកើនដល់ ៩៧ ភាគរយ នៅឆ្នាំសិក្សា ២០១២-២០១៣ ហើយរំពឹងថានឹងកើនបន្ថែមទៀតនៅឆ្នាំសិក្សាខាងមុខរហូតដល់ ១០០ ភាគរយ (រូបភាពទី២)។ ការចូលរៀននៅបឋមសិក្សាត្រូវបានកែលម្អជាបណ្តើរៗក្នុងរយៈពេលកន្លងមក ជាពិសេសការចូលរៀនរបស់កុមារកាន់តែត្រូវទៅតាមអាយុកំណត់ ។

រូបភាពទី១ : ប្រជាជនតាមអាយុនៃភូមិសិក្សានីមួយៗ ពីឆ្នាំសិក្សា២០០៨-២០០៩ ដល់ ២០១២-២០១៣




រូបភាពទី២ : អត្រារួមនៃការសិក្សានិងអត្រាពិតនៃការសិក្សានៅបឋមសិក្សាពីឆ្នាំសិក្សា២០០៩-២០១០ ដល់ ២០១២-២០១៣




ដូចបង្ហាញក្នុងរូបភាពខាងក្រោម អត្រាពិតនៃការសិក្សានៅបឋមសិក្សាត្រូវបានកែលម្អតាមរាជធានី ខេត្ត។ ក្នុងឆ្នាំសិក្សា ២០១២-២០១៣ គ្រប់រាជធានី ខេត្ត មានអត្រាពិតនៃការសិក្សានៅបឋមសិក្សាខ្ពស់ជាង ៩០ ភាគរយ និង ១០ រាជធានី ខេត្ត មានអត្រាពិតនៃការសិក្សាខ្ពស់ជាង ៩៧ ភាគរយ។

*រូបភាពទី ៣ ៖ អត្រាពិតនៃការសិក្សានៅបឋមសិក្សាក្នុងឆ្នាំសិក្សា ២០០៩-២០១០ និង ២០១២-២០១៣*







រូបភាពទី៣ បង្ហាញពីនិន្នាការរបស់អត្រារួមនិងអត្រាពិតនៃការសិក្សានៅបឋមសិក្សាតាមតំបន់ទីប្រជុំជននិងជនបទរវាងឆ្នាំសិក្សា ២០០៩-២០១០ និង២០១២-២០១៣។ ទាំងអត្រារួមនៃការសិក្សាទាំងអត្រាពិតនៃការសិក្សាបានធ្លាក់ចុះយ៉ាងខ្លាំងនៅតំបន់ទីប្រជុំជន។ អត្រារួមនៃការសិក្សាបានកើនឡើងខ្លាំងនៅតំបន់ជនបទ ជាពិសេសអត្រាពិតនៃការសិក្សា ដែលបង្ហាញពីការកើនឡើងនូវលទ្ធភាព

ទទួលបានការអប់រំនៅតំបន់ជនបទ ក៏ដូចជាការកែលម្អប្រសិទ្ធភាពរបស់ប្រព័ន្ធអប់រំ ដែលមានកុមារដល់អាយុបានចូលរៀនកាន់តែច្រើន។

*រូបភាពទី ៤ : អត្រារួមនៃសិក្សានៅបឋមសិក្សា តាមតំបន់ទីប្រជុំជននិងជនបទ ពីឆ្នាំសិក្សា ២០០៩-២០១០ដល់២០១២-២០១៣*




*រូបភាពទី ៥ : អត្រាពិតនៃសិក្សានៅបឋមសិក្សា តាមតំបន់ទីប្រជុំជននិងជនបទ ពីឆ្នាំសិក្សា ២០០៩-២០១០ដល់២០១២-២០១៣*




ផែនទីខាងក្រោមបង្ហាញថា អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ មិនបានកើនឡើងដូចការរំពឹងទុក ប៉ុន្តែខេត្តមួយចំនួនបានធ្លាក់ចុះ។

*រូបភាពទី ៦ ៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិឆ្នាំសិក្សា ២០០៩-២០១០ និង ២០១២-២០១៣*







រូបភាពទី ៦ បង្ហាញថា អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិនៅតំបន់ទីប្រជុំជននិងតំបន់ជនបទបានថយចុះ។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងតំបន់ទីប្រជុំជនបានថយចុះខ្លាំង ហើយនៅតំបន់ជនបទបានថយចុះបន្តិចបន្តួច ដែលឆ្លុះបញ្ចាំងពីចំនួនសាលារៀនកាន់តែច្រើនឡើងៗនៅតំបន់ជនបទ។

រូបភាពទី ៧ និងទី ៨ បង្ហាញពីនិន្នាការនៃអត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ បានថយចុះ។ ប៉ុន្តែមានស្ថានភាពប្រសើរជាងនៅមធ្យមសិក្សាបឋមភូមិ។

*រូបភាពទី៧ : អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិតាមតំបន់ទីប្រជុំជននិងជនបទពីឆ្នាំសិក្សា ២០០៩-២០១០ ដល់ ២០១២-២០១៣*




*រូបភាពទី៨ : អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិតាមតំបន់ទីប្រជុំជននិងជនបទពីឆ្នាំសិក្សា ២០០៩-២០១០ ដល់ ២០១២-២០១៣*




## ១.៣ ការវិភាគអំពីប្រសិទ្ធភាពផ្ទៃក្នុង

អត្រាត្រួតថ្នាក់នៅគ្រប់ភូមិសិក្សាបានថយចុះ ជាពិសេសនៅបឋមសិក្សាបានថយចុះពី ៩,០ ភាគរយនៅឆ្នាំសិក្សា ២០០៨-២០០៩ មកត្រឹម ៥,៣ ភាគរយនៅឆ្នាំសិក្សា ២០១១-២០១២។ ចំណែកនៅមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ អត្រាត្រួតថ្នាក់ថយចុះបន្តិចបន្តួច មកនៅត្រឹម ១,៥ ភាគរយនិង ១,៧ភាគរយ នៅឆ្នាំសិក្សា ២០១១-២០១២។

*រូបភាពទី៩ : អត្រាត្រួតថ្នាក់តាមភូមិសិក្សាពីឆ្នាំសិក្សា ២០០៨-២០០៩ ដល់ ២០១១-២០១២*




ក្នុងផែនទីខាងក្រោម អត្រាត្រួតថ្នាក់បានថយចុះ នៅគ្រប់រាជធានី ខេត្ត នៅសល់តែខេត្តមួយប៉ុណ្ណោះដែលមានអត្រាខ្ពស់ជាង ១០ ភាគរយ។ រូបភាពទី ៩ បង្ហាញថា អត្រាត្រួតថ្នាក់នៅបឋមសិក្សា

ក្នុងរាជធានី ខេត្តជាងពាក់កណ្តាល មានអត្រាចន្លោះពី ៨,៩ ភាគរយឆ្នាំសិក្សា ២០០៨-២០០៩ ទៅ ៥,៣ ភាគរយ ឆ្នាំសិក្សា ២០១១-២០១២។ ទោះជាយ៉ាងណាក៏ដោយ ដូចបានឃើញនៅក្នុងផែនទីនិង រូបភាពក្នុងផ្នែកបន្ទាប់ អត្រាបោះបង់ការសិក្សានៅតែមានកម្រិតខ្ពស់។

*រូបភាពទី ១០ : អត្រាត្រួតថ្នាក់នៅបឋមសិក្សាក្នុងឆ្នាំសិក្សា ២០០៨-២០០៩ និង ២០១១-២០១២*

*អត្រាត្រួតថ្នាក់នៅបឋមសិក្សាឆ្នាំសិក្សា ២០០៨-២០០៩*




*អត្រាត្រួតថ្នាក់នៅបឋមសិក្សាឆ្នាំសិក្សា ២០១១-២០១២*




ខេត្តស្ទឹងត្រែងមានអត្រាត្រួតថ្នាក់នៅបឋមសិក្សាខ្ពស់ជាងគេ ជាមធ្យម ១៣,៦ ភាគរយ ខេត្តព្រះវិហារ ៩,៧ ភាគរយ និងខេត្តកែបមានអត្រាត្រួតថ្នាក់ទាបជាងគេ គឺ ១,៦ ភាគរយ។

*រូបភាពទី ១១ : អត្រាបោះបង់ការសិក្សានៅបឋមសិក្សាក្នុងឆ្នាំសិក្សា ២០០៨-២០០៩ និង ២០១១-២០១២*






អត្រាបោះបង់ការសិក្សានៅបឋមសិក្សាបង្ហាញពីការកែលម្អគួរឱ្យកត់សម្គាល់ ក្នុងពេលកំពុងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំកន្លងមក។ រូបភាពទី ១១ បង្ហាញថាអត្រាបោះបង់ការសិក្សាមានភាពខុសគ្នាខ្លាំងក្នុងចំណោមរាជធានី ខេត្តទាំងអស់។ ស្ថានភាពនៃអត្រាបោះបង់ការសិក្សាមិនមានលក្ខណៈដូចគ្នារវាងភូមិសិក្សាមួយទៅភូមិសិក្សាមួយទៀតនោះទេ។

## ១.៤ បញ្ហាប្រឈម

តាមរយៈការពិនិត្យតាមដានវឌ្ឍនភាព បញ្ហាប្រឈមនិងដំណោះស្រាយមួយចំនួនត្រូវបានរកឃើញ ដែលនឹងត្រូវដោះស្រាយនៅក្នុងដំណាក់កាលបន្ទាប់ ដូចខាងក្រោម ៖

- បញ្ហាប្រឈម ៖ ការពង្រីកការអប់រំកុមារតូច ការជំរុញការចូលរៀននៅក្នុងកម្មវិធីអប់រំកុមារតូចឱ្យបានត្រឹមត្រូវតាមអាយុរបស់កុមារអាយុ ០ ទៅ ៥ ឆ្នាំ។ ការបង្កើនសមត្ថភាពគ្រូមត្តេយ្យសិក្សាតាមរយៈការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូមត្តេយ្យសិក្សា និងការផ្សព្វផ្សាយពីគុណតម្លៃនៃការសិក្សាដល់មាតាបិតានិងសហគមន៍។
- ដំណោះស្រាយ ៖ បង្កើនការចូលរៀនក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះនិងសហគមន៍ ជាមួយគ្នានឹងកម្មវិធីបណ្តុះបណ្តាលក្រុមម្តាយ និងគ្រូមត្តេយ្យសហគមន៍។
- បញ្ហាប្រឈម ៖ ការពង្រីកការអប់រំដោយសមធម៌នៅបឋមសិក្សា ជាពិសេស តំបន់ជួបការលំបាក និងក្រុមកុមារជួបការលំបាក។
- ដំណោះស្រាយ ៖ ពង្រីកកម្មវិធីអប់រំពីរភាសា កម្មវិធីអាហារូបករណ៍និងអាហារបត្ថម្ភ ការពន្លឿនការសិក្សា និងកម្មវិធីចូលរៀនឡើងវិញ តាមរយៈការអប់រំក្រៅប្រព័ន្ធ និងការបង្កើនសមាហរណកម្មការអប់រំបញ្ចូលគ្នាទៅគ្រប់កម្រិតសិក្សា ។
- បញ្ហាប្រឈម ៖ ការចូលរៀននិងគុណភាពនៅមធ្យមសិក្សា។
- ដំណោះស្រាយ ៖ បង្កើនការចូលរៀននៅមធ្យមសិក្សា ដោយយកចិត្តទុកដាក់លើការកាត់បន្ថយគម្លាតយេនឌ័រ និងយកចិត្តទុកដាក់ជំរុញការបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ។ បង្កើនចំនួនអាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ ជាពិសេសសិស្សស្រី។ បង្កើនចំនួនសាលាមធ្យមសិក្សាបឋមភូមិ តាមរយៈការពង្រីកសាលាបឋមសិក្សាស្របតាមកំណើនសិស្ស។
- បញ្ហាប្រឈម ៖ ការប្រមូលកុមារក្រៅសាលានិងការអប់រំក្រៅប្រព័ន្ធ។
- ដំណោះស្រាយ ៖ រៀបចំវិធានការដើម្បីកាត់បន្ថយចំនួនកុមារនៅក្រៅសាលា យកចិត្តទុកដាក់បន្ថែមលើកុមារជនជាតិដើមភាគតិច កុមារពិការ និងកុមារក្នុងគ្រួសារក្រីក្រ តាមរយៈកម្មវិធីដែលបានកំណត់។

- បញ្ហាប្រឈម ៖ ប្រព័ន្ធអប់រំមិនទាន់អាចផ្តល់ការអប់រំដែលមានគុណភាពខ្ពស់និងភាពឆ្លើយតបសម្រាប់កុមារនិងយុវជន។
- ដំណោះស្រាយ ៖ បង្កើតក្របខ័ណ្ឌថ្នាក់ជាតិសម្រាប់ធានាការពិនិត្យតាមដានគុណភាព និងយន្តការនានាសម្រាប់អនុវត្ត។ រួមបញ្ចូលទាំងយន្តការសម្រាប់វាស់វែងលទ្ធផលនៃការសិក្សារបស់សិស្ស តាមរយៈការធ្វើតេស្តនៅតាមថ្នាក់រៀនជាប្រចាំ ការវាយតម្លៃការសិក្សារបស់សិស្សថ្នាក់ទី ៣ ព្រមទាំងពង្រីកទៅដល់ថ្នាក់ទី ៦ និងទី ៨។ លើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការសិក្សា តាមរយៈការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងសម្ភារៈសិក្សាជាទៀងទាត់និងមានលក្ខណៈជាប្រព័ន្ធ។
- បញ្ហាប្រឈម ៖ ការផ្គត់ផ្គង់សៀវភៅសិក្សាគោលនិងសម្ភារៈសិក្សា។
- ដំណោះស្រាយ ៖ ពិនិត្យឡើងវិញនិងកែលម្អការបែងចែកនិងគ្រប់គ្រងសៀវភៅសិក្សាគោល។ ធានាការផ្គត់ផ្គង់សៀវភៅសិក្សាគោល កម្មវិធីសិក្សាថ្មី និងការផ្តល់សៀវភៅគ្រូដល់គ្រូបង្រៀននៅតំបន់ជួបការលំបាក។
- បញ្ហាប្រឈម ៖ ការផ្គត់ផ្គង់និងពង្រាយគ្រូដែលមានគុណភាព។
- ដំណោះស្រាយ៖ ពង្រាយគ្រូបង្រៀននៅតាមវិទ្យាល័យ និងអនុវិទ្យាល័យដែលបង្កើតថ្មី ពិសេសតំបន់ជួបការលំបាក។ បង្កើនសមត្ថភាពចំណេះដឹងនិងជំនាញរបស់គ្រូបង្រៀនលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រ តាមរយៈវិក្រឹតការគ្រូបង្រៀន និងដាក់ឱ្យអនុវត្តប្រព័ន្ធការវាយតម្លៃការងារបុគ្គលិក។
- បញ្ហាប្រឈម ៖ ការពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំនិងត្រៀមអនុវត្តវិមជ្ឈការនិងវិសហមជ្ឈការ។
- ដំណោះស្រាយ ៖ អភិវឌ្ឍសមត្ថភាពរបស់នាយកសាលា មន្ត្រីគ្រប់គ្រងនៅមន្ទីរអប់រំ យុវជននិងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។ ពង្រឹងសមត្ថភាពក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងការពិនិត្យតាមដាននិងគាំទ្រសាលារៀន។
- បញ្ហាប្រឈម ៖ ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។
- ដំណោះស្រាយ ៖ ប្រើប្រាស់ធនធានដែលមានប្រកបដោយប្រសិទ្ធភាពខ្ពស់ និងកៀរគរហិរញ្ញប្បទានបន្ថែមពីប្រភពខាងក្រៅ និងដៃគូអភិវឌ្ឍ។
- បញ្ហាប្រឈម ៖ ការពង្រឹងការគ្រប់គ្រងបុគ្គលិក ។
- ដំណោះស្រាយ ៖ អនុវត្តកំណែទម្រង់មុខងារសាធារណៈ បង្កើនបៀវត្ស និង ធានាការតែងតាំងមន្ត្រីរាជការ ដោយឈរលើមូលដ្ឋានសមិទ្ធកម្ម ។

- បញ្ហាប្រឈម ៖ ការពង្រឹងរាល់ដំណើរការប្រឡងគ្រប់ប្រភេទ។
- ដំណោះស្រាយ ៖ ពង្រឹងគុណភាពប្រឡងដោយអនុវត្តគោលការណ៍ ៤ យ៉ាង គឺគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន។
- បញ្ហាប្រឈម ៖ ការបង្កើតធនាគារខួរក្បាលរបស់វិស័យអប់រំ។
- ដំណោះស្រាយ ៖ ពង្រឹងសមត្ថភាព និងអភិវឌ្ឍស្ថាប័ន និងកំណត់នូវវិធានការកំណែទម្រង់។
- បញ្ហាប្រឈម ៖ កំណែទម្រង់ឧត្តមសិក្សា ។
- ដំណោះស្រាយ ៖ ពង្រឹងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជន ដើម្បីអភិវឌ្ឍធនធានមនុស្សដែលមានជំនាញខ្ពស់ ឆ្លើយតបនឹងនិន្នាការអភិវឌ្ឍសេដ្ឋកិច្ច និងផ្សារភ្ជាប់ទំនាក់ទំនងរវាងសាកលវិទ្យាល័យសាធារណៈ ឯកជន និងសហគ្រាស។
- បញ្ហាប្រឈម ៖ ការអភិវឌ្ឍជំនាញបច្ចេកទេសនិងជំនាញទន់សម្រាប់យុវជន។
- ដំណោះស្រាយ ៖ បង្កើនការចូលរៀនផ្នែកអប់រំបច្ចេកទេស និងផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា។ ការប្រកួតប្រជែងជំនាញបច្ចេកទេស សំដៅត្រៀមលក្ខណៈសម្រាប់សមាហរណកម្មអាស៊ានក្នុងឆ្នាំ ២០១៥ ដើម្បីឆ្លើយតបបានទៅនឹងសេចក្តីត្រូវការទីផ្សារពលកម្ម និងបង្កើនឱកាសទទួលបានការងារ។
- បញ្ហាប្រឈម៖ ការអភិវឌ្ឍការអប់រំកាយនិងកីឡាដើម្បីត្រៀមរៀបចំកីឡាស៊ីហ្គេមនៅឆ្នាំ២០២៣
- ដំណោះស្រាយ៖ រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍវិស័យកីឡានិងយន្តការសម្រាប់អនុវត្ត ។



# ជំពូកទី ២
# អាទិភាពនៃការអភិវឌ្ឍជាតិ និង
# គោលនយោបាយអប់រំ ២០១៤-២០១៨

## ២.១ បរិការណ៍នៃការអភិវឌ្ឍជាតិ

**ចក្ខុវិស័យ ២០៣០៖ កសាងសេដ្ឋកិច្ច មានការប្រកួតប្រជែង សុខដុមនីយកម្ម និងនិរន្តរភាព**

ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល គឺកសាងសង្គមកម្ពុជាមួយដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម កំណើនសេដ្ឋកិច្ចរយៈពេលវែង ការអភិវឌ្ឍប្រកបដោយចីរភាពនិងសមធម៌ ការកែលម្អជីវភាពនិងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការការពារបរិស្ថាន ការលើកស្ទួយវប្បធម៌និងអត្តសញ្ញាណជាតិ ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ ប្រជាធិបតេយ្យសេរីពហុបក្ស ព្រមទាំងការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្សនិងមានកោសិការផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់និងវប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារ ព្រមទាំងមានកិត្យានុភាពខ្ពស់លើឆាកអន្តរជាតិ។

កម្ពុជាសង្ឃឹមថានឹងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងឈានទៅជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។ រាជរដ្ឋាភិបាលបានកំណត់គោលដៅយុទ្ធសាស្ត្រ ៤ រួមមាន ១) ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ ៧ ភាគរយ ប្រកបដោយចីរភាព ២) បង្កើតការងារឱ្យបានកាន់តែច្រើនជូនដល់ប្រជាជន ពិសេសសម្រាប់ស្រទាប់យុវជន ៣) សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង ១ ភាគរយក្នុងមួយឆ្នាំ និង៤) បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ។

រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើវិស័យអភិវឌ្ឍធនធានមនុស្ស ដែលនឹងធានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្មក្នុងតំបន់ដែលកាន់តែបើកចំហរ តាមរយៈ ១) ការបណ្តុះបណ្តាលពលករឱ្យមានជំនាញនិងផលិតភាពខ្ពស់តាមសេចក្តីត្រូវការនៃទីផ្សារ និងអាចបង្កើតតម្លៃបន្ថែមខ្ពស់ ២) ការរៀបចំក្របខណ្ឌគតិយុត្តនិងកសាងស្ថាប័នអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ៣) លើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមក្នុងកិច្ចការនេះ និង៤) ការពង្រឹងគុណភាពនៃការអប់រំនិងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## ២.២ គោលនយោបាយនិងអាទិភាពសម្រាប់ការអភិវឌ្ឍជាតិ

ដើម្បីឆ្លើយតបនឹងចក្ខុវិស័យជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨ ត្រូវកំណត់ច្បាស់ថា កម្ពុជានឹងឆ្លើយតបទៅនឹងការធ្វើសមាហរណកម្មអាស៊ានក្នុងឆ្នាំ ២០១៥ និងកសាងគ្រឹះសម្រាប់ការប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមក្នុងឆ្នាំ ២០៣០។ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍនៅមូលដ្ឋាន រាជរដ្ឋាភិបាលបានប្តេជ្ញាផ្ទេរមុខងារនិងការទទួលខុសត្រូវដល់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ នៅក្នុងរយៈពេលវែង រដ្ឋបាលឯកភាពមួយនឹងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាល រួមបញ្ចូលទាំងការិយាល័យនានារបស់ក្រសួងស្ថាប័ន។ ដំណើរការផ្ទេរមុខងារនិង

ការទទួលខុសត្រូវជាបណ្ដើរៗនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌គឺជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចនិងភាពប្រកួតប្រជែងរបស់ប្រទេសទាំងពេលចំពោះមុខ និងសម្រាប់អនាគត ជាពិសេសក្នុងពេលដែលកម្ពុជាឈានចូលទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងពេលដ៏ខ្លីខាងមុខ ហើយបន្តឡើងទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ ២០៥០ តាមចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ការអភិវឌ្ឍធនធានមនុស្សគឺសំដៅទៅលើការកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញការច្នៃប្រឌិត និងនវានុវត្តន៍លើគ្រប់ផ្នែក គ្រប់វិស័យ ពិសេសផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ព្រមទាំងសមត្ថភាពក្នុងការស្រាវជ្រាវនិងការអភិវឌ្ឍ។ ទន្ទឹមនឹងនេះការលើកស្ទួយគុណភាពផ្នែកសុខភាព កាយសម្បទា សីលធម៌ ស្មារតីទទួលខុសត្រូវ និងមនសិការស្នេហាជាតិ និងវិជ្ជាជីវៈ ដោយគ្មានការរើសអើងខាងយេនឌ័រ រួមជាមួយនឹងប្រព័ន្ធសុវត្ថិភាពសង្គមគត់មត់។

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពនិងសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាដែលជាកត្តាគន្លឹះ សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងក្នុងពេលចំពោះមុខ និងសម្រាប់អនាគតរយៈពេលវែង នៅតែជាបញ្ហាប្រឈមដ៏ចម្បងរបស់រាជរដ្ឋាភិបាល។ ជាក់ស្ដែង ក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលត្រូវបន្តផ្ដោតអាទិភាពលើការពង្រឹងគុណភាព ភាពអាចឆ្លើយតបបានទៅនឹងសេចក្ដីត្រូវការនៃទីផ្សារពលកម្ម និងការអភិវឌ្ឍជំនាញបច្ចេកទេសសម្រាប់យុវជន ដើម្បីបង្កើនឱកាសការងារ និងប្រើប្រាស់ឱ្យអស់នូវសក្ដានុពលនៃផលលាភប្រជាសាស្ត្ររបស់កម្ពុជា ក៏ដូចជាដើម្បីធានាការបន្តវេនក្នុងការដឹកនាំនិងអភិវឌ្ឍប្រទេស។

## ២.៣ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ចក្ខុវិស័យ**របស់ក្រសួងអប់រំ យុវជន និង កីឡាគឺ កសាងនិងអភិវឌ្ឍធនធានមនុស្សប្រកប ដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

ដើម្បីសម្រេចបានតាមចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និង កីឡាមាន**បេសកកម្ម**ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និង កីឡានៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និងសកលលោក ។

វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យនិងបណ្ដុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណ

ធមិខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថាយុវជននិងកុមារកម្ពុជាគ្រប់រូបមានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួនពួកគេនឹងមានចំណេះដឹងស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេសជាតិ ។

ប្រទេសកម្ពុជាបានឈានចូលក្នុងដំណាក់កាលមួយថ្មីទៀតនៃការអភិវឌ្ឍវិស័យអប់រំ ដែលចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹងការអប់រំមូលដ្ឋាន និងគុណភាពសិក្សានៅក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចជាតិ ដែលមានលក្ខណៈជាប្រព័ន្ធដ៏ទូលំទូលាយ។ ចក្ខុវិស័យអប់រំសម្រាប់រយៈពេលវែងរបស់កម្ពុជា នឹងយកចិត្តទុកដាក់ផ្តល់សេវាអប់រំចាប់ពីអប់រំកុមារតូចតាមគ្រប់រូបភាព ដែលជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការអប់រំនៅកម្រិតបន្តបន្ទាប់ទៀត និងយកចិត្តទុកដាក់ដល់សិស្សានុសិស្សនៅកម្រិតដំបូងនៃបឋមសិក្សាលើបំណិនអំណាននិងលេខនព្វន្ត។ វិស័យអប់រំនឹងពង្រីកវិសាលភាពនៃការអប់រំសម្រាប់ទាំងអស់គ្នាពីបឋមសិក្សា ៦ ឆ្នាំ ទៅដល់អប់រំមូលដ្ឋាន ៩ ឆ្នាំ។ សិស្សានុសិស្សដែលបញ្ចប់ការសិក្សាអប់រំមូលដ្ឋាននឹងត្រូវពិនិត្យមើលឧបនិស្ស័យ ក្នុងការជ្រើសរើសបន្តការសិក្សានៅអប់រំមធ្យមសិក្សាចំណេះទូទៅ ឬក៏ជ្រើសរើសផ្នែកអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ។ ការលើកកម្ពស់គុណភាពនៃការអប់រំ ក៏ត្រូវផ្តោតលើការលើកកម្ពស់គុណភាពរបស់ធាតុចូល ដំណើរការរៀននិងបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។ គុណភាពរបស់ធាតុចូល នឹងផ្តោតសំខាន់លើគុណវុឌ្ឍិគ្រូបង្រៀន ដែលនឹងត្រូវបង្កើនរូបមន្តពី ១២ បូក ២ ទៅដល់ ១២ បូក ៤ នៅឆ្នាំ ២០២០។ គុណភាពរបស់កម្មវិធីសិក្សានៅអប់រំចំណេះទូទៅនិងឧត្តមសិក្សាឱ្យស្របនឹងគុណភាពស្តង់ដារអាស៊ាន។

## ២.៤ គោលវិធីក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨

ការធ្វើសមាហរណកម្មទៅក្នុងសមាគមអាស៊ានឆ្នាំ ២០១៥ និងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមឆ្នាំ ២០៣០ ទាមទារឱ្យមានការវិនិយោគបន្ថែមទៀតក្នុងវិស័យអប់រំ។ ធនធានមនុស្សដែលមានវិជ្ជាជីវៈត្រឹមត្រូវ និងមានគុណភាព ព្រមទាំងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ក៏ត្រូវដាក់ចូលក្នុងវិស័យអប់រំផងដែរ (ប្រទេសក្នុងអាស៊ានដែលជោគជ័យ ក៏ទទួលបទពិសោធពីការបង្កើនការវិនិយោគទៅក្នុងវិស័យអប់រំ ៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប)។

ក្រសួងអប់រំ យុវជន និងកីឡាទទួលស្គាល់ពីសារៈសំខាន់ក្នុងការជំរុញឱ្យវិស័យទាំងមូលអាចធ្វើការជាមួយគ្នា ដើម្បីឆ្លើយតបនឹងតម្រូវការសង្គមនិងសេដ្ឋកិច្ច។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ

២០១៩-២០២៣ ផ្តោតលើការពង្រឹងសមិទ្ធផលដែលមានកន្លងមក ការឈានទៅដល់ក្រុមជួបការលំបាក ការផ្តល់ការអប់រំប្រកបដោយគុណភាពនិងភាពឆ្លើយតបសម្រាប់ការអភិវឌ្ឍប្រទេស។ ការផ្តល់សេវាអប់រំប្រកបដោយវិជ្ជាជីវៈនិងគណនេយ្យភាព ជាមូលដ្ឋានសម្រាប់កសាងសង្គមមួយប្រកបដោយចំណេះដឹងនិងជំនាញ។ វិស័យអប់រំនឹងរៀបចំនូវក្របខណ្ឌធានាគុណភាពទូទាំងវិស័យ ដោយផ្អែកលើស្តង់ដារនៃការសិក្សារៀនសូត្រនិងការផ្តល់សេវាដែលឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ សហគមន៍និងទីផ្សារការងារ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំនឹងឈរលើមូលដ្ឋាននៃការគ្រប់គ្រង និងការកសាងផែនការថវិកាផ្តោតលើលទ្ធផលនឹងត្រូវរៀបចំតាមអនុវិស័យសំខាន់ៗ ៧ ដូចជាការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស ការអប់រំឧត្តមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍយុវជន និងការអប់រំកាយនិងកីឡា។

ការងាររបស់អនុវិស័យទាំងនេះរួមបញ្ចូលទាំងការអភិវឌ្ឍគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា និងសម្ភារៈរៀននិងបង្រៀន ការរៀបចំក្របខណ្ឌធានាគុណភាព ការអភិវឌ្ឍបែបវិមជ្ឈការនិងវិសហមជ្ឈការនឹងគាំទ្រដោយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនិងធនធានមនុស្ស។

## ២.៥ គោលនយោបាយ យុទ្ធសាស្ត្រ សូចនាករស្នូល និងចំណុចដៅអប់រំ

### ២.៥.១ គោលនយោបាយអប់រំ

**គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌**

កុមារគ្រប់រូបបានទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងមានឱកាសបន្តការសិក្សាទៅមុខទៀត។ សម្រាប់កុមារដែលពុំមានលទ្ធភាពចូលរៀនក្នុងប្រព័ន្ធ ជម្រើសផ្សេងទៀតនឹងត្រូវផ្តល់លទ្ធភាពឱ្យអ្នកទាំងនោះទទួលបានការអប់រំ។

ការបង្កើនចំនួនកុមារនិងយុវជនឱ្យទទួលបានការអប់រំនៅគ្រប់កម្រិត ដោយផ្តោតលើសមធម៌ និង តំបន់និងក្រុមកុមារជួបការលំបាក។ ការបង្កើនឱកាសដល់សិស្សដែលបញ្ចប់ការសិក្សានៅថ្នាក់ទី ១២ ឱ្យទទួលបាននូវចំណេះដឹងនិងជំនាញក្នុងការគិតនិងហេតុផល និងអាចជាមូលដ្ឋានសម្រាប់បន្តការសិក្សានៅក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងឧត្តមសិក្សាតទៅទៀត។

**គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងភាពឆ្លើយតប**

កុមារនិងយុវជនគ្រប់រូបមានបទពិសោធក្នុងការសិក្សា ប្រកបដោយគុណភាពនិងភាពឆ្លើយតបដែលអាចឱ្យពួកគេអាចចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ។

ការធានាថា ការអប់រំប្រកបដោយគុណភាព និងមានទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់ប្រទេស។ ក្របខណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សា មាតាបិតា សហគមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រង ជាមួយនឹងស្តង់ដារនៃផលសម្រេច ការពិនិត្យតាមដាននិងរបាយការណ៍។

**គោលនយោបាយទី ៣ ៖ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

ការផ្តល់សេវាអប់រំនឹងត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាពនិងទន់ភ្លន់។ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងវិជ្ជាជីវៈនឹងផ្តល់នូវតម្លៃដ៏ល្អបំផុត (ផ្តោតលើលទ្ធផល) ទាន់ពេលវេលា ការពិនិត្យតាមដាននិងរបាយការណ៍នូវលទ្ធផលនិងយោបល់ត្រឡប់ វិធានការប្រកបដោយគណនេយ្យភាព និង យន្តការសម្រាប់កែលម្អគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈនឹងអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការជាក់ស្តែងនៅកម្រិតសាលារៀន។

## ២.៥.២ សូចនាករស្នូល

| សូចនាករស្នូល | ស្ថានភាពបច្ចុប្បន្ន ២០១២-២០១៣ | ចំណុចដៅ ២០១៧-២០១៨ |
|---|---|---|
| គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | | |
| ១ - ភាគរយកុមារអាយុ៥ឆ្នាំ ក្នុងការអប់រំកុមារតូចគ្រប់រូបភាព | ៥៦,៥% | ៨០% |
| ២- ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច ៨០ ភាគរយ | ១១៩ | ១៩៤ |
| ៣- ចំនួនខេត្តដែលបានសម្រេចអត្រាបញ្ចប់មធ្យមសិក្សាបឋមភូមិយ៉ាងតិច ៤០ ភាគរយ | ៧ | ១៧ |
| គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងភាពឆ្លើយតប | | |
| ៤- អត្រាអក្ខរកម្មយុវជន (អាយុ ១៥-២៤) | ៩១,៥% | ៩៧,៥% |
| ៥- អត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥-៤៥) | ៨៧,០៥% | ៩០,៥% |
| ៦- ការវាយតម្លៃថ្នាក់ជាតិលទ្ធផលសិក្សារបស់សិស្សថ្នាក់ ទី ៣ ទី ៦ និងទី ៨ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | កំពុងអនុវត្តថ្នាក់ទី៣ | អនុវត្តថ្នាក់ទី៨ |
| ៧- ចំនួនគ្រូបង្រៀនឧត្តមសិក្សាមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ | ៦៣១១ នាក់ | ៧៣១១ នាក់ |
| ៨- ចំនួនគ្រូបង្រៀនឧត្តមសិក្សាមានសញ្ញាបត្របណ្ឌិត | ៨០៨ នាក់ | ១០៥៨ នាក់ |
| គោលនយោបាយទី៣ ៖ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | |
| ៩- ភាគរយថវិកាកម្មវិធីធៀបនឹងថវិកាសរុបក្រសួងអប់រំ យុវជន និងកីឡា | ១៣,៦៩% (នៅឆ្នាំ២០១៣) | ១០០% |
| ១០- ភាគរយការទូទាត់ចំណាយថវិកាកម្មវិធី | ៨៦,៧% | ១០០% |

## ២.៥.៣ គោលការណ៍របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨

ក្របខណ្ឌយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ នឹងផ្តោតលើការបន្តសកម្មភាព ការពង្រីក និងការបន្តនិរន្តរភាពនៃសមិទ្ធផលដែលបានសម្រេចកន្លងមកទាក់ទងនឹងការចូលរៀន

ការលើកកម្ពស់សមធម៌ ការបង្កើនគុណភាពនិងភាពឆ្លើយតបសម្រាប់កុមារនិងយុវជន តាមរយៈការផ្តល់សេវាអប់រំប្រកបដោយវិជ្ជាជីវៈ តម្លាភាព និងគណនេយ្យភាព។

ដើម្បីសម្រេចបានវត្ថុបំណងគោលនយោបាយនិងកម្មវិធីនានា ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

- ផ្សារភ្ជាប់ទៅនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងចូលរួមក្នុងដំណើរការបង្កើតរដ្ឋបាលឯកភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមការណែនាំពីគណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។
- រៀបចំយន្តការប្រតិបត្តិទាំងក្នុងនិងក្រៅ និងប្រព័ន្ធការងារទាំងខ្សែទទឹងនិងខ្សែបណ្តោយ ប្រព័ន្ធព័ត៌មាន និងមុខងារប្រតិបត្តិ ដែលឆ្លុះបញ្ចាំងពីការគ្រប់គ្រងតាមបែបអនុវិស័យ និងស្របតាមវត្ថុបំណងគោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការរបស់ក្រសួង។
- ឆ្លើយតបនឹងក្របខណ្ឌនៃការកសាងផែនការ ការគ្រោងថវិកា ការពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល។
- ផ្អែកលើគោលការណ៍សិទ្ធិ និងសមធម៌។
- ផ្តល់ជាក្របខណ្ឌគុណភាពទូលំទូលាយមួយ ដែលរួមបញ្ចូលទាំងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (ផ្សារភ្ជាប់នឹងការវាយតម្លៃនៅថ្នាក់តំបន់និងអន្តរជាតិ) កម្មវិធីសិក្សានិងសម្ភារៈសិក្សា ជំនាញនិងចំណេះដឹងក្នុងការបង្រៀន សម្ភារៈ ការគ្រប់គ្រង និងស្តង់ដាររបស់សេវាអប់រំ។
- លើកកម្ពស់និរន្តរភាពផ្នែកហិរញ្ញវត្ថុ តាមរយៈការធ្វើចំណោលផ្អែកតាមតម្រូវការ។
- កៀរគរការចូលរួមរបស់អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ។

## ២.៥.៤ កម្មវិធីអាទិភាព

- *កម្មវិធីពង្រីកការគាំពារនិងអប់រំកុមារតូច* ៖ ជាមូលដ្ឋានសម្រាប់ការសិក្សានៅភូមិសិក្សាបន្ទាប់ទៀត ដោយផ្តល់នូវការអប់រំសុខភាព បំណិន និងចំណេះដឹង ដើម្បីចូលរួមការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈការបង្កើនការចូលរៀនឱ្យបាន ៨០ ភាគរយនៃកុមារតូច នៅតាមសាលាមត្តេយ្យសិក្សារដ្ឋ សាលាមត្តេយ្យសិក្សាឯកជន សាលាមត្តេយ្យសិក្សាសហគមន៍ និងអប់រំកុមារតូចតាមផ្ទះ តាមខ្នងផ្ទះ។
- *កម្មវិធីអភិវឌ្ឍនិងសាងសង់សាលារៀន* ៖ ធានាថាកុមារទាំងអស់បានចូលរៀននៅបឋមសិក្សា និងចូលរៀនកាន់តែច្រើនឡើងនៅមធ្យមសិក្សា តាមរយៈការសាងសង់សាលារៀន (ជាពិសេសការពង្រីកសាលាបឋមសិក្សាទៅជាអនុវិទ្យាល័យឱ្យបានច្រើនតាមឃុំ សង្កាត់ ស្របតាម

កំណើនសិស្ស) ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន ការផ្គត់ផ្គង់គ្រូ ការផ្តល់សៀវភៅសិក្សាគោលនិងបរិក្ខារបណ្ណាល័យ ការបំប៉ននាយកសាលារៀន បន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បន្ទប់សិក្សាភាសាបរទេស រោងជាង និងទីលានកីឡា។

- *កម្មវិធីអភិវឌ្ឍប្រព័ន្ធធានាគុណភាពអប់រំនិងគុណភាពសាលារៀន* ៖ សម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ ការអភិវឌ្ឍក្របខ័ណ្ឌគុណភាពនិងឧបករណ៍ ការអភិវឌ្ឍសមត្ថភាពក្នុងការជួយសាលារៀននិងគ្រូបង្រៀន ដើម្បីសម្រេចបានស្តង់ដារគុណភាពនិងភាពឆ្លើយតប តាមរយៈការអភិវឌ្ឍកម្មវិធីសិក្សាឱ្យមានភាពឆ្លើយតប សម្ភារៈសិក្សាគ្រប់គ្រាន់ និងការបង្រៀនប្រកបដោយឧត្តមភាព។
- *កម្មវិធីពង្រឹងប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិនិងអន្តរជាតិ* ៖ ពង្រឹងការធ្វើតេស្តថ្នាក់រៀនជាប្រចាំនិងតេស្តវាយតម្លៃថ្នាក់ជាតិ ការកែទម្រង់ការប្រឡងថ្នាក់ជាតិ និងការត្រៀមខ្លួនចូលរួមក្នុងកម្មវិធីវាយតម្លៃការសិក្សារបស់សិស្សថ្នាក់អន្តរជាតិ។
- *កម្មវិធីអាហារូបករណ៍* ៖ ពង្រីកវិសាលភាពដល់បឋមសិក្សានិងមធ្យមសិក្សា និងផ្តោតលើការកំណត់ក្រុមគោលដៅ ការពិនិត្យតាមដាន និងវាយតម្លៃកម្មវិធី។
- *កម្មវិធីអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ* ៖ អនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិថ្នាក់ជាតិ ដើម្បីបង្កើនគុណភាពនៃការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ និងរៀបចំស្ថាប័នសម្របសម្រួលជាមួយនឹងអ្នកពាក់ព័ន្ធដទៃទៀត។
- *កម្មវិធីគ្រប់គ្រងនិងវាយតម្លៃការបំពេញការងាររបស់បុគ្គលិក* ៖ បង្កើនគុណភាពនៃការបង្រៀន ការវាយតម្លៃ ការសរសើរ ការលើកទឹកចិត្ត និងការអភិវឌ្ឍវិជ្ជាជីវៈ។
- *កម្មវិធីអភិវឌ្ឍឧត្តមសិក្សា* ៖ កែទម្រង់ប្រព័ន្ធអប់រំនៅឧត្តមសិក្សាឱ្យមានលក្ខណៈជាប្រព័ន្ធ ស្របជាមួយនឹងស្តង់ដារក្នុងតំបន់និងអន្តរជាតិ លើកកម្ពស់គុណភាពនៃដំណើរការរបស់ប្រព័ន្ធការបង្រៀននិងស្រាវជ្រាវលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា។
- *កម្មវិធីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល* ៖ កសាង អភិវឌ្ឍសមត្ថភាព និងផ្លាស់ប្តូររបៀបរបបការងារដើម្បីអនុវត្តការកសាងផែនការ ការរៀបចំថវិកា និងប្រព័ន្ធពិនិត្យតាមដានផ្អែកលើលទ្ធផល នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- *កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុអប់រំនិងហិរញ្ញប្បទាន* ៖ អភិវឌ្ឍសមត្ថភាពក្នុងការរៀបចំនិងការអនុវត្តថវិកា ការដេញថ្លៃ ការធ្វើវិមជ្ឈការងារថវិកាដល់សាលារៀន ការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុ និងការពង្រឹងការងារសវនកម្ម។
- *កម្មវិធីអក្ខរកម្មនិងរៀនពេញមួយជីវិត* ៖ អនុវត្តកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ និងកំណត់យន្តការច្បាស់លាស់សម្រាប់អនុវត្តកម្មវិធីអក្ខរកម្មនិងរៀនពេញមួយជីវិត ដើម្បីបង្កើតធនធាន

មនុស្សដែលអាចសម្របខ្លួន និងទទួលបានអត្ថប្រយោជន៍ពីឱកាសនានា ក្នុងបរិបទសង្គម វប្បធម៌ និងបរិស្ថានសេដ្ឋកិច្ច។

- *កម្មវិធីសម្របសម្រួលក្នុងវិស័យនិងអន្តរវិស័យ* ៖ បង្កើតយន្តការប្រតិបត្តិដែលស្អិតរមួតនិងរលូន សម្រាប់អនុវិស័យទាំងអស់។
- *បញ្ហាឆ្លងវិស័យ* ៖ ក្រសួងនឹងបន្តដោះស្រាយបញ្ហាឆ្លងវិស័យនានាដូចជា ទី១) យេនឌ័រ ដោយផ្តោតសំខាន់លើការអប់រំនៅគ្រប់កម្រិតសិក្សា ជាពិសេសការផ្តល់អាហារូបករណ៍ និងការអភិវឌ្ឍសមត្ថភាពមន្ត្រីជានារី ទី២) ការកាត់បន្ថយគ្រោះមហន្តរាយ ទី៣) ការថែរក្សាបរិស្ថានតាមរយៈការធានាថារាល់បញ្ហាត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីសិក្សា និងទី៤) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈសហការជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ថ្នាក់ជាតិ។



# ជំពូកទី ៣
# ផែនការតាមអនុវស័យ
# ឆ្នាំ ២០១៤-២០១៨

# ៣.១ អនុវិស័យ ការអប់រំកុមារតូច

## ៣.១.១ សាវតារ

ក្នុងឆ្នាំសិក្សា២០១២-២០១៣ កុមារអាយុ៥ឆ្នាំ ៥៦,៨៩ ភាគរយ បានចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច ធៀបនឹងឆ្នាំសិក្សា ២០០៨-២០០៩ មានត្រឹមតែ ៣៥ ភាគរយ ។ កុមារអាយុ ៣-៤ ឆ្នាំបានចូលរៀន ២១,២៣ ភាគរយ ។ ប៉ុន្តែការទទួលបានសេវាអប់រំកុមារតូចអាយុ ០ ទៅក្រោម ៣ ឆ្នាំ សម្រេចបានតែ ៣,១៩ ភាគរយប៉ុណ្ណោះ។

វឌ្ឍនភាពដែលទទួលបានទាំងនេះ ដោយសារមានការពង្រីកចំនួនសាលាមត្តេយ្យសិក្សាសហគមន៍ ថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សាឯកជន និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ ខ្ទងផ្ទះ។ ទោះជាយ៉ាងណា វិសាលភាពនៃការពង្រីកនេះនៅមានកម្រិតនៅឡើយ ដោយសារកង្វះធនធានរូបវន្តនិងហិរញ្ញវត្ថុ ព្រមទាំងសមត្ថភាព។ តម្រូវការនិងគុណភាពនៃសេវាអប់រំនៅកម្រិតនេះនៅមានកម្រិត និងមានគម្លាតរវាងទីតាំងភូមិសាស្ត្រមួយទៅភូមិសាស្ត្រមួយទៀត ជាពិសេសនៅតំបន់ដែលមានការចូលរៀននៅបឋមសិក្សាមានកម្រិតទាប និងបោះបង់ការសិក្សាខ្ពស់។ អនុវិស័យនេះបានផ្តោតការយកចិត្តទុកដាក់តិចតួចលើបញ្ហាអាហារូបត្ថម្ភ ការគាំពារ និងសុខភាពរបស់កុមារតូច។

ក្នុងពេលបច្ចុប្បន្ន ក្របខណ្ឌធានាគុណភាពមិនទាន់បានរៀបចំ និងមានតែគ្រូមត្តេយ្យសិក្សានៅសាលាសាធារណៈប៉ុណ្ណោះ ដែលបានទទួលវិក្រឹតការស្តីពីបច្ចុប្បន្នភាពកម្មវិធីសិក្សា។ គ្រូមត្តេយ្យសិក្សាសហគមន៍និងក្រុមម្តាយបង្គោលនៃកម្មវិធីអប់រំកុមារតូចតាមផ្ទះនិងខ្ទងផ្ទះ បានទទួលការបំប៉នតិចតួច ការផ្តល់សម្ភារៈរៀននិងបង្រៀននៅមានកម្រិត និងការអភិវឌ្ឍសម្ភារូបវន្តមត្តេយ្យសិក្សាសហគមន៍មិនទាន់ជាចំណុចអាទិភាពនៅឡើយ។

អន្តរាគមន៍គោលនយោបាយក្នុងអំឡុង ២០០៩-២០១៣ បានផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការឈានទៅបង្កើនគុណភាពនៃសេវាអប់រំកុមារតូចនៅឆ្នាំ២០១៨។ មូលដ្ឋានគ្រឹះទាំងនោះមានដូចជាការរៀបចំគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ការបង្កើតគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច ប្រកាសស្តីពីការគ្រប់គ្រងសាលាមត្តេយ្យសិក្សាឯកជន និងប្រកាសស្តីពីការទទួលស្គាល់គ្រូបង្គោលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ គោលការណ៍ប្រតិបត្តិសម្រាប់មត្តេយ្យសិក្សាសហគមន៍ កម្មវិធីអប់រំមាតាបិតារួមបញ្ចូលទាំងស្ត្រីមានផ្ទៃពោះនិងមាតាបិតាដែលមានកូនអាយុក្រោម ២ ឆ្នាំ និងគោលការណ៍ប្រតិបត្តិសម្រាប់សាលាមត្តេយ្យសិក្សាធនធាន។

## ៣.១.២ វត្ថុបំណងគោលនយោបាយ

- បង្កើនការចូលរៀននិងការគាំពារដល់កុមារអាយុ ០ ដល់ក្រោម ៦ ឆ្នាំ ជាពិសេស កុមារមកពីគ្រួសារក្រីក្រ ជនជាតិដើមភាគតិច និងកុមារមានពិការភាព ព្រមទាំងផ្តល់អាទិភាពដល់សាលាមត្តេយ្យសិក្សាសហគមន៍ និងអប់រំកុមារតូចតាមផ្ទះនិងខ្ទងផ្ទះ

- លើកកម្ពស់គុណភាពគ្រប់សេវាអប់រំ ការគាំពារ អាហារូបត្ថម្ភ និងសុខភាព ព្រមទាំងបង្កើនការប្រើប្រាស់សេវាសុខាភិបាល
- ធានាប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលដំណើរការពេញលេញ ដើម្បីគាំទ្រដល់ការគាំពារនិងអភិវឌ្ឍកុមារតូច ។

## ៣.១.៣ សកម្មភាពគោលនយោបាយ

- រៀបចំផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច នៅឆ្នាំ ២០១៤
- ដាក់ឱ្យអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យអប់រំកុមារតូច នៅឆ្នាំ ២០១៤
- រៀបចំគោលការណ៍ណែនាំសម្រាប់អប់រំមាតាបិតានិងអាណាព្យាបាល ស្តីពីសេវាអាហារូបត្ថម្ភ ការគាំពារ កិច្ចការពារកុមារ និងការប្រើប្រាស់សេវាសុខាភិបាល នៅឆ្នាំ ២០១៤
- រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងនិងដំណើរការសាលាមត្តេយ្យសិក្សាធនធាន នៅឆ្នាំ ២០១៤
- កែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះនិងខ្នងផ្ទះ នៅឆ្នាំ ២០១៤
- កែសម្រួលភារកិច្ចនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអប់រំកុមារតូច ឆ្លើយតបនឹងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ នៅឆ្នាំ ២០១៤
- រៀបចំគោលការណ៍បង្កើនក្របខណ្ឌបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ឆ្នាំ ២០១៤
- កែសម្រួលតួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ផ្នែកអប់រំកុមារតូចនៅថ្នាក់ក្រោមជាតិឆ្នាំ២០១៤
- រៀបចំផែនការការងារប្រចាំឆ្នាំនៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច នៅឆ្នាំ ២០១៥
- រៀបចំគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងនិងដំណើរការមត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះនិងខ្នងផ្ទះ នៅឆ្នាំ ២០១៥
- រៀបចំសេចក្តីណែនាំសម្រាប់ផ្នែកឯកជន កសិដ្ឋាន និងសហគ្រាសធំៗ ឱ្យចូលរួមចំណែកលើការងារអប់រំកុមារតូចតាមគ្រប់រូបភាព ឆ្នាំ ២០១៥
- រៀបចំគោលការណ៍អភិបាលកិច្ចល្អនៅគ្រឹះស្ថានមត្តេយ្យសិក្សា នៅឆ្នាំ ២០១៤
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយគ្រូបង្រៀន នៅឆ្នាំ ២០១៥។

### ៣.១.៤ យុទ្ធសាស្ត្រ

- ពង្រីកសេវាអប់រំកុមារតូចគ្រប់រូបភាពនិងគ្រប់ទីកន្លែង ជាពិសេសតំបន់ដែលមានអត្រាចូលរៀនថ្មី និងអត្រាពិតនៃការសិក្សាទាប អត្រាបោះបង់ការសិក្សាខ្ពស់ និងតំបន់ដែលមានស្ថានភាពអាហារូបត្ថម្ភ ការគាំពារ កិច្ចការពារកុមារ និងការប្រើប្រាស់សេវាសុខាភិបាលនៅទាប
- ពង្រឹងនិងពង្រីកមត្តេយ្យសិក្សាសហគមន៍ពីរភាសាសម្រាប់តំបន់ជនជាតិដើមភាគតិច
- ពង្រីកកម្មវិធីអប់រំបញ្ចូលគ្នា សម្រាប់កុមារមានពិការភាព នៅតាមសាលាមត្តេយ្យសិក្សារដ្ឋ និង មត្តេយ្យសិក្សាសហគមន៍
- ផ្តល់អាហារូបត្ថម្ភ និងលើកកម្ពស់សុខភាពសិក្សា សម្រាប់មត្តេយ្យសិក្សាគ្រប់រូបភាព
- ផ្តល់ធាតុចូលមានគុណភាពនិងគាំទ្របច្ចេកទេសដល់មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំតាមផ្ទះស្របតាមស្តង់ដារ (ការបំប៉នគ្រូ កម្មវិធីសិក្សា កម្មវិធីអប់រំកាយនិងសុខភាព សម្ភារៈបង្រៀននិងរៀនក្នុងនិងក្រៅថ្នាក់ ទីតាំង)
- អភិវឌ្ឍប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន តាមរយៈការរៀបចំស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន បញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ ៩ បូក ២ បណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់ក្របខ័ណ្ឌ រដ្ឋ និងឯកជន
- ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូមត្តេយ្យសិក្សា
- ពង្រឹងការគ្រប់គ្រង ការធ្វើផែនការ ការបំពេញការងារ និងការពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ព្រមទាំងការធ្វើរបាយការណ៍
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធសម្រាប់ការគាំពារនិងអភិវឌ្ឍន៍កុមារតូច
- ពង្រឹងគោលការណ៍អភិបាលកិច្ច ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការធ្វើទំនើបកម្មលិខិតបទដ្ឋានគតិយុត្ត។

### ៣.១.៥ សូចនាករផលសម្រេច (សាធារណៈ ឯកជន និងសហគមន៍)

- ភាគរយកុមារអាយុ ៥ ឆ្នាំបានទទួលសេវាអប់រំកុមារតូចគ្រប់រូបភាព កើនឡើងពី ៥៦,៩៩ ភាគរយ នៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ៨០ ភាគរយ នៅឆ្នាំសិក្សា ២០១៧-២០១៨
- ភាគរយកុមារអាយុ ៤ ឆ្នាំបានទទួលសេវាអប់រំកុមារតូចគ្រប់រូបភាព កើនឡើងពី ២១,៥ ភាគរយ នៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ៤៥ ភាគរយ នៅឆ្នាំសិក្សា ២០១៧-២០១៨
- ភាគរយកុមារអាយុ ៣ ឆ្នាំបានទទួលសេវាអប់រំកុមារតូចគ្រប់រូបភាព កើនឡើងពី ២១,១ ភាគរយ នៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ៤០ ភាគរយនៅឆ្នាំសិក្សា ២០១៧-២០១៨

- ភាគរយសេវាអប់រំកុមារតូចដែលគោរពតាមស្តង់ដារគុណភាពកើនដល់ ៩០ ភាគរយនៅឆ្នាំសិក្សា ២០១៧-២០១៨
- ភាគរយសេវាអប់រំកុមារតូចដែលបានអនុវត្តតេស្តទៀងទាត់ ដើម្បីវាស់សមត្ថភាពកុមារអាយុ ៥ ឆ្នាំ កើនដល់ ៨០ ភាគរយ នៅឆ្នាំសិក្សា ២០១៧-២០១៨
- ភាគរយកុមារក្នុងសេវាគាំពារនិងអភិវឌ្ឍន៍កុមារតូច ដែលមានស្ថានភាពអាហារូបត្ថម្ភកើនដល់ ៩០ ភាគរយ នៅឆ្នាំសិក្សា ២០១៧-២០១៨
- ភាគរយកុមារនៅតាមសាលាមត្តេយ្យសិក្សាសាធារណៈយ៉ាងតិច ៩០ ភាគរយ បានទទួលថ្នាំទម្លាក់ព្រូន នៅឆ្នាំសិក្សា ២០១៧-២០១៨។

## ៣.១.៦ កម្មវិធីនិងសកម្មភាព

- ***ការប្រមូលកុមារចូលរៀននៅសាលាមត្តេយ្យសិក្សារដ្ឋ*** ៖ ផ្តល់ថវិកាទ្រទ្រង់ សម្ភារៈបង្រៀននិងរៀន សម្ភារៈប្រើប្រាស់ ការជួសជុលតូច សម្ភារៈការិយាល័យ ការប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍។
- ***ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូមត្តេយ្យសិក្សា*** ៖
  - បណ្តុះបណ្តាលនិងផ្គត់ផ្គង់គ្រូមត្តេយ្យសិក្សាចន្លោះពី ២០០ ទៅ ៣០០នាក់ក្នុងមួយឆ្នាំ
  - ផ្តល់ថវិកាដំណើរការប្រចាំឆ្នាំដល់ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ដើម្បីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សារដ្ឋ ការធ្វើវិក្រឹតការគ្រូមត្តេយ្យសិក្សាអំពីបច្ចេកទេសបង្រៀននិងខ្លឹមសារថ្មីៗ ដូចជាការអប់រំបញ្ចូលគ្នា ការអប់រំថ្នាក់ពីរភាសា
  - អភិវឌ្ឍកម្មវិធីនិងឯកសារបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ឱ្យសមស្របតាមស្តង់ដារនៃការបណ្តុះបណ្តាលគ្រូបង្រៀន
  - អភិវឌ្ឍសមត្ថភាពគ្រប់គ្រងនិងដឹកនាំនៅសាលាមត្តេយ្យសិក្សា
  - បំប៉នដំបូងនិងបំប៉នបន្តដល់គ្រូមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍។
- ***កម្មវិធីអប់រំកុមារតូចតាមផ្ទះ ខ្នងផ្ទះ*** ៖ បំប៉នដំបូងនិងបំប៉នបន្ត និងផ្តល់សម្ភារៈដំណើរការដល់ម្តាយបង្គោល គាំទ្រដល់ការប្រជុំក្រុមម្តាយ ទស្សនកិច្ចសិក្សា និងយុទ្ធនាការផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំកុមារតូច។
- ***ការអភិវឌ្ឍកម្មវិធីសិក្សា*** ៖ កែសម្រួលកម្មវិធីសិក្សា និងសម្ភារៈបង្រៀននិងរៀន ផ្អែកតាមស្តង់ដារសិក្សា ដោយផ្សារភ្ជាប់ជាមួយកម្មវិធីសិក្សារបស់បណ្តាប្រទេសក្នុងតំបន់។

- ***ការអប់រំមាតាបិតាឬអាណាព្យាបាល*** ៖ ផ្តល់ការអប់រំមាតាបិតា ផ្សារភ្ជាប់ជាមួយកម្មវិធីរបស់មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍។ ពង្រីកខ្លឹមសារក្នុងកម្មវិធីអប់រំកុមារតូចតាមផ្ទះ និងផ្តល់ការអប់រំដល់ស្ត្រីមានផ្ទៃពោះនិងមាតាបិតា ដែលមានកូនក្រោម ២ ឆ្នាំ។
- ***ការវាយតម្លៃថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ*** ៖ អភិវឌ្ឍសមត្ថភាពលើការរៀបចំប្រព័ន្ធពិនិត្យតាមដាននិងការគ្រប់គ្រងប្រព័ន្ធ រៀបចំនិងអនុវត្តប្រព័ន្ធធានាគុណភាពសាលាមត្តេយ្យសិក្សាគ្រប់រូបភាព។
- ***ការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ*** ៖ អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ជាពិសេសការផ្តល់ជំនួយបច្ចេកទេសនិងការគាំទ្រដល់គ្រូបង្គោលថ្នាក់ក្រោមជាតិសម្រាប់ការអភិវឌ្ឍកុមារតូចនៅតាមមូលដ្ឋាន និងលើកទឹកចិត្តដល់សាលាល្អនិងគ្រូល្អ។
- ***ការពិនិត្យសុខភាពនិងកាយសម្បទាកុមារមុនចាប់ផ្តើមចូលរៀន*** ៖ ពិនិត្យសុខភាព ស្ថានភាពអាហារូបត្ថម្ភនិងកាយសម្បទាកុមារ នៅពេលចាប់ផ្តើមឆ្នាំសិក្សាដំបូងនៅថ្នាក់មត្តេយ្យសិក្សា និងបន្តតាមដានស្ថានភាពសុខភាពរបស់កុមារ។ ចាក់ថ្នាំបង្ការនានា ផ្តល់ថ្នាំទម្លាក់ព្រូនពីរដងក្នុងមួយឆ្នាំ និងផ្តល់អាហារដែលមានមីក្រូសារធាតុដល់កុមារដោយសហការជាមួយក្រសួងសុខាភិបាល។
- ***ការអភិវឌ្ឍសម្ភាររូបវន្ត*** ៖
    - សាងសង់និងពង្រីកសាលាមត្តេយ្យសិក្សារដ្ឋ សាលាមត្តេយ្យសិក្សាសហគមន៍ និងសាលាមត្តេយ្យសិក្សាធនធាន ឱ្យស្របតាមស្តង់ដារគុណភាពដោយបំពាក់សម្ភាររូបវន្តផ្នែកអនាម័យ ទឹកស្អាត កន្លែងលាងសម្អាតដៃ ប្រអប់សង្គ្រោះបឋម និងរៀបចំទីធ្លាសម្រាប់ការលេងរបស់កុមារ។
    - កែលម្អហេដ្ឋារចនាសម្ព័ន្ធ សម្ភាររូបវន្តសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម។
- ***ការអភិវឌ្ឍក្របខណ្ឌច្បាប់ លិខិតបទដ្ឋាន ពង្រឹងអភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*** ៖ ធ្វើទំនើបកម្មច្បាប់និងគោលនយោបាយ ផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈវិស័យអប់រំ ប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្សនិងពលកម្មកុមារ ការលើកកម្ពស់យេនឌ័រ ជំរុញការអនុវត្តយន្តការប្រឆាំងអំពើពុករលួយ ពង្រឹងសមត្ថភាពដោះស្រាយនិងទប់ស្កាត់វិវាទក្នុងវិស័យអប់រំ។

## ៣.២ អនុវិស័យ ការអប់រំនៅបឋមសិក្សា

### ៣.២.១ សាវតារ

កុមារបានចូលរៀននៅបឋមសិក្សាកាន់តែច្រើន ជាក់ស្តែងអត្រាពិតនៃការសិក្សាបានកើនពី ៩៤,៨ ភាគរយ ឆ្នាំសិក្សា២០០៨-២០០៩ ដល់ ៩៧ ភាគរយ ឆ្នាំសិក្សា២០១២-២០១៣ និងគ្មានគម្លាតយេនឌ័រ។ អត្រាត្រួតថ្នាក់និងសិស្សបោះបង់ការសិក្សាបានថយចុះ។ សាលាបឋមសិក្សាមិនគ្រប់កម្រិតត្រូវបានបន្ថែមបន្ទប់រៀន ដើម្បីក្លាយជាសាលាគ្រប់កម្រិត។ ការសិក្សាអំពីកុមារពិការនិងកុមារក្រៅសាលាត្រូវបានធ្វើឡើងនៅតាមសាលារៀនមួយចំនួន។ សាលារៀនជាច្រើនក្នុងរាជធានី ខេត្ត ១២ បានអនុវត្តកម្មវិធីផ្តល់អាហារពេលព្រឹក។ សាលាបឋមសិក្សា ៥០ ភាគរយមានកន្លែងលាងសម្អាតដៃ ៨០,២ ភាគរយមានបង្គន់អនាម័យ ៥៨,៥ ភាគរយមានទឹកស្អាតប្រើប្រាស់។ ជាមួយគ្នានេះ សម្ភារបរិក្ខាមួយចំនួនដូចជា ប្រអប់សង្គ្រោះបឋម ធុងចម្រោះទឹកស្អាត ធុងសំរាមត្រូវបានផ្តល់ជាបណ្តើរៗដល់សាលាបឋមសិក្សាមួយចំនួន។

សាលាបឋមសិក្សាភាគច្រើនបានអនុវត្តតាមគោលនយោបាយសាលាកុមារមេត្រី។ ឧបករណ៍សម្រាប់វាយតម្លៃការសិក្សារបស់សិស្សត្រូវបានរៀបចំ និងបានបង្ហាញថាការសិក្សារបស់សិស្សបានល្អប្រសើរ ជាពិសេសមុខវិជ្ជាភាសាខ្មែរនៅកម្រិតថ្នាក់ដំបូង។ ការអប់រំពីរភាសាកំពុងត្រូវបានពង្រីក ក៏ដូចគ្នានឹងថ្នាក់ពន្លឿនការអប់រំ និងថ្នាក់គួបផងដែរ។ អាហារូបករណ៍ប្រមាណ ១៥ ០០០ បានផ្តល់ដល់សិស្សក្រីក្រនៅបឋមសិក្សា។ ថវិកាកែលម្អសាលារៀនត្រូវបានផ្តល់ជូនសាលារៀនប្រមាណ ៦០០ សាលាដែលនឹងពង្រីកទូទាំងប្រទេសក្នុងឆ្នាំសិក្សា ២០១៣-២០១៤។ គ្រូបង្រៀនជាច្រើននាក់ត្រូវបានបំប៉នអំពីប្រសិទ្ធភាពនៃការរៀននិងបង្រៀន។

តួនាទីរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មានសារៈសំខាន់ណាស់ក្នុងការគាំទ្រដល់ប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំ។ ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការគាំទ្រទាន់ពេលវេលាដល់សាលារៀន។ ក្រុមគ្រូឧទ្ទេសបង្គោលថ្នាក់ជាតិត្រូវបានបង្កើតឡើង ដើម្បីជួយដល់ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌនិងសាលារៀន។

ទោះយ៉ាងណា គម្លាតភូមិសាស្ត្រនិងសាលាបឋមសិក្សាមិនគ្រប់កម្រិតនៅតែជាឧបសគ្គសម្រាប់ការចូលរៀនរបស់កុមារ ជាពិសេសការចូលរៀនត្រឹមត្រូវតាមអាយុកំណត់។ លទ្ធផលសិក្សារបស់សិស្សលើសអាយុទាបជាងសិស្សរៀនត្រឹមត្រូវតាមអាយុ។

កិច្ចការបន្ទាប់គឺត្រូវបង្កើនសមត្ថភាពរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ។ សាលារៀនត្រូវការធាតុចូលដែលមានគុណភាពជាពិសេសសាលារៀននៅតំបន់ជនបទ។ តួនាទីរបស់មាតាបិតានិងសហគមន៍ក្នុងការគ្រប់គ្រងសាលារៀនត្រូវតែពង្រឹង ដើម្បីដោះស្រាយបញ្ហាឆ្លងផ្នែក និងបញ្ហាសង្គមសេដ្ឋកិច្ចនៅកម្រិតសហគមន៍ និងគ្រួសារ។ ការបំពេញការងាររបស់គ្រូបង្រៀនត្រូវធ្វើការពិនិត្យតាមដាននិងវាយតម្លៃជាទៀងទាត់។ នៅ

តំបន់ជនបទនៅខ្វះគ្រូបង្រៀនដែលមានបទពិសោធ។ នាយកសាលារៀនត្រូវការបំប៉នបន្ថែមអំពីជំនាញគ្រប់គ្រងនិងដឹកនាំ។ សុក្រឹតភាពរបស់ទិន្នន័យទាមទារឱ្យមានការខិតខំបន្ថែមទៀត និងសុខដុមនីយកម្មរវាងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំជាមួយនឹងប្រព័ន្ធធានាគុណភាពអប់រំ។

ការអប់រំបឋមសិក្សាត្រូវបានចាត់ទុកជាអាទិភាពមួយ និងទទួលបាននូវចំណែកថវិកាច្រើនជាងគេក្នុងថវិកាសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការផ្តល់ហិរញ្ញប្បទានសម្រាប់បឋមសិក្សាគួរត្រូវបន្តជាអាទិភាពតទៅទៀត និងត្រូវបង្ហាញច្បាស់អំពីទំនាក់ទំនងរវាងធនធាននិងលទ្ធផល។

ដៃគូអភិវឌ្ឍជាច្រើនបានបន្តផ្តល់ការគាំទ្រជាហិរញ្ញវត្ថុ និងបច្ចេកទេសសម្រាប់អនុវិស័យនេះ ដូចជា មូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំ ការគាំទ្ររបស់ប្រទេសស៊ុយអែតក្នុងការផ្តល់ថវិកាកែលម្អសាលារៀន និងសហភាពអឺរ៉ុបផ្តល់ជាថវិកាគាំទ្រដែលមានលទ្ធភាពក្នុងការបង្កើនថវិកាដំណើរការសាលារៀនតាមរយៈថវិកាកម្មវិធី។ ថវិកាភាពជាដៃគូសម្រាប់ការអភិវឌ្ឍសមត្ថភាពបានផ្តល់លទ្ធភាពក្នុងការអភិវឌ្ឍសមត្ថភាពនៅគ្រប់កម្រិត។ កម្មវិធីស្បៀងអាហារពិភពលោកនឹងបន្តផ្តល់អាហារតាមសាលារៀន។ ដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាលបានអនុវត្តនូវកម្មវិធីផ្តួចផ្តើមមួយចំនួនដែលនឹងផ្តល់ជាធាតុចូលសម្រាប់ការពិភាក្សាកម្រិតគោលនយោបាយ និងការពង្រីកវិសាលភាពផងដែរ។

### ៣.២.២ វត្ថុបំណងគោលនយោបាយ

- ធានាប្រមូលកុមារដល់វ័យនិងក្នុងវ័យសិក្សាឱ្យចូលរៀននិងរៀនបានចប់ឆ្នាំសិក្សានិងភូមិសិក្សា
- ធានាកុមារទាំងអស់ទទួលបានចំណេះដឹង បំណិន សុខភាពពេញលេញ និងសីលធម៌ស្របតាមស្តង់ដារដែលបានកំណត់
- ធានាដំណើរការពេញលេញនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល។

### ៣.២.៣ សកម្មភាពគោលនយោបាយ

- ធ្វើវិសោធនកម្មអនុក្រឹត្យ ស្តីពីការផ្តល់អាហារូបករណ៍សម្រាប់បឋមសិក្សា នៅឆ្នាំ ២០១៤
- កែសម្រួលលិខិតបទដ្ឋានគតិយុត្តិ ស្តីពីការប្រើប្រាស់ថវិកាដំណើរការសាលារៀន នៅឆ្នាំ ២០១៤
- រៀបចំលក្ខន្តិកៈ ស្តីពីការបង្កើតគ្រឹះស្ថានបឋមសិក្សាសាធារណៈនិងឯកជន នៅឆ្នាំ ២០១៥
- កែលម្អលិខិតបទដ្ឋានគតិយុត្តិ ស្តីពីការសាងសង់និងការបំពាក់សម្ភារបរិក្ខារគ្រឹះស្ថានសិក្សាឱ្យស្របតាមស្តង់ដារគុណភាពសាលាបឋមសិក្សា នៅឆ្នាំ ២០១៥
- រៀបចំលិខិតបទដ្ឋានណែនាំអនុវត្តកម្មវិធីអាហារូបត្ថម្ភនៅតាមសាលាបឋមសិក្សា នៅឆ្នាំ២០១៤
- កែសម្រួលផែនការគោលក្នុងការជួយកុមារពិការ ចាប់ពីឆ្នាំ ២០១៤
- កែលម្អកម្មវិធីសិក្សានៅបឋមសិក្សានៅឆ្នាំ ២០១៥

- រៀបចំសេចក្ដីណែនាំស្ដីពីការប្រើប្រាស់កម្រងសំណួរពាក់ព័ន្ធការសិក្សារបស់សិស្សនៅឆ្នាំ ២០១៤
- ធ្វើវិសោធនកម្ម និយាមប្រើប្រាស់បុគ្គលិកអប់រំនៅឆ្នាំ ២០១៤
- រៀបចំលិខិតបទដ្ឋានគតិយុត្តិស្ដីពី ការបង្រៀនភាសាបរទេសសម្រាប់បឋមសិក្សាចាប់ពីថ្នាក់ទី ៤ នៅឆ្នាំ ២០១៤
- រៀបចំក្របខណ្ឌធានាគុណភាពអប់រំកម្រិតសាលារៀន នៅឆ្នាំ ២០១៤
- សាកល្បងការបង្រៀននិងរៀនពេញមួយថ្ងៃចាប់ពីឆ្នាំ ២០១៤
- កែលម្អប្រព័ន្ធនិងកម្មវិធីបណ្ដុះបណ្ដាលនិងវិក្រឹតការគ្រូបឋមសិក្សា នៅឆ្នាំ ២០១៦
- រៀបចំផែនការសកម្មភាពអនុវត្តគោលនយោបាយគ្រូបង្រៀននៅឆ្នាំ២០១៥
- ផ្សព្វផ្សាយនិងអនុវត្តប្រព័ន្ធធានាគុណភាពការងារបណ្ដុះបណ្ដាលគ្រូបង្រៀននៅឆ្នាំ ២០១៤
- រៀបចំតួនាទី ភារកិច្ច និងផែនការសកម្មភាពរបស់គណៈកម្មការគ្រប់គ្រងសាលាកុមារមេត្រី នៅឆ្នាំ ២០១៤
- កែសម្រួលនិងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសុខភាពសិក្សា នៅឆ្នាំ ២០១៦
- សាកល្បងអនុវត្តប្រព័ន្ធវាយតម្លៃការបំពេញការងាររបស់បុគ្គលិកនៅឆ្នាំ ២០១៤ និងអនុវត្តជាផ្លូវការនៅឆ្នាំ ២០១៦
- រៀបចំប្រព័ន្ធត្រួតពិនិត្យតាមដានផ្អែកលើលទ្ធផលនៅឆ្នាំ ២០១៤
- រៀបចំផែនការគោលអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ស្របតាមគោលនយោបាយស្ដីពី បច្ចេកវិទ្យាសារគមនាគមន៍និងព័ត៌មានរបស់ក្រសួង នៅឆ្នាំ ២០១៤។

### ៣.២.៤ យុទ្ធសាស្ត្រ

- បង្កើនការប្រមូលកុមារចូលរៀននៅបឋមសិក្សា ជាពិសេសក្រុមកុមារបាត់បង់ឱកាស[1] តាមរយៈការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងអាហារូបត្ថម្ភនៅតាមសាលាបឋមសិក្សា
- បង្កើនលទ្ធភាពចូលរួមរបស់ផ្នែកឯកជន និងសហគមន៍លើផ្នែកអភិវឌ្ឍវិស័យអប់រំ នៅគ្រប់កម្រិតសិក្សា ជាពិសេស គណៈកម្មការនិងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ប្រភេទ
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត តាមរយៈ ការកាត់បន្ថយសាលាបឋមសិក្សាមិនគ្រប់កម្រិត បង្កើតសាលារៀនថ្មី និងផ្ដល់សម្ភាររូបវន្តបន្ថែម

[1] កុមារនៅតំបន់ជួបការលំបាក កុមារមានអាយុច្រើន កុមារមកពីគ្រួសារក្រីក្រ កុមារជនជាតិដើមភាគតិច កុមារពិការ និងកុមារចំណាកស្រុក

- ផ្តល់ធាតុចូលមានគុណភាពនិងគាំទ្របច្ចេកទេសដល់សាលារៀនស្របតាមស្តង់ដារ (គ្រូចេញពីសាលាគរុកោសល្យ សៀវភៅសិក្សាគោល សម្ភារៈបង្រៀននិងរៀន)
- កែលម្អកម្មវិធីសិក្សាសម្រាប់បឋមសិក្សា
- រៀបចំក្របខណ្ឌធានាគុណភាពសាលារៀន (ព័ត៌មាន ការដឹកនាំនិងគ្រប់គ្រង សម្ភារបរិក្ខារ ការបង្រៀននិងរៀន ការងារសុខភាពសិក្សា សម្ភាររៀននិងបង្រៀន ការគ្រប់គ្រងហិរញ្ញវត្ថុ ការអប់រំកាយនិងកីឡា ការចូលរួមរបស់មាតាបិតានិងសហគមន៍)
- អភិវឌ្ឍប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន តាមរយៈការរៀបចំស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន បញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ ៩ បូក ២ និងបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់ក្របខ័ណ្ឌ រដ្ឋ និងឯកជន
- ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបឋមសិក្សា
- កែលម្អការបំពេញការងារនិងការទទួលខុសត្រូវរបស់សាលារៀន គ្រូបង្រៀន និងសិស្ស តាមរយៈតាមដាននិងវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្ស និងផ្តល់ការគាំទ្របានទាន់ពេលវេលា
- បង្កើនគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ និងការទទួលខុសត្រូវរបស់គ្រឹះស្ថានសិក្សា ក្នុងការប្រើប្រាស់ថវិកា និងការសម្រេចចិត្តលើកម្មវិធីនានា
- ពង្រឹងភាពជាអ្នកដឹកនាំនិងគ្រប់គ្រងនៅកម្រិតសាលារៀន ដើម្បីធានាដំណើរការសាលារៀនប្រកបដោយវិជ្ជាជីវៈនិងការទទួលខុសត្រូវ
- ពង្រឹងការគ្រប់គ្រង ការកសាងផែនការ ការអនុវត្ត ការពិនិត្យតាមដាន និង ការធ្វើរបាយការណ៍ផ្អែកលើលទ្ធផល ស្របតាមគោលការណ៍អភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បង្កើនការប្រើប្រាស់សេវាសុខាភិបាលដើម្បីលើកកម្ពស់គ្រប់សេវាអប់រំសុខភាពនៅបឋមសិក្សា។

### ៣.២.៥ សូចនាករផលសម្រេច (សាធារណៈនិងឯកជន)

- ភាគរយសាលាកុមារមេត្រីកម្រិតមធ្យមនិងកម្រិតអភិវឌ្ឍកើនពី ៧២,៧១ ភាគរយ នៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ១០០ ភាគរយនៅឆ្នាំសិក្សា ២០១៧-២០១៨
- អត្រាពិតចូលរៀនថ្មីកើនពី ៩៤,៣ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ១០០ ភាគរយនៅឆ្នាំសិក្សា ២០១៧-២០១៨
- អត្រាពិតនៃការសិក្សាកើនពី ៩៧,០ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ១០០ ភាគរយនៅឆ្នាំសិក្សា ២០១៧-២០១៨

- អត្រាបោះបង់ការសិក្សាថយចុះពី ៣,៧ ភាគរយនៅឆ្នាំសិក្សា២០១១-២០១២ មកត្រឹម ១ ភាគរយ នៅឆ្នាំសិក្សា ២០១៦-២០១៧
- អត្រាត្រួតថ្នាក់ថយចុះពី ៥,៣ ភាគរយនៅឆ្នាំសិក្សា ២០១១-២០១២ មកត្រឹម ២ ភាគរយ នៅឆ្នាំសិក្សា ២០១៦-២០១៧
- អត្រាបញ្ចប់ការសិក្សាកើនពី ៨៧,៤ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ១០០ ភាគរយ នៅឆ្នាំសិក្សា ២០១៧-២០១៨
- ភាគរយកុមារចូលរៀនថ្នាក់ទី១ថ្មី បានឆ្លងកាត់មត្តេយ្យសិក្សាកើនពី ៨០ ភាគរយនៅឆ្នាំសិក្សា ២០១១-២០១២ ដល់ ១០០ ភាគរយ នៅឆ្នាំសិក្សា ២០១៧-២០១៨
- អត្រាឆ្លងភូមិសិក្សាទៅមធ្យមសិក្សាបឋមភូមិកើនពី ៧៨,៩ ភាគរយនៅឆ្នាំសិក្សា ២០១១-២០១២ ដល់ ១០០ ភាគរយ នៅឆ្នាំសិក្សា ២០១៧-២០១៨
- ភាគរយសាលាបឋមសិក្សាមានបង្គន់អនាម័យនិងទឹកស្អាត (៨៧ ភាគរយ) កន្លែងលាងសម្អាតដៃ (៦០ ភាគរយ) និងប្រអប់សង្គ្រោះបឋម (៧០ ភាគរយ) នៅឆ្នាំ ២០១៨។

### ៣.២.៦ កម្មវិធីនិងសកម្មភាព

- ***ការប្រមូលកុមារចូលរៀន*** ៖ តាមរយៈ ការផ្តល់ថវិកាដំណើរការសាលារៀន ការអនុវត្តផែនការកែលម្អសាលារៀន និងការផ្តល់អាហារូបករណ៍សម្រាប់កុមារក្រីក្រនិងអាហារពេលព្រឹក
    - **ផ្តល់ថវិកាដំណើរការសាលារៀន ៖** ថវិកាដំណើរការសាលាបឋមសិក្សា គណៈកម្មការកម្រង សាលាប្រជុំកសាងផែនការ ការបំប៉នគ្រូនិងអ្នកពាក់ព័ន្ធពីបច្ចេកទេសរៀននិងបង្រៀន ការពិនិត្យតាមដាននិងការប្រឡងប្រណាំងគ្រូល្អ សាលារៀនល្អ។
    - **ផែនការកែលម្អសាលារៀន** ៖ កែលម្អប្រព័ន្ធព័ត៌មានគ្រប់គ្រងសាលារៀន។ កែលម្អផែនការសាលារៀនដើម្បីឆ្លើយតបតាមស្តង់ដារគុណភាព។
    - **អាហារូបករណ៍សម្រាប់កុមារក្រីក្រ និងអាហារពេលព្រឹក** ៖ ផ្តល់អាហារូបករណ៍ជាថវិកានិងស្បៀងអាហារដល់កុមារក្រីក្រពីថ្នាក់ទី ៤ ដល់ទី ៦ និងផ្តល់អាហារពេលព្រឹកសម្រាប់សាលាបឋមសិក្សា។
- ***កម្មវិធីអភិវឌ្ឍសម្ភារៈបង្រៀននិងរៀន*** ៖ តាមរយៈ ការអភិវឌ្ឍកម្មវិធីសិក្សា ការផ្តល់សម្ភារៈបង្រៀននិងរៀន
    - ***ការអភិវឌ្ឍកម្មវិធីសិក្សា*** ៖ ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ស្តង់ដារកម្មវិធីសិក្សាតាមមុខវិជ្ជា។ កសាងឯកសារ ផ្សព្វផ្សាយ ណែនាំការអនុវត្តកម្មវិធីសិក្សា និងពិនិត្យតាមដាន

វាយតម្លៃ។ អភិវឌ្ឍសម្ភារឧបទេសសម្រាប់ការរៀននិងបង្រៀន។ អភិវឌ្ឍសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជា បោះពុម្ព និងចែកចាយដល់សាលារៀនចំណេះទូទៅ។

- ***ការផ្តល់សម្ភារៈបង្រៀននិងរៀន*** ៖ ផ្តល់សៀវភៅសិក្សា សៀវភៅសម្រាប់គ្រូនៅតំបន់ជួបការលំបាក សម្ភារឧបទេ្ទស និងរៀបចំបន្ទប់រៀនមានស្តង់ដាដូចបានកំណត់ក្នុងបរិស្ថានរួបរន្តសាលាកុមារមេត្រី។

- ***កម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន*** ៖ តាមរយៈ ការបណ្តុះបណ្តាលគ្រូចេញថ្មីប្រកបដោយគុណភាព វិក្រឹតការគ្រូបង្រៀន ការពង្រាយគ្រូទៅតំបន់ជួបការលំបាក និងការអនុវត្តម្មវិធីណែនាំដល់គ្រូចេញថ្មី
    - **ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន** ៖ ផ្តល់ថវិកាដំណើរការសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត រៀបចំកម្មវិធីអភិវឌ្ឍបុគ្គលិកនៅសាលាគរុកោសល្យ បង្កើនសមត្ថភាពគ្រូបឋមសិក្សាឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន បំប៉នសមត្ថភាពស្តីពីការប្រើប្រាស់កម្មវិធីសិក្សា ស្តង់ដារកម្មវិធីសិក្សា ការអប់រំកាយនិងកីឡា និងអប់រំបញ្ចូលគ្នា បំប៉នសមត្ថភាពស្តីពីការបញ្ច្រាបយេនឌ័រដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ អភិវឌ្ឍកម្មវិធី និងខ្លឹមសារឯកសារបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបឋមសិក្សា។ បណ្តុះបណ្តាលនិងផ្គត់ផ្គង់គ្រូបឋមសិក្សាចន្លោះពី ២០០០ ទៅ ២៥០០ នាក់ក្នុងមួយឆ្នាំសិក្សា។
    - ***ការផ្គត់ផ្គង់និងតម្រូវការគ្រូបង្រៀន*** ៖ ជំរុញលើកទឹកចិត្តគ្រូល្អឱ្យទៅបង្រៀននៅតំបន់ជួបការលំបាក។ ដំណើរការរៀនពេញមួយថ្ងៃនៅតាមសាលារៀនជ្រើសរើសមួយចំនួន។ បង្កើតកន្លែងស្នាក់នៅសម្រាប់គ្រូនៅបឋមសិក្សានៅតំបន់ជួបការលំបាក។
    - ពង្រឹងការអនុវត្តស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ស្តង់ដារសាលាគរុកោសល្យ និងប្រព័ន្ធធានាគុណភាពបណ្តុះបណ្តាលគ្រូបង្រៀន
    - ***កម្មវិធីណែនាំដល់គ្រូចេញថ្មី*** ៖ កម្មវិធីណែនាំត្រូវបានបង្កើតឡើងនៅបឋមសិក្សា។

- ***កម្មវិធីកែលម្អគុណភាព*** ៖ តាមរយៈ ការអភិវឌ្ឍកម្មវិធីអាន សរសេរភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ដំបូង ការបង្រៀនភាសាបរទេសចាប់ពីថ្នាក់ទី ៤ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងការអនុវត្តតេស្តវាយតម្លៃថ្នាក់ជាតិ
    - **ការអភិវឌ្ឍកម្មវិធីអាន សរសេរភាសាខ្មែរនិងគណិតវិទ្យាថ្នាក់ដំបូង** ៖ កសាងឯកសារការបំប៉នគ្រូនិងអ្នកពាក់ព័ន្ធអំពីការប្រើប្រាស់សៀវភៅ បោះពុម្ព ធ្វើតេស្តសមត្ថភាពសិស្ស ពិនិត្យតាមដាន និងធ្វើបច្ចុប្បន្នភាព។

- ○ **ការបង្រៀនភាសាបរទេសចាប់ពីថ្នាក់ទី ៤** ៖ កសាងឯកសារនិងវិធីសាស្ត្រ ពង្រឹងសមត្ថភាពគ្រូលើភាសាបរទេសនិងព័ត៌មានវិទ្យា។ ជំរុញការអនុវត្តកម្មវិធីភាសាអន្តរជាតិដើម្បីធ្វើសមាហរណកម្មតំបន់និងពិភពលោក។
- ○ **ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស** ៖ បំប៉នក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ នាយកសាលា និងគ្រូបង្រៀនអំពីរបៀបកសាងនិងប្រើប្រាស់ឧបករណ៍សម្រាប់អនុវត្តវាយតម្លៃនិងសម្ភាសន៍ និងរៀបចំរបាយការណ៍។ ផ្តល់រង្វាន់លើកទឹកចិត្តសិស្សពូកែនៅបឋមសិក្សា។
- ○ **ការលើកកម្ពស់តេស្តវាយតម្លៃថ្នាក់ជាតិ** ៖ ពិនិត្យឡើងវិញកម្រងសំណួរតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី ៣ និងទី ៦ មុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា និងបញ្ចូលភាសាអង់គ្លេសថ្នាក់ទី ៦។

• *កម្មវិធីអប់រំពិសេសនៅបឋមសិក្សា* ៖ តាមរយៈការអនុវត្តថ្នាក់ពន្លឿនការសិក្សា ថ្នាក់គួប ការអប់រំពីរភាសា

- ○ **ថ្នាក់ពន្លឿនការសិក្សា** ៖ អនុវត្តថ្នាក់ពន្លឿនការសិក្សា និងបណ្តុះបណ្តាលគ្រូ។
- ○ **ថ្នាក់គួប** ៖ អនុវត្តថ្នាក់គួបនិងបណ្តុះបណ្តាលគ្រូ។
- ○ **ការអប់រំពីរភាសា** ៖ អនុវត្តការអប់រំពីរភាសា តាមរយៈការបំប៉នសមត្ថភាពគ្រូ ដើម្បីជាស្ពាន។ ប្រែក្លាយសាលាសហគមន៍ឱ្យទៅជាសាលាសាធារណៈ។
- ○ **ការគាំទ្រដល់សិស្សដែលមានបញ្ហាមើលនិងស្តាប់** ៖ គាំទ្រដល់កុមារពិការ បំប៉នអំពីរបៀបធ្វើតេស្ត ធ្វើតេស្តកុមារដែលមានបញ្ហាភ្នែក និងផ្តល់វ៉ែនតា។ ផ្តល់ឧបករណ៍ស្តាប់ដល់កុមារដែលមានបញ្ហាស្តាប់ និងពិនិត្យតាមដាន។

• *កម្មវិធីអប់រំអនាម័យនិងបរិស្ថាន* ៖ តាមរយៈការរៀបចំសាលារៀនសុវត្ថិភាព ការអប់រំសុខភាព ការត្រួតពិនិត្យសុខភាពរបស់កុមារ និងការបំពាក់សម្ភារៈអនាម័យនៅតាមសាលារៀន

- ○ **សាលារៀនសុវត្ថិភាព** ៖ បំប៉នក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ គ្រូបង្រៀន សហគមន៍ និងអ្នកពាក់ព័ន្ធ អំពីការបង្ការគ្រោះថ្នាក់ផ្សេងៗ គ្រោះថ្នាក់ដោយធម្មជាតិ និងដោយសារគ្រាប់សំណល់ពីសង្គ្រាម។
- ○ **ត្រួតពិនិត្យមើលសុខភាពរបស់កុមារមុនចាប់ផ្តើមចូលរៀន** ៖ ពិនិត្យសុខភាពនិងកាយសម្បទាកុមារថ្នាក់ទី ១ នៅពេលចាប់ផ្តើមឆ្នាំសិក្សាដំបូង។ ចាក់ថ្នាំវាក់សាំង ថ្នាំបង្ការ ផ្តល់វីតាមីន ផ្តល់ថ្នាំទម្លាក់ព្រូនពីរដងក្នុងមួយឆ្នាំដល់បុគ្គលិកអប់រំ និងអ្នកសិក្សា។

- **ការអប់រំសុខភាព** ៖ ផ្តល់ការអប់រំអំពីសុខភាពបន្តពូជ សុខភាពផ្លូវភេទ រួមបញ្ចូលទាំងការអប់រំ បង្ការជំងឺអេដស៍ គ្រឿងញៀន ការអប់រំសុខភាពអនាម័យ សុវត្ថិភាពចំណីអាហារ អាហារូបត្ថម្ភ វិធីសាស្ត្រសង្គ្រោះបឋម គ្រឿងស្រវឹង បារី សុខភាពភ្នែក សុខភាពមាត់ធ្មេញ ព្រមទាំងការអប់រំបង្ការជំងឺមិនឆ្លងនិងជំងឺឆ្លងនានាដូចជាគ្រុនចាញ់ គ្រុនឈាម ដង្កូវព្រូនជាដើម។
- **ការបំពាក់សម្ភារូបវន្តផ្នែកអនាម័យតាមសាលារៀន** ៖ ផ្គត់ផ្គង់ទឹកស្អាត បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ ផ្តល់ប្រអប់សង្គ្រោះបឋមនិងសម្ភារៈបម្រុង គ្រប់គ្រងកាកសំណល់រឹងរាវ និងរៀបចំនិងរក្សាទុកព័ត៌មានសុខភាពរបស់សិស្សនៅគ្រប់ភូមិសិក្សា
- **ការអប់រំអំពីសង្គមនិងបរិស្ថាន** ៖ បំប៉នគ្រូបង្រៀន សិស្ស និងអ្នកពាក់ព័ន្ធអំពីវិធានការបង្ការទប់ស្កាត់ គ្រោះមហន្តរាយ គ្រោះថ្នាក់ផ្សេងៗ បម្រែបម្រួលអាកាសធាតុ ការដាំដើមឈើឡើងវិញ និងការថែរក្សាបរិស្ថាន។
- **ការអភិវឌ្ឍកម្មវិធីបំណិនជីវិត** ៖ បំប៉នគ្រូនិងសិស្សអំពីវិធានការចម្រុះថៃទាំដំណាំ ចុះអនុវត្តកម្មវិធី និងវាយតម្លៃ។ បំប៉ននាយកសាលានិងគ្រូបង្រៀនអំពីបន្លែសរីរាង្គ បរិស្ថាន សិល្ប: គំនូរ គេហកិច្ច និងរោងជាង។

- ***កម្មវិធីអភិវឌ្ឍសមត្ថភាពនិងការគាំទ្រ*** ៖ តាមរយៈ ការគាំទ្រដល់ក្រុង ស្រុក ខណ្ឌ ការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសបង្គោល ការអភិវឌ្ឍបណ្ណាល័យ កម្រងសាលារៀន ការរៀបចំផែនទីសិក្សា និងផែនទីខ្នងផ្ទះ និង ការផ្ទេរមុខងារដល់ថ្នាក់ក្រោមជាតិ
    - **កម្មវិធីគាំទ្រក្រុង ស្រុក ខណ្ឌដែលបំពេញការងារនៅទាបជាងចំណុចដៅ៖** ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌចុះពិនិត្យមើលសាលារៀនបំពេញការងារមិនទាន់បានល្អ។ ជំរុញលើកទឹកចិត្តសហគមន៍ឱ្យចូលរួមក្នុងការអភិវឌ្ឍ និងការបំពេញការងាររបស់សាលារៀនទៅតាមស្តង់ដារសាលាកុមារមេត្រី។ គាំទ្រដល់ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំការបំប៉នសមត្ថភាពគ្រូនៅពេលវិស្សមកាល និងតាមរយៈការប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍។
    - **ការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសបង្គោល** ៖ ធ្វើបច្ចុប្បន្នកម្មកម្មវិធីបណ្តុះបណ្តាល បំពាក់សម្ភារៈក្នុងបណ្ណាល័យ បច្ចុប្បន្នកម្មកម្មវិធីចុះកម្មសិក្សា។
    - **ការអភិវឌ្ឍបណ្ណាល័យ** ៖ រៀបចំបណ្ណាល័យនិងដាក់ឱ្យដំណើរការពេញលេញ។ បំប៉នបណ្ណារក្ស នាយកសាលា ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ រៀបចំទស្សនកិច្ចសិក្សានិងការប្រជុំប្រចាំឆ្នាំ។

- **ការពង្រឹងកម្រងសាលារៀន** ៖ បណ្តុះបណ្តាលក្រុមប្រឹក្សានិងគណៈកម្មការកម្រងសាលារៀន។ ផ្លាស់ប្តូរទស្សនកិច្ចសិក្សានិងការពិនិត្យតាមដាន។ រៀបចំសេចក្តីណែនាំនិងគោលការណ៍ស្តីពីកម្រងសាលារៀន។ ប្រជុំភាពជាដៃគូរវាងឪពុកម្តាយនិងគ្រូបង្រៀន ។
- **ការកសាងផែនទីសិក្សានិងផែនទីខ្នងផ្ទះ** ៖ បំប៉នសមត្ថភាពអ្នកប្រមូលទិន្នន័យចុះប្រមូលទិន្នន័យកុមារ ដើម្បីធ្វើបច្ចុប្បន្នភាពផែនទីខ្នងផ្ទះ។
- **អភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសនៅសាលាគរុកោសល្យនិងគ្រូបឋមសិក្សា** អំពីបច្ចេកទេសបង្រៀន ការបញ្ជ្រាបចំណេះដឹងយេនឌ័រ និងការអប់រំបញ្ចូលគ្នា។
- **លើកកម្ពស់ចំណេះដឹងដល់គ្រូបឋមសិក្សា** ឱ្យបានសមស្របតាមស្តង់ដារបណ្តុះបណ្តាលគ្រូ ជាពិសេសគ្រូបឋមសិក្សាដែលគ្មានសញ្ញាបត្រទុតិយភូមិ។
- អភិវឌ្ឍសមត្ថភាពគ្រប់គ្រងនិងដឹកនាំដល់នាយកសាលាបឋមសិក្សា។
- **ការផ្ទេរមុខងារដល់ថ្នាក់ក្រោមជាតិ** ៖ ពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ ការរៀបចំឯកសារស្តីពីនីតិវិធីនៃការស្នើឬការតវ៉ា នីតិវិធីនៃដំណោះស្រាយ លិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យអប់រំ ឯកសារស្តីពីក្របខណ្ឌច្បាប់ការការពារនិងប្រឆាំងការជួញដូរនិងការរត់ពន្ធមនុស្ស។ សិក្សាមុខងារ ការស្ទាបស្ទង់មតិ ប្រមូលព័ត៌មាន ផ្សព្វផ្សាយ និងរៀបចំការផ្ទេរមុខងារដល់ថ្នាក់ក្រោមជាតិ។ ពង្រឹងសមត្ថភាពក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការ ដើម្បីអនុវត្តនីតិវិធីនិងក្របខណ្ឌច្បាប់នានា។
- **ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ** ៖ អភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំតាមរយៈការបំពាក់បរិក្ខារ ការបណ្តុះបណ្តាល ការធ្វើវិមជ្ឈការដល់រាជធានី ខេត្ត និងប្រមូលទិន្នន័យពាក់ព័ន្ធពីគ្រប់ស្ថាប័នពាក់ព័ន្ធ។

- ***កម្មវិធីគាំទ្រអនុវិស័យបឋមសិក្សា*** ៖ តាមរយៈ ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ប្រសិទ្ធភាពការគ្រប់គ្រងរដ្ឋបាលអប់រំ និងការពង្រឹងតួនាទីនិងភារកិច្ចរបស់គណៈកម្មការទ្រទ្រង់សាលារៀន
  - **ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ** ៖ ជំរុញការធ្វើប្លង់កម្មសិទ្ធិរបស់អង្គភាពការអភិវឌ្ឍសមត្ថភាពនិងដំណើរការអង្គភាព។ ផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌ ទិន្នន័យអចលនទ្រព្យ និងពិនិត្យតាមដានការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅតាមគ្រឹះស្ថានសិក្សា។
  - **ការអភិវឌ្ឍនិងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងរដ្ឋបាលអប់រំ** ៖ ពង្រឹងសមត្ថភាពការងារគ្រប់គ្រងរដ្ឋបាល របាយការណ៍ និងការងារប្រឡងប្រណាំង។ រៀបចំសេវាផ្តល់និង

ទទួលព័ត៌មានក្នុងផ្នែករដ្ឋបាលនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន។ រៀបចំទិន្នន័យសម្រាប់តម្កល់ឯកសាររដ្ឋបាល និងឯកសារពាក់ព័ន្ធ។

- **ជំរុញការអនុវត្តតួនាទីនិងភារកិច្ចរបស់គណៈកម្មការទ្រទ្រង់សាលារៀន** ៖ ផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការបង្កើតនិងដំណើរការគណៈកម្មការទ្រទ្រង់សាលារៀន ឱ្យបានស៊ីជម្រៅ។ ពង្រឹងសមត្ថភាពគណៈកម្មការទ្រទ្រង់សាលារៀនលើការងារគ្រប់គ្រងរដ្ឋបាល របាយការណ៍ និងទំនាក់ទំនង។
- **ការអភិវឌ្ឍក្របខណ្ឌច្បាប់ លិខិតបទដ្ឋាន ពង្រឹងអភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ៖ ធ្វើទំនើបកម្មច្បាប់និងគោលនយោបាយផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈវិស័យអប់រំ ប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្សនិងពលកម្មកុមារ ការលើកកម្ពស់យេនឌ័រ ជំរុញការអនុវត្តយន្តការប្រឆាំងអំពើពុករលួយ ពង្រឹងសមត្ថភាពដោះស្រាយនិងទប់ស្កាត់វិវាទក្នុងវិស័យអប់រំ ។

• ***កម្មវិធីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបឋមសិក្សា*** ៖ តាមរយៈ ការសាងសង់សាលារៀនគ្រប់កម្រិតការអភិវឌ្ឍមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូ

- **ការសាងសង់សាលាបឋមសិក្សាគ្រប់កម្រិត** ៖ ស្រាវជ្រាវពីតម្រូវការច្បាស់លាស់ផ្នែកសេវាអប់រំក្នុងបណ្តាខេត្តដែលបានជ្រើសរើស សាងសង់សាលាបឋមសិក្សាថ្មីបន្ថែមឱ្យគ្រប់កម្រិត និងពង្រាយគ្រូទៅតំបន់ជួបការលំបាកនិងដាច់ស្រយាល និងសាលាមិនគ្រប់កម្រិត។
- **ការអភិវឌ្ឍមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូ** ៖ កសាងនិងជួសជុល បរិស្ថានអគារសិក្សាអន្តេវាសិកដ្ឋាន បន្ទប់ទឹក បន្ទប់ពិសោធ និងបំពាក់សម្ភារៈ។

## ៣.៣ អនុវិស័យ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស

### ៣.៣.១ សាវតារ

អំឡុងឆ្នាំ ២០០៩-២០១៣ សកម្មភាពគោលនយោបាយមួយចំនួនត្រូវបានរៀបចំដូចជា ផែនការគោលស្តីពីការអភិវឌ្ឍមធ្យមសិក្សា និងសៀវភៅប្រតិបត្តិសម្រាប់សាលាមធ្យមសិក្សាធនធាន គោលនយោបាយស្តីពីសាលាកុមារមេត្រីនៅមធ្យមសិក្សា និងការកែលម្អកម្មវិធីសិក្សា។ ប្រព័ន្ធវិក្រឹតការគ្រូបង្រៀនលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រត្រូវបានរៀបចំ។ កម្មវិធីបំណិនជីវិត បច្ចេកវិទ្យា ព័ត៌មាន និងទេសចរណ៍ត្រូវបានអនុម័ត និងស្តង់ដារបណ្ណាល័យនៅមធ្យមសិក្សាកំពុងរៀបចំជាសេចក្តីព្រាង។

ការចូលរៀននិងគុណភាពនៅកម្រិតនេះមានការប្រែប្រួលតិចតួច។ អត្រាត្រួតថ្នាក់បានថយចុះតិចតួច ប៉ុន្តែអត្រាបោះបង់ការសិក្សាមិនមានប្រែប្រួលទេ។ សិស្សភាគច្រើនបានជ្រើសរើសយកបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រនៅថ្នាក់ទី ១១ និងថ្នាកទី ១២។ ទោះយ៉ាងណាក៏ដោយ គុណភាពនៅកម្រិតនេះមិនទាន់អាចវាស់វែងបាននៅឡើយ ដោយសារពុំទាន់បានធ្វើតេស្តវាយតម្លៃថ្នាក់ជាតិនៅថ្នាក់ទី ១២ ។ អាហារូបករណ៍បានផ្តល់ជារៀងរាល់ឆ្នាំ។ សិស្សបានទទួលមេដាយលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រពីកម្មវិធីប្រកួតស៊ីមេអូឡាំព្យាដ និងកម្មវិធីប្រកួតអន្តរជាតិផ្សេងៗទៀត។

ប្រព័ន្ធវាយតម្លៃថ្នាក់ជាតិត្រូវបានដាក់ឱ្យអនុវត្តនិងមានថវិកាសម្រាប់ដំណើរការ។ ការប្រឡងថ្នាក់ជាតិនៅថ្នាក់ទី ៩ និងទី ១២ ត្រូវបានអនុវត្តជាទៀងទាត់។

ចំនួនអនុវិទ្យាល័យ និងវិទ្យាល័យបានកើនឡើង។ សាលាមធ្យមសិក្សាបឋមភូមិ ៥០ ភាគរយបានអភិវឌ្ឍទៅជាសាលាមធ្យមសិក្សាទុតិយភូមិ។ អគារធនធាននៅមធ្យមសិក្សាត្រូវបានកសាងនៅគ្រប់រាជធានី ខេត្ត។ សាលាមធ្យមសិក្សាបឋមភូមិចំនួន ១៩១ ក្នុងខេត្ត ៨ មានបន្ទប់កុំព្យូទ័រ។ ប្រព័ន្ធនៃការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន ជាពិសេសគ្រូបង្រៀនកម្រិតអប់រំមូលដ្ឋាននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានជាតិអប់រំកំពុងត្រូវបានពង្រីក។ ការងារវិក្រឹតការលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រ ក៏កំពុងពង្រីកផងដែរ។ នាយកសាលាមធ្យមសិក្សាទុតិយភូមិទាំងអស់ និងនាយកសាលាមធ្យមសិក្សាបឋមភូមិមួយចំនួនបានទទួលការបំប៉នស្តីពីការគ្រប់គ្រងនិងដឹកនាំ។ ប្រធានក្រុមបច្ចេកទេសនៃសាលាមធ្យមសិក្សាធនធាន និងបណ្ណាញទាំងអស់បានទទួលការបំប៉ន ស្តីពីស្តង់ដារកម្មវិធីសិក្សា។ គោលនយោបាយសាលាកុមារមេត្រីត្រូវបានអនុវត្តនៅសាលាចំនួន ៨២៣ (៥០,៧ ភាគរយនៃសាលាមធ្យមសិក្សាបឋមភូមិ)។ សាលាមធ្យមសិក្សាបឋមភូមិ ៨៤,៤ ភាគរយមានបង្គន់អនាម័យ ៥២,៩ ភាគរយមានទឹកស្អាតប្រើប្រាស់ និងសាលាមធ្យមសិក្សាទុតិយភូមិ ៩៧,៧ ភាគរយ មានបង្គន់អនាម័យ ៦៤,៤ ភាគរយមានទឹកស្អាតប្រើប្រាស់។

បញ្ហាប្រឈមសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ នៅពេលបន្ទាប់គឺ ការបង្កើនសមធម៌ក្នុងការចូលរៀននៅមធ្យមសិក្សា តាមរយៈបង្កើនចំនួនសាលាមធ្យមសិក្សាបឋមភូមិឱ្យបានគ្រប់ឃុំ សង្កាត់ និងវិទ្យាល័យនៅគ្រប់ស្រុក ខណ្ឌ។ គុណភាពរបស់សិស្សបញ្ចប់ថ្នាក់ទី ១២ ត្រូវលើកកម្ពស់ និងផ្តល់នូវ

ចំណេះដឹងពាក់ព័ន្ធដទៃទៀត សម្រាប់ការអប់រំបច្ចេកទេសវិជ្ជាជីវៈ និងឧត្តមសិក្សា។ សាលាមធ្យមសិក្សាភាគច្រើន ជាពិសេសនៅតំបន់ជនបទខ្វះខាតធាតុចូលដែលមានគុណភាពដូចជា គ្រូបង្រៀនតាមមុខវិជ្ជា សម្ភារៈបង្រៀននិងគ្រឿងបរិក្ខារ សៀវភៅសិក្សាគោល បន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ និងភាសា និងបរិក្ខារបណ្ណាល័យ។ វិធីសាស្ត្រក្នុងការបង្រៀនក្នុងពេលបច្ចុប្បន្នអនុវត្តតាមរបៀបជាមេរៀន ចម្លងតាម ដកស្រង់ និងការចងចាំ។ វិធីសាស្ត្រទាំងនេះគួរត្រូវបញ្ចូលនូវការគិត និងជំនាញវិភាគ។ ស្តង់ដារគ្រូបង្រៀនគួរត្រូវពិនិត្យតាមដាន វាយតម្លៃ និងអភិវឌ្ឍជាប្រចាំ។

ការអប់រំបច្ចេកទេសជាមុខងារថ្មីមួយក្នុងក្រសួង និងទើបតែបានអនុម័តគោលនយោបាយស្តីពីការអប់រំបច្ចេកទេស។ ក្នុងគោលនយោបាយនេះបានលើកឡើងពី ការបង្កើតវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសនៅគ្រប់រាជធានី ខេត្ត។ នាពេលបច្ចុប្បន្ន សាលាមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេស ចំនួន ៣ កំពុងដំណើរការ និងផ្តល់នូវមុខវិជ្ជាសំខាន់បួន។ សិស្សដែលបញ្ចប់ការសិក្សានៅសាលាទាំងនេះ អាចរកការងារបាន។

កម្មវិធីអប់រំបច្ចេកទេស ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន មានកង្វះខាតទាំងក្របខណ្ឌគុណភាពដ៏រឹងមាំ និងធាតុចូលដែលមានគុណភាព។ ប្រព័ន្ធទទួលស្គាល់និងប្រព័ន្ធធានាគុណភាពសាលារៀនមិនទាន់បានបង្កើត ព្រមទាំងទំនាក់ទំនងរវាងប្រព័ន្ធអប់រំ និងទីផ្សារការងារនៅមានកម្រិត។ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុសាលារៀនមិនទាន់បង្កើត។ ការងារអប់រំបច្ចេកទេសត្រូវដកបទពិសោធពីប្រទេសដទៃ។ ដៃគូអភិវឌ្ឍជាច្រើនបានចាប់អារម្មណ៍គាំទ្រដល់កម្មវិធីនេះ។

### ៣.៣.២ វត្ថុបំណងគោលនយោបាយ

- ធានាសមធម៌ និងពង្រីកការចូលរៀននៅសាលាមធ្យមសិក្សាចំណេះទូទៅ ស្របតាមស្តង់ដារគុណភាព ព្រមទាំងនៅនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស និងបំផុសសកម្មភាពអប់រំកាយ និងកីឡា រួមទាំងការលើកកម្ពស់សុខភាពសិក្សា
- ធានាសិស្សបញ្ចប់ការសិក្សានៅមធ្យមសិក្សាចំណេះទូទៅ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសទទួលបានជំនាញត្រឹមត្រូវ និងអាចចូលបម្រើការងារ ឬបន្តការសិក្សានៅផ្នែកអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា
- ធានាប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលនៅមធ្យមសិក្សាចំណេះទូទៅ និងមធ្យមសិក្សាបច្ចេកទេសបានដំណើរការពេញលេញ។

### ៣.៣.៣ សកម្មភាពគោលនយោបាយ

- កសាងគោលនយោបាយជាតិស្តីពី អាហារូបករណ៍ ឧបត្ថម្ភធន និងឥណទានអ្នកសិក្សា នៅឆ្នាំ ២០១៤

- រៀបចំអនុក្រឹត្យស្តីពី ការបង្កើនប្រាក់លើកទឹកចិត្តដល់គ្រូបម្រើការនៅតំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល នៅឆ្នាំ ២០១៤
- កែសម្រួលសេចក្តីណែនាំស្តីពី ការប្រឡងថ្នាក់ជាតិ នៅឆ្នាំ ២០១៥
- រៀបចំក្របខណ្ឌគោលនយោបាយនិងសេចក្តីណែនាំ ស្តីពីកម្មវិធីសាលាកុមារមេត្រីនៅមធ្យមសិក្សា នៅឆ្នាំ ២០១៤
- ធ្វើបច្ចុប្បន្នភាពគោលនយោបាយកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាចំណេះទូទៅ នៅឆ្នាំ ២០១៨
- រៀបចំស្តង់ដារផ្គត់ផ្គង់សម្ភារៈបរិក្ខារបម្រើដល់រដ្ឋបាលសាលារៀន នៅឆ្នាំ ២០១៤
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយគ្រូបង្រៀន នៅឆ្នាំ ២០១៥
- រៀបចំប្រព័ន្ធធានាគុណភាពសាលារៀន នៅឆ្នាំ ២០១៦
- រៀបចំប្រព័ន្ធកសាងផែនការ ពិនិត្យតាមដាន និងវាយតម្លៃ ផ្អែកលើលទ្ធផលនៅមធ្យមសិក្សា នៅឆ្នាំ ២០១៤
- រៀបចំផែនការគោលសម្រាប់អភិវឌ្ឍការអប់រំបច្ចេកទេស នៅឆ្នាំ ២០១៤
- រៀបចំកម្មវិធីសិក្សា និងស្តង់ដារកម្មវិធីសិក្សាអប់រំបច្ចេកទេសស្របតាមតម្រូវការរបស់សហគមន៍ នៅឆ្នាំ ២០១៦
- កែលម្អប្រព័ន្ធនិងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សានៅឆ្នាំ ២០១៧
- អនុវត្តប្រព័ន្ធធានាគុណភាពការងារបណ្តុះបណ្តាលគ្រូបង្រៀន នៅឆ្នាំ ២០១៤
- រៀបចំក្របខណ្ឌគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស ដែលបង្រៀននៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស នៅឆ្នាំ ២០១៤
- រៀបចំលិខិតបទដ្ឋានស្តីពី ការគ្រប់គ្រងគ្រឹះស្ថានអប់រំមធ្យមសិក្សាឯកជន នៅឆ្នាំ ២០១៤
- រៀបចំសេចក្តីណែនាំស្តីពី ស្វ័យភាព និងការទទួលខុសត្រូវរបស់សាលាមធ្យមសិក្សានៅឆ្នាំ ២០១៤
- កែសម្រួល និងរៀបចំលិខិតបទដ្ឋានគតិយុទ្ធ ពាក់ព័ន្ធនឹងសុខភាពសិក្សា នៅឆ្នាំ ២០១៦
- រៀបចំគោលការណ៍អភិបាលកិច្ចល្អនៅសាលាមធ្យមសិក្សាចំណេះទូទៅ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស នៅឆ្នាំ ២០១៤
- ធ្វើបច្ចុប្បន្នភាពគោលនយោបាយបច្ចេកវិទ្យាសារគមនាគមន៍និងព័ត៌មានក្នុងវិស័យអប់រំ នៅឆ្នាំ ២០១៤

- ធ្វើបច្ចុប្បន្នភាពផែនការគោលសម្រាប់អនុវត្តបច្ចេកវិទ្យាសារគមនាគមន៍និងព័ត៌មានក្នុងវិស័យអប់រំ នៅឆ្នាំ ២០១៥។
- រៀបចំប្រកាសស្តីពី ការកែសម្រួលភារកិច្ច និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នៅឆ្នាំ២០១៤
- រៀបចំសេចក្តីណែនាំស្តីពី ការពង្រឹងការគ្រប់គ្រងនិងការអនុវត្តផ្នែកអប់រំបច្ចេកទេសនៅសាលាមធ្យមសិក្សា នៅឆ្នាំ២០១៥
- រៀបចំសេចក្តីណែនាំស្តីពី ការប្រឡងសិស្សផ្នែកអប់រំបច្ចេកទេស នៅឆ្នាំ២០១៤
- រៀបចំលិខិតបទដ្ឋាន និងយន្តការការងាររបស់ទីប្រឹក្សាអាជីពនៅតាមសាលារៀន នៅឆ្នាំ២០១៥
- រៀបចំស្តង់ដារវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស នៅឆ្នាំ ២០១៥
- រៀបចំលិខិបទដ្ឋានគតិយុត្តិនិងយន្តការស្តីពី ការពង្រីកវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសនៅឆ្នាំ២០១៥
- រៀបចំលិខិតបទដ្ឋានគតិយុត្តិ យន្តការ និងក្របខណ្ឌការងារ ដើម្បីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់សិស្សដែលបោះបង់ការសិក្សា នៅសាលាមធ្យមសិក្សា នៅឆ្នាំ២០១៥
- រៀបចំសេចក្តីណែនាំស្តីពី ការគ្រប់គ្រងផ្នែកលើលទ្ធផលនៅមធ្យមសិក្សាចំណេះទូទៅ និងមធ្យមសិក្សាបច្ចេកទេស នៅឆ្នាំ២០១៥។

## ៣.៣.៤ យុទ្ធសាស្ត្រ

- បង្កើនការចូលរៀននៅមធ្យមសិក្សា ជាពិសេសសិស្សស្រី ក្រុមបាត់បង់ឱកាស តាមរយៈ ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងអាហារូបត្ថម្ភដល់សិស្សមកពីគ្រួសារក្រីក្រ
- បង្កើនលទ្ធភាពចូលរួមរបស់ផ្នែកឯកជន និងសហគមន៍លើផ្នែកអភិវឌ្ឍវិស័យអប់រំ នៅមធ្យមសិក្សា ជាពិសេស គណៈកម្មការនិងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ប្រភេទ
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត តាមរយៈបង្កើតសាលារៀនថ្មីនិងពង្រីកកម្រិតសិក្សា ព្រមទាំងបំពាក់សម្ភារូបវន្ត (បណ្ណាល័យ បន្ទប់ពិសោធ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ ទីលានអប់រំកាយនិងកីឡា បង្គន់អនាម័យ ទឹកស្អាត កន្លែងលាងសម្អាតដៃ បន្ទប់សង្គ្រោះបឋម រោងជាងអន្តេវាសិកដ្ឋានសម្រាប់សិស្ស)
- ផ្តល់ធាតុចូលមានគុណភាពនិងគាំទ្របច្ចេកទេសដល់សាលារៀនស្របតាមស្តង់ដារ (គ្រូចេញពីសាលាគរុកោសល្យ សៀវភៅសិក្សាគោល សម្ភារៈបង្រៀននិងរៀន)

- ជំរុញការអនុវត្តគោលនយោបាយសាលាកុមារមេត្រីនៅមធ្យមសិក្សា និងការកាត់បន្ថយចំណាយក្រៅផ្លូវការ
- លើកកម្ពស់គុណភាពនៃការបង្រៀននិងរៀន (វិទ្យាសាស្ត្រ និងគណិតវិទ្យា បច្ចេកវិទ្យាសារគមនាគមន៍និងព័ត៌មាន ភាសាបរទេស ការអប់រំសុខភាព ការអប់រំបច្ចេកទេស ការអប់រំវិជ្ជាជីវៈជម្រើស និងការអប់រំបំណិនជីវិត)
- អភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ការអប់រំបច្ចេកទេស និងកែលម្អកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាចំណេះទូទៅ
- រៀបចំក្របខណ្ឌធានាគុណភាពសាលារៀន (ព័ត៌មាន ការដឹកនាំនិងគ្រប់គ្រង សម្ភារបរិក្ខារ ការបង្រៀននិងរៀន ការងារសុខភាពសិក្សា សម្ភារៈបង្រៀននិងរៀន ការគ្រប់គ្រងហិរញ្ញវត្ថុ ការអប់រំកាយនិងកីឡា ការចូលរួមរបស់មាតាបិតានិងសហគមន៍)
- អភិវឌ្ឍប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន តាមរយៈការរៀបចំស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន បណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់ក្របខ័ណ្ឌ រដ្ឋ និងឯកជន
- លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀននៅមធ្យមសិក្សា
- អភិវឌ្ឍផែនការសកម្មភាពសម្រាប់អភិវឌ្ឍសមត្ថភាពគ្រូមធ្យមសិក្សាតាមឆ្នាំនីមួយៗ
- កែលម្អការបំពេញការងារនិងការទទួលខុសត្រូវរបស់សាលារៀន គ្រូបង្រៀន និងសិស្ស តាមរយៈតាមដាននិងវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្ស និងផ្តល់ការគាំទ្របានទាន់ពេលវេលា
- បង្កើនគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈនិងការទទួលខុសត្រូវរបស់គ្រឹះស្ថានសិក្សា ក្នុងការប្រើប្រាស់ថវិកានិងការសម្រេចចិត្តលើកម្មវិធីនានា
- ពង្រឹងភាពជាអ្នកដឹកនាំនិងគ្រប់គ្រងនៅកម្រិតសាលារៀន ដើម្បីធានាដំណើរការសាលារៀនប្រកបដោយវិជ្ជាជីវៈនិងការទទួលខុសត្រូវ
- ពង្រឹងការគ្រប់គ្រង ការកសាងផែនការ ការអនុវត្ត ការពិនិត្យតាមដាន និងការធ្វើរបាយការណ៍ផ្អែកលើលទ្ធផល ស្របតាមគោលការណ៍អភិបាលកិច្ចល្អនិងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ពង្រឹងការអនុវត្តក្របខណ្ឌការងារស្តីពីការអប់រំបច្ចេកទេសសម្រាប់សិស្សមធ្យមសិក្សា
- ជំរុញការអនុវត្តគោលនយោបាយស្តីពីការអប់រំបច្ចេកទេស។

### ៣.៣.៥ សូចនាករផលសម្រេច (សាធារណៈ និងឯកជន)

- អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ថយចុះពី ២០ ភាគរយនៅឆ្នាំសិក្សា ២០១១-២០១២ ដល់ ៣ ភាគរយនៅឆ្នាំសិក្សា ២០១៦- ២០១៧
- អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ កើនឡើងពី ៥៣,៦ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ៨៧,០ ភាគរយនៅឆ្នាំសិក្សា ២០១៧- ២០១៨
- អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិកើនឡើងពី ២៧,៤ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ៤៥,០ ភាគរយនៅឆ្នាំសិក្សា ២០១៧- ២០១៨
- អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិកើនឡើងពី ៧៥,០ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ៨៣,០ ភាគរយនៅឆ្នាំសិក្សា ២០១៧-២០១៨
- អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិកើនឡើងពី ៤០,៦ ភាគរយនៅឆ្នាំសិក្សា ២០១២ -២០១៣ ដល់ ៧៦,៤ ភាគរយនៅឆ្នាំសិក្សា ២០១៧- ២០១៨
- ភាគរយសិស្សមធ្យមសិក្សាបឋមភូមិយ៉ាងតិច ៩ ភាគរយទទួលអាហារូបករណ៍ជារៀងរាល់ឆ្នាំ
- ចំនួនគ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីសាលាកុមារមេត្រីកើនឡើងពី ៥០,៧ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ៧៥ ភាគរយនៅឆ្នាំសិក្សា ២០១៧-២០១៨
- សាលាមធ្យមសិក្សាបឋមភូមិ ៩០ ភាគរយ និង សាលាមធ្យមសិក្សាទុតិយភូមិ ១០០ ភាគរយមានបង្គន់អនាម័យនិងមានទឹកស្អាត នៅឆ្នាំ ២០១៨
- ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមាន ៧ នៅឆ្នាំ ២០១៨
- ចំនួនសិស្សចូលរៀនក្នុងការអប់រំបច្ចេកទេសកើនឡើងពី ៦១០ នាក់នៅឆ្នាំសិក្សា២០១២-២០១៣ ដល់ ២០០០ នាក់ នៅឆ្នាំសិក្សា ២០១៧-២០១៨
- សាលាមធ្យមសិក្សា ៣០ ភាគរយបានអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមគោលការណ៍ណែនាំនៅឆ្នាំ២០១៨។

### ៣.៣.៦ កម្មវិធីនិងសកម្មភាព

កម្មវិធីនិងសកម្មភាពសំខាន់ៗ ដើម្បីបង្កើនការចូលរៀនប្រកបដោយសមធម៌នៅសាលាមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ ៖

- ***ការបង្កើនសិស្សចូលរៀននៅមធ្យមសិក្សា*** ៖ តាមរយៈ ការផ្តល់ថវិកាដំណើរការសាលារៀន ការបង្កើតសាលារៀន និងការផ្តល់អាហារូបករណ៍
    - ***ការបង្កើតសាលារៀននិងអភិវឌ្ឍកម្មវិធី*** ៖ សាងសង់ និងផ្តល់គ្រូបង្រៀនដល់សាលារៀន

កម្រិតអប់រំមូលដ្ឋាន បង្កើតថ្មីសាលាមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ។

- ***កម្មវិធីអាហារូបករណ៍*** ៖ ផ្តល់អាហារូបករណ៍សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ។

- ***ការអភិវឌ្ឍកម្មវិធីសិក្សានិងសម្ភារៈបង្រៀននិងរៀន*** ៖ តាមរយៈ ការអភិវឌ្ឍកម្មវិធីសិក្សា ការផ្តល់សៀវភៅសិក្សាគោល និងការអប់រំសុខភាពសិក្សា

  - ***ការអភិវឌ្ឍកម្មវិធីសិក្សា*** ៖ ធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សា ស្តង់ដារកម្មវិធីសិក្សាតាមមុខវិជ្ជាសម្រាប់មធ្យមសិក្សាបឋមភូមិនិងមធ្យមសិក្សាទុតិយភូមិ។ កសាងឯកសារ ផ្សព្វផ្សាយណែនាំការអនុវត្ត កម្មវិធីសិក្សា និងពិនិត្យតាមដានវាយតម្លៃ។ អភិវឌ្ឍសម្ភារឧបទេសសម្រាប់ការរៀននិងបង្រៀន។ អភិវឌ្ឍសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជា បោះពុម្ពចែកចាយដល់សាលារៀនចំណេះទូទៅ។

  - ***ការអភិវឌ្ឍនិងការចែកចាយសៀវភៅសិក្សាគោល*** ៖ បោះពុម្ពសៀវភៅសិក្សាគោលសម្រាប់ថ្នាក់ទី៧ ដល់ ថ្នាក់ទី១២។

  - ***ការអប់រំសុខភាពសិក្សា*** ៖ ផ្តល់ការអប់រំសុខភាពបន្តពូជ សុខភាពផ្លូវភេទ រួមបញ្ចូលទាំងការអប់រំ បង្ការជំងឺអេដស៍ គ្រឿងញៀន ការអប់រំសុខភាពអនាម័យ សុវត្ថិភាពចំណីអាហារ អាហារូបត្ថម្ភ វិធីសាស្ត្រសង្គ្រោះបឋម គ្រឿងស្រវឹង បារី សុខភាពភ្នែក ព្រមទាំងការអប់រំបង្ការជំងឺឆ្លងនិងជំងឺមិនឆ្លងដូចជា គ្រុនចាញ់ គ្រុនឈាម ដង្កូវព្រូនជាដើម នៅតាមសាលារៀន។

- ***ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន*** ៖ តាមរយៈ ការបណ្តុះបណ្តាល ការពង្រាយគ្រូបង្រៀន ការអភិវឌ្ឍសមត្ថភាពគ្រប់គ្រងអប់រំ នាយកសាលា និងការណែនាំដល់គ្រូចេញថ្មី

  - ***ការអភិវឌ្ឍការបណ្តុះបណ្តាល និងការពង្រាយគ្រូ*** ៖ ផ្តល់ថវិកាដំណើរការប្រចាំឆ្នាំដល់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។ បង្កើនសមត្ថភាពគ្រូបឋមសិក្សាឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងកំណើនសិស្សចូលរៀននៅមធ្យមសិក្សាបឋមភូមិ។ បណ្តុះបណ្តាលគ្រូគណិតវិទ្យានិងវិទ្យាសាស្ត្រ ដើម្បីបំពេញគម្លាតរវាងសាលានៅតំបន់ទីប្រជុំជននិងជនបទ អភិវឌ្ឍសមត្ថភាពវិទ្យាស្ថានជាតិអប់រំនិងវិទ្យាស្ថានជាតិអប់រំកាយនិងកីឡា ធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលគ្រូ បណ្ណារក្ស និងសម្ភារៈបង្រៀននិងរៀន បន្ទប់ពិសោធន៍ កុំព្យូទ័រ និងវិទ្យាសាស្ត្រតាមស្តង់ដារ។ អភិវឌ្ឍកម្មវិធីនិងខ្លឹមសារបណ្តុះបណ្តាលនិងវិក្រឹតការគ្រូមធ្យមសិក្សា។ បណ្តុះបណ្តាលនិងផ្គត់ផ្គង់គ្រូមធ្យមសិក្សាចន្លោះពី ២៥០០ ទៅ ៣០០០ នាក់ក្នុងមួយឆ្នាំសិក្សា។

  - ***កម្មវិធីអភិវឌ្ឍសមត្ថភាពគ្រប់គ្រងអប់រំ*** ៖ ផ្តល់ឱ្យនាយកសាលាមធ្យមសិក្សានូវជំនាញ

នានា ដើម្បីអនុវត្តការដឹកនាំឱ្យបានសកម្ម និងទទួលខុសត្រូវ និងគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាពនិងគុណភាព តាមរយៈកម្មវិធីបំប៉នសមត្ថភាពគ្រប់គ្រងអប់រំ។ ផ្សព្វផ្សាយនិងពង្រឹងការអនុវត្តស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ស្តង់ដារសាលាគរុកោសល្យ និងប្រព័ន្ធធានាគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន។

- ***ការអភិវឌ្ឍ និងពង្រីកប្រព័ន្ធការងារវិក្រឹតការ*** ៖ ពង្រីកតួនាទីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដើម្បីបណ្តុះបណ្តាលគ្រូអប់រំមូលដ្ឋាន និងដាក់ពង្រាយនៅក្នុងសាលាមធ្យមសិក្សាបឋមភូមិដែលបង្កើតថ្មី។ អភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងគ្រូមធ្យមសិក្សាអំពីការងារបច្ចេកទេសនៃការបង្រៀន ការបញ្ជ្រាបយេនឌ័រ និងការអនុវត្តកម្មវិធីសាលាកុមារមេត្រីមធ្យមសិក្សា។
- ***កម្មវិធីណែនាំដល់គ្រូចេញថ្មី*** ៖ កម្មវិធីណែនាំត្រូវបានបង្កើតឡើងនៅមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិនៅតំបន់ជនបទ។ បង្កើតក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុកក្រុង ខណ្ឌសម្រាប់មធ្យមសិក្សា។
- ***ការអភិវឌ្ឍនាយកសាលា*** ៖ បំប៉ននាយកសាលាតែងតាំងថ្មីស្តីពីភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង និងរៀបចំនីតិវិធីគ្រប់គ្រងនិងប្រតិបត្តិនៅមធ្យមសិក្សា។

- ***ការសម្របសម្រួលសាលារៀនឯកជន*** ៖ តាមរយៈ សហប្រតិបត្តិការសាលាឯកជននិងបទបញ្ជាផ្ទៃក្នុងបង្កើតនិងទទួលស្គាល់គុណភាពសាលាជាតិ និងអន្តរជាតិ។
- ***ការអប់រំមធ្យមសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស*** ៖ តាមរយៈ ការផ្តល់ថវិកាគាំទ្រដំណើរការវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ការអភិវឌ្ឍកម្មវិធីសិក្សា ការអប់រំបំណិនជីវិត ការអប់រំវិជ្ជាជីវៈជម្រើស ការផ្តល់សេវាអប់រំតម្រង់ទិសវិជ្ជាជីវៈ និងការពិគ្រោះយោបល់ជ្រើសរើសអាជីព
    - ***ដំណើរការវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស*** ៖ ផ្តល់ថវិកាដំណើរការសកម្មភាពបង្រៀននិងរៀន និងកម្មសិក្សា។
    - ***ការអភិវឌ្ឍកម្មវិធីសិក្សាមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេស*** ៖ បង្កើតនិងអភិវឌ្ឍកម្មវិធីសិក្សា (ជំនាញបច្ចេកទេសនិងចំណេះធ្វើ) សម្រាប់មធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស។ អភិវឌ្ឍវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសឱ្យទទួលបានស្តង់ដារគុណភាពដូចជា សម្ភារបរិក្ខាសមស្រប (បន្ទប់រៀន បន្ទប់ប្រតិបត្តិ និងរោងជាង) នាយកសាលាមានសមត្ថភាព និងគ្រូមានសមត្ថភាពទៅតាមបទដ្ឋាន និងកម្មវិធីសិក្សា។ ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស និងការប្រឡងសិស្សផ្នែកអប់រំបច្ចេកទេសនៅមធ្យមសិក្សា។
    - ***ការលើកកម្ពស់ការអប់រំបំណិនជីវិត*** ៖ សិក្សាស្រាវជ្រាវ និងទស្សនកិច្ចផ្លាស់ប្តូរ

បទពិសោធ កសាងឯកសារជំនួយដល់គ្រូ បំប៉នសមត្ថភាពនាយក និងគ្រូបង្រៀនអប់រំបំណិនជីវិតអំពីវិធីសាស្ត្របង្រៀន និងជំនាញពាក់ព័ន្ធនឹងផ្នែកកសិកម្ម គេហវិទ្យា រោងជាង អប់រំសិល្បៈ បំណិនការងារ បច្ចេកវិទ្យាសារគមនាគមន៍និងព័ត៌មាន ការយល់ដឹងពីការប្រែប្រួលអាកាសធាតុ ការសង្គ្រោះបន្ទាន់ និងការបង្ការនិងទប់ស្កាត់គ្រោះមហន្តរាយ។ ការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីអប់រំបំណិនជីវិតនៅតាមសាលាមធ្យមសិក្សា។

- ***ការលើកកម្ពស់ការអប់រំតម្រង់ទិសវិជ្ជាជីវៈ*** ៖ បង្កើតនិងដំណើរការគណៈកម្មការតម្រង់ទិសវិជ្ជាជីវៈនៅតាមសាលាមធ្យមសិក្សា។ បំប៉នសមត្ថភាពអ្នកពាក់ព័ន្ធនិងដឹកនាំសិស្សចុះកម្មសិក្សា និងពិនិត្យតាមដានការអនុវត្តសកម្មភាពនៅតាមសាលារៀន។
- ***លើកកម្ពស់ការអនុវត្តកម្មវិធីអប់រំវិជ្ជាជីវៈជម្រើស*** ៖ បំប៉នសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាជីវៈជម្រើស ពិនិត្យតាមដាននិងវាយតម្លៃសកម្មភាពការងារ។
- ***ការពិគ្រោះយោបល់ជ្រើសរើសអាជីព*** ៖ ផ្តល់សេវាប្រឹក្សាពីការជ្រើសរើសអាជីពដល់សិស្សនៅតាមសាលាមធ្យមសិក្សា។ កសាងឯកសារជំនួយ និងបំប៉នសមត្ថភាពដល់គ្រូ ដែលជាទីប្រឹក្សាអាជីពនៅតាមសាលាមធ្យមសិក្សា ផ្តល់ថវិកាគាំទ្រសម្រាប់ដំណើរការ និងការពិនិត្យតាមដាន និងវាយតម្លៃការពិគ្រោះយោបល់អាជីព នៅតាមសាលាមធ្យមសិក្សា។

• ***ការវាយតម្លៃលទ្ធផលសិក្សា និងការធ្វើតេស្ត*** ៖ តាមរយៈ ការអនុវត្តតេស្តនៅតាមថ្នាក់រៀនជាទៀងទាត់ ការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា ការកែលម្អប្រព័ន្ធប្រឡងថ្នាក់ជាតិ ការត្រៀមចូលរួមតេស្តលក្ខណៈជាអន្តរជាតិ និងការអភិវឌ្ឍប្រព័ន្ធធានាគុណភាពសាលារៀន

- ***ការកែលម្អគុណភាព និងការអនុវត្តតេស្តថ្នាក់រៀនទៀងទាត់*** ៖ អនុវត្តតេស្តស្តង់ដារថ្នាក់រៀន តាមដានវឌ្ឍនភាពនៃលទ្ធផលការសិក្សារបស់សិស្ស ប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ជាទៀងទាត់។
- ***លើកកម្ពស់តេស្តវាយតម្លៃថ្នាក់ជាតិ*** ៖ ពិនិត្យឡើងវិញកម្រងសំណួរតេស្តវាយតម្លៃថ្នាក់ជាតិ ដោយបញ្ចូលនូវមុខវិជ្ជាបំណិនជីវិត។ ធ្វើតេស្តថ្នាក់ជាតិលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យានៅថ្នាក់ទី ៨ និងគណិតវិទ្យានិងវិទ្យាសាស្ត្រថ្នាក់ទី១១។
- ***ការកែទម្រង់ប្រព័ន្ធប្រឡងថ្នាក់ជាតិ*** ៖ ពិនិត្យឡើងវិញប្រព័ន្ធប្រឡងថ្នាក់ជាតិសម្រាប់ថ្នាក់ទី៩និងទី១២។
- ***ការអភិវឌ្ឍតេស្តអន្តរជាតិ*** ៖ រៀបចំកម្មវិធី TIMSS និង PISA (កម្រងសំណួរ តេស្តសំណាកគំរូ រដ្ឋបាលតេស្ត ការបញ្ចូលទិន្នន័យ របាយការណ៍ និងការផ្សព្វផ្សាយនិងសកម្មភាព

កែលម្អការបង្រៀន)។

- ***ការអភិវឌ្ឍប្រព័ន្ធធានាគុណភាពសាលារៀន*** ៖ រៀបចំប្រព័ន្ធធានាគុណភាពសាលារៀន។ សាកល្បង និងបញ្ចប់ប្រព័ន្ធធានាគុណភាពសាលារៀន។

- ***ការអភិវឌ្ឍសម្ភាររូបវន្ត*** ៖ តាមរយៈ ការសាងសង់និងជួសជុលអគារសិក្សា បណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ អន្តេវាសិកដ្ឋានសម្រាប់គ្រូនៅជនបទ និងសម្ភារៈអនាម័យតាមសាលារៀន
    - ***ការសាងសង់សាលារៀន*** ៖ ជួសជុលអគារ ថ្នាក់រៀនចាស់ និងសាងសង់អគារថ្នាក់រៀនថ្មី និងអន្តេវាសិកដ្ឋានសម្រាប់សិស្ស។
    - ***ការអភិវឌ្ឍបណ្ណាល័យ*** ៖ រៀបចំស្តង់ដារបណ្ណាល័យសាលាមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិមានបណ្ណាល័យសមស្របតាមស្តង់ដារ (សម្ភារៈរៀននិងបង្រៀន ការភ្ជាប់ប្រព័ន្ធអ៊ីនធឺណេត និងប្រតិបត្តិបានពេញលេញ)។
    - ***បន្ទប់ពិសោធសម្រាប់មធ្យមសិក្សាទុតិយភូមិ*** ៖ រៀបចំស្តង់ដារបន្ទប់ពិសោធវិទ្យាសាស្ត្រ (បន្ទប់ពិសោធន៍សម្រាប់ការពិសោធន៍វិទ្យាសាស្ត្រ បានប្រតិបត្តិពេញលេញនិងធ្វើបច្ចុប្បន្នភាពបន្ទប់ពិសោធន៍វិទ្យាសាស្ត្រនៅវិទ្យាស្ថានជាតិអប់រំ)។
    - ***បន្ទប់កុំព្យូទ័រសម្រាប់មធ្យមសិក្សា*** ៖ រៀបចំបន្ទប់កុំព្យូទ័រនៅសាលាមធ្យមសិក្សានិងបានប្រតិបត្តិពេញលេញ ជ្រើសរើសគ្រូព័ត៌មានវិទ្យានិងបណ្តុះបណ្តាលលើវិធីសាស្ត្របង្រៀនកុំព្យូទ័រ
    - ***សម្ភាររូបវន្តសម្រាប់គ្រូនៅសាលាជនបទ*** ៖ រៀបចំអន្តេវាសិកដ្ឋានសម្រាប់គ្រូ ភ្ជាប់ប្រព័ន្ធពន្លឺព្រះអាទិត្យទៅនឹងសាលាគ្មានអគ្គីសនី កុំព្យូទ័រសម្រាប់គ្រូ និងរៀបចំកិច្ចសន្យាសម្រាប់គ្រូ។
    - ***ការបំពាក់សម្ភាររូបវន្តអនាម័យតាមសាលារៀន*** ៖ ផ្គត់ផ្គង់ទឹកស្អាត បង្គន់អនាម័យ កន្លែងលាងដៃ ផ្តល់ប្រអប់សង្គ្រោះបឋម និងសម្ភារៈបម្រុង និងគ្រប់គ្រងកាកសំណល់រឹងរាវ ព្រមទាំងរៀបចំនិងរក្សាទុកព័ត៌មានសុខភាពរបស់សិស្សនៅតាមសាលារៀន។
    - ***ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធការបណ្តុះបណ្តាលគ្រូបង្រៀន*** ៖ កសាងនិងជួសជុលបរិស្ថានអគារសិក្សា អន្តេវាសិកដ្ឋាន បន្ទប់ទឹក បន្ទប់ពិសោធ និងបំពាក់សម្ភាររូបវន្តនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។

- ***ការអភិវឌ្ឍក្របខណ្ឌច្បាប់ លិខិតបទដ្ឋាន ពង្រឹងអភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*** ៖ ធ្វើទំនើបកម្មច្បាប់និងគោលនយោបាយ ផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈវិស័យអប់រំ ប្រយុទ្ធប្រឆាំងការជួញដូរ

ការរត់ពន្ធមនុស្សនិងពលកម្មកុមារ លើកកម្ពស់យេនឌ័រ ជំរុញការអនុវត្តយន្តការប្រឆាំងអំពើពុករលួយ ពង្រឹងសមត្ថភាពដោះស្រាយនិងទប់ស្កាត់វិវាទក្នុងវិស័យអប់រំ និងពិនិត្យតាមដានវិវាទបុគ្គលិកអប់រំក្នុងប្រព័ន្ធតុលាការ។

- ***កិច្ចសហប្រតិបត្តិការ ៖***
  - ***ថ្នាក់ជាតិ*** ៖សហការជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍក្នុងការលើកកម្ពស់គុណភាព ប្រសិទ្ធភាពអប់រំ និងអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ
  - ***ថ្នាក់តំបន់ និងអន្តរជាតិ*** ៖ អនុវត្តកិច្ចព្រមព្រៀង សហប្រតិបត្តិការវិស័យអប់រំទ្វេភាគី និងពហុភាគី។

## ៣.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា

### ៣.៤.១ សាវតារ

ក្នុងអំឡុងឆ្នាំ២០០៩-២០១៣ ឧត្តមសិក្សាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាមួយនឹងកំណើននិស្សិត ៥៧ ភាគរយ ពី ១៣៧២៥៣ នាក់ដល់ ២១៦០៥៣ នាក់។ ចំនួននិស្សិតទទួលអាហារូបករណ៍រដ្ឋនៅតាមគ្រឹះស្ថានឧត្តមសិក្សាមានការកើនឡើងទ្វេដងពី ៩០៩៧ នាក់ ដល់ ១៨៩០៦ នាក់។ ក៏ប៉ុន្តែចំនួននិស្សិតអាហារូបករណ៍នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមានប្រមាណ ១៦,៤ ភាគរយនៅឆ្នាំ ២០០៩ និង ១៨,៧ ភាគរយនៅឆ្នាំ ២០១៣ (កើន ២,៣ ភាគរយ)។ អគ្គនាយកដ្ឋានឧត្តមសិក្សានិងគ្រឹះស្ថានឧត្តមសិក្សាបានអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ក្នុងការកសាងផែនការនិងការពិនិត្យតាមដានការគ្រប់គ្រងមូលនិធិស្រាវជ្រាវ មូលនិធិអាហារូបករណ៍ និងមានលទ្ធភាពទាញយកមូលនិធិឱ្យកាន់តែច្រើន ដើម្បីពង្រីកកម្មវិធី។ វប្បធម៌នៃការស្រាវជ្រាវបានចាប់ផ្តើមផុសឡើង តាមរយៈការអនុវត្តកម្មវិធីផ្តល់មូលនិធិស្រាវជ្រាវ និងមានកិច្ចសហប្រតិបត្តិការក្នុងតំបន់រឹងមាំ កិច្ចសហការ និងសកម្មភាពបានអនុវត្តរួមគ្នា។ សកម្មភាពគោលនយោបាយសំខាន់ៗមួយចំនួនដែលត្រូវបានអនុវត្ត ដូចជាការអនុម័តផែនការគោល ស្តីពីការស្រាវជ្រាវ ព្រះរាជក្រឹត្យស្តីពីចំណាត់ថ្នាក់សាស្ត្រាចារ្យ និងការរៀបចំចក្ខុវិស័យឧត្តមសិក្សាឆ្នាំ ២០៣០។ ការបង្កើតក្រុមការងារបច្ចេកទេសឧត្តមសិក្សាជាជំណាក់កាលសំខាន់មួយ ក្នុងការបង្កើតវេទិកាមួយសម្រាប់ការជជែកនិងពិភាក្សា អំពីបញ្ហានៅឧត្តមសិក្សា។

បញ្ហាប្រឈមចម្បងសម្រាប់ឆ្នាំខាងមុខនេះគឺ ការដោះស្រាយអំពីភាពខុសគ្នារវាងតម្រូវការទីផ្សារការងារ ជាពិសេស ជំនាញសមត្ថភាពក្នុងការគិតពិចារណានិងចំណេះដឹង ជាមួយនឹងជំនាញរបស់បរិញ្ញាជនបញ្ចប់ការសិក្សានាពេលបច្ចុប្បន្ន។ កត្តានេះទាមទារឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងអំពីទីផ្សារការងារ ការសម្របសម្រួលល្អប្រសើរជាងមុន និងមានតំណភ្ជាប់ជាមួយនឹងវិស័យឧស្សាហកម្ម និងព័ត៌មានកាន់តែប្រសើរឡើងសម្រាប់និស្សិត ដូច្នេះពួកគេអាចជ្រើសរើសវគ្គសិក្សាមុខជំនាញដែលសមស្រប។ ដើម្បីរក្សាបាននូវកម្មវិធីមានគុណភាពខ្ពស់ដែលអាចទទួលស្គាល់ជាអន្តរជាតិបាននោះ ការកំណត់រចនាសម្ព័ន្ធតម្លៃសិក្សាមួយដែលមានកម្រិតសមរម្យក៏ជាបញ្ហាប្រឈមមួយផងដែរ។ ការបង្កើនកិច្ចខិតខំប្រឹងប្រែងនិងការផ្តល់ធនធានបន្ថែម ជាកត្តាចាំបាច់ដើម្បីធានាថាសិស្សដែលមានទេពកោសល្យ និងមកពីក្រុមជួបការលំបាក នឹងអាចចូលសិក្សានៅឧត្តមសិក្សា តាមរយៈកម្មវិធីអាហារូបករណ៍ ឬគម្រោងប្រាក់កម្ចីសិក្សា។

រាជរដ្ឋាភិបាលបានទទួលស្គាល់អំពីសារៈសំខាន់ នៃការផ្តល់កាលានុវត្តភាពក្នុងការសិក្សានៅឧត្តមសិក្សា និងអំពីសារៈសំខាន់ក្នុងការធានាគុណភាពនិងភាពឆ្លើយតប។ ការធ្វើសមាហរណកម្មអាស៊ាននឹងផ្តល់ជាកាលានុវត្តភាព សម្រាប់ការសហការរវាងស្ថាប័ន ការស្រាវជ្រាវរួមគ្នា និងការកំណត់ស្តង់ដារគុណភាព។

### ៣.៤.២ វត្ថុបំណងគោលនយោបាយ

- បង្កើនភាគរយនិស្សិតអាហារូបករណ៍ និងកាលានុវត្តភាព ដល់និស្សិតចូលរៀននៅឧត្តមសិក្សា
- លើកកម្ពស់គុណភាព និងភាពឆ្លើយតប នៃការអប់រំឧត្តមសិក្សា
- អភិវឌ្ឍប្រព័ន្ធអប់រំឧត្តមសិក្សាឱ្យមានការប្រតិបត្តិពេញលេញ សម្រាប់គាំទ្រគ្រឹះស្ថានឧត្តមសិក្សា ដើម្បីទទួលបាន ស្តង់ដារថ្នាក់ជាតិ និងថ្នាក់តំបន់ នៅឆ្នាំ២០១៨។

### ៣.៤.៣ សកម្មភាពគោលនយោបាយ

- រៀបចំគោលនយោបាយជាតិស្តីពីអាហារូបករណ៍ ការឧបត្ថម្ភធន និងឥណទានសម្រាប់អ្នកសិក្សា នៅឧត្តមសិក្សា នៅឆ្នាំ ២០១៤
- រៀបចំផែនការបង្កើនចំនួននិស្សិតផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម សិល្បៈច្នៃប្រឌិត និង គណិតសាស្ត្រ នៅឆ្នាំ ២០១៤
- រៀបចំផែនការពង្រីកសេវាកម្មនិងធនធានរបស់គ្រឹះស្ថានឧត្តមសិក្សាតាមតំបន់ នៅឆ្នាំ ២០១៦
- បង្កើតគោលនយោបាយអភិវឌ្ឍធនធានមនុស្សសម្រាប់ឧត្តមសិក្សា នៅឆ្នាំ ២០១៥
- រៀបចំសេចក្តីណែនាំស្តីពីការជ្រើសរើសនិស្សិតចូលរៀននិងការបញ្ចប់ការសិក្សា នៅឆ្នាំ ២០១៤
- រៀបចំគោលការណ៍ណែនាំអំពីតម្លៃសិក្សាអប្បបរមាតាមមុខជំនាញសិក្សានៅឧត្តមសិក្សា នៅឆ្នាំ ២០១៧
- រៀបចំគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍកម្មវិធីសិក្សា នៅឆ្នាំ ២០១៦
- រៀបចំគោលការណ៍ណែនាំស្តីពីការវាយតម្លៃតាមថ្នាក់រៀនជាប្រចាំ នៅឆ្នាំ ២០១៥
- រៀបចំបង្កើតមហាវិទ្យាល័យអប់រំនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅឆ្នាំ ២០១៤
- រៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពីគម្រោងស្រាវជ្រាវ នៅឆ្នាំ២០១៥
- រៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងបណ្ណាល័យ នៅឆ្នាំ ២០១៤
- រៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងបន្ទប់ពិសោធន៍ នៅឆ្នាំ ២០១៤
- រៀបចំសេចក្តីណែនាំស្តីពីការអភិវឌ្ឍកម្មវិធីចុះកម្មសិក្សា នៅឆ្នាំ ២០១៥
- រៀបចំសេចក្តីណែនាំស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា នៅឆ្នាំ ២០១៤
- រៀបចំយន្តការអនុវត្តព្រះរាជក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ នៅឆ្នាំ ២០១៥
- រៀបចំរចនាសម្ព័ន្ធនិងយន្តការអនុវត្តគោលនយោបាយស្តីពីការស្រាវជ្រាវនិងអភិវឌ្ឍនៅឆ្នាំ២០១៤

- រៀបចំស្តង់ដារនិងគោលការណែនាំអំពីការធានាគុណភាពផ្ទៃក្នុង នៅឆ្នាំ ២០១៥
- រៀបចំផែនការផ្តែកលើលទ្ធផលនៅឧត្តមសិក្សា ២០១៤-២០១៨ នៅឆ្នាំ ២០១៤
- រៀបចំគោលការណ៍ណែនាំស្តីពីប្រព័ន្ធពិនិត្យតាមដានវាយតម្លៃផ្អែកលើលទ្ធផល នៅឆ្នាំ២០១៥
- កែលម្អប្រព័ន្ធស្តីពីការទទួលស្គាល់និងការបង្កើតគ្រឹះស្ថានឧត្តមសិក្សា នៅឆ្នាំ ២០១៤
- រៀបចំគំរូផែនការអភិវឌ្ឍន៍និងធុរកិច្ចនៅតាមគ្រឹះស្ថានឧត្តមសិក្សា នៅឆ្នាំ ២០១៦
- រៀបចំលិខិតបទដ្ឋានស្តីពីការផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សា នៅឆ្នាំ២០១៤
- រៀបចំគោលនយោបាយអភិបាលកិច្ចនិងការគ្រប់គ្រងហិរញ្ញវត្ថុនៅឧត្តមសិក្សា នៅឆ្នាំ២០១៦
- កសាងផែនការគោលសម្រាប់បង្កើតសាកលវិទ្យាល័យជាតិ នៅឆ្នាំ២០១៨។

### ៣.៤.៤ យុទ្ធសាស្ត្រ

- បង្កើនកញ្ចប់ថវិកាអាហារូបករណ៍និងកាលានុវត្តភាពដល់និស្សិតក្រីក្រ និស្សិតនារី និងនិស្សិតពិការ
- ពង្រឹងសមត្ថភាពស្រូបយកនិស្សិតរបស់គ្រឹះស្ថានឧត្តមសិក្សាតាមតំបន់
- ពង្រីកសមត្ថភាពស្រូបយកនិស្សិតផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតសាស្ត្រនៅឧត្តមសិក្សា
- អភិវឌ្ឍសមត្ថភាពបុគ្គលិកបង្រៀន និងបុគ្គលិករដ្ឋបាលនៅឧត្តមសិក្សា
- លើកកម្ពស់គុណភាពនៃការរៀន ការបង្រៀន និងការស្រាវជ្រាវនៅឧត្តមសិក្សា
- ជំរុញការធ្វើពិពិធកម្មកម្មវិធីសិក្សានិងកម្មវិធីអាទិភាពស្របតាមស្តង់ដាររបស់អាស៊ាន (វិស្វកម្ម ស្ថាបត្យកម្ម វេជ្ជសាស្ត្រ ទន្តសាស្ត្រ គិលានុបដ្ឋាក គណនេយ្យ ទេសចរណ៍ និងសេវាកម្មអាជីព)
- បង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អនុវិស័យឧត្តមសិក្សា ជាពិសេសទៅលើកម្មវិធីអាទិភាព
- ពង្រឹងប្រព័ន្ធធានាគុណភាពផ្ទៃក្នុងរបស់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការឆ្លើយតបទៅនឹងប្រព័ន្ធទទួលស្គាល់គុណភាពឧត្តមសិក្សា
- ពង្រឹងស្វ័យភាព គណនេយ្យភាព និងតម្លាភាព ក្នុងកម្មវិធីហិរញ្ញប្បទានឧត្តមសិក្សា
- ពង្រឹងការធ្វើផែនការ ការរៀបចំថវិកា ការអនុវត្ត និងការពិនិត្យតាមដានវាយតម្លៃ និងការធ្វើរបាយការណ៍ដោយផ្អែកលើលទ្ធផលនៅឧត្តមសិក្សា
- ពង្រឹងកម្មវិធីអប់រំសុខភាពនៅគ្រឹះស្ថានឧត្តមសិក្សា។

### ៣.៤.៥ សូចនាករផលសម្រេច

- ចំនួនសាស្ត្រាចារ្យដែលមានគុណវុឌ្ឍកម្រិតបរិញ្ញាបត្រជាន់ខ្ពស់កើន ១០០០ នាក់ និងកម្រិតបណ្ឌិត កើន ២៥០ នាក់ នៅឆ្នាំ ២០១៨
- ភាគរយនិស្សិតអាហារូបករណ៍រដ្ឋចូលរៀនឆ្នាំទី១ នៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋ កើនឡើងពី ៥ ភាគរយ នៅឆ្នាំ ២០១២ ដល់ ១៥ ភាគរយ នៅឆ្នាំ ២០១៨
- អត្រារួមនៃការសិក្សានៅឧត្តមសិក្សាកើនពី ១៣ ភាគរយ នៅឆ្នាំ ២០១២ ដល់ ២៣ ភាគរយ នៅឆ្នាំ ២០១៨
- អត្រានិស្សិតបញ្ចប់ការសិក្សាចន្លោះពី ៧៥ ទៅ ៨៥ ភាគរយ
- ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើបានកើនឡើងនៅឆ្នាំ ២០១៨ ចំនួន៥ ទៅ ១០ ភាគរយ ធៀបនឹងទិន្នន័យគោលដែលនឹងរកឃើញ ក្នុងឆ្នាំ ២០១៤
- ៨០ ភាគរយនៃគ្រឹះស្ថានឧត្តមសិក្សា បានរៀបចំផែនការថវិកាប្រចាំឆ្នាំ នៅឆ្នាំ ២០១៨
- ៥០ ភាគរយនៃគ្រឹះស្ថានឧត្តមសិក្សា សម្រេចបានតាមស្តង់ដារធានាគុណភាពផ្ទៃក្នុង នៅឆ្នាំ ២០១៨
- ថវិកាសម្រាប់អនុវិស័យឧត្តមសិក្សាពី ៤ ភាគរយ ដល់ ២០ ភាគរយ នៅឆ្នាំ ២០១៨
- ប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលនៅឧត្តមសិក្សា នឹងដំណើរការ នៅឆ្នាំ ២០១៨។

### ៣.៤.៦ កម្មវិធីនិងសកម្មភាព

- *កម្មវិធីបង្កើនសមធម៌នៃការចូលរៀននៅឧត្តមសិក្សា៖*
    - *កម្មវិធីផ្តល់និងពង្រីកអាហារូបករណ៍* ៖ ពង្រីកនិងផ្តល់អាហារូបករណ៍ពេញលេញតាមរយៈ ការបង្កើនថវិកាបស់រាជរដ្ឋាភិបាល និងថវិកាដៃគូអភិវឌ្ឍ។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សានិងគ្រឹះស្ថានឧត្តមសិក្សា និងដៃគូអភិវឌ្ឍចូលរួមសិក្ខាសាលា និងទស្សនកិច្ចសិក្សាស្តីពីអាហារូបករណ៍។
    - *កម្មវិធីផ្តល់ប្រាក់កម្ចីសម្រាប់អ្នកសិក្សា* ៖ នាយកដ្ឋានឧត្តមសិក្សាសហការជាមួយគ្រឹះស្ថានឧត្តមសិក្សានិងផ្នែកពាក់ព័ន្ធដទៃទៀត រៀបចំនិងអនុវត្តកម្មវិធីផ្តល់ប្រាក់កម្ចីសម្រាប់អ្នកសិក្សា។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា គ្រឹះស្ថានឧត្តមសិក្សា និងអ្នកពាក់ព័ន្ធចូលរួមសិក្ខាសាលា និងទស្សនកិច្ចសិក្សាស្តីពីការផ្តល់ប្រាក់កម្ចីសម្រាប់អ្នកសិក្សា។
    - *ការផ្តល់សេវាសិក្សា* ៖ ផ្តល់ការគាំទ្រលើការសិក្សាដល់និស្សិតជួបការលំបាក ជាពិសេសដល់និស្សិត នៅឆ្នាំសិក្សាមូលដ្ឋាន ដូចជាសេវាប្រឹក្សាយោបល់។

- *ការអប់រំសុខភាព* ៖ សហការជាមួយអ្នកពាក់ព័ន្ធក្នុងវិស័យសុខាភិបាល ដើម្បីពង្រឹងសុខមាលភាពនិស្សិត និងបុគ្គលិកអប់រំ។
- *កម្មវិធីវិនិយោគ* ៖ បង្កើនធនធានមនុស្ស ហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្រាប់ការពង្រីកកម្មវិធីអាទិភាពដូចជាផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតសាស្ត្រ និងសម្រាប់ការលើកកម្ពស់គុណភាពនៃការអប់រំឧត្តមសិក្សា។

- *កម្មវិធីកែលម្អគុណភាព និងបង្កើនភាពឆ្លើយតបនឹងទីផ្សារការងារ*
  - *ការអភិវឌ្ឍកម្មវិធីសិក្សា* ៖ គ្រឹះស្ថានឧត្តមសិក្សាត្រូវអភិវឌ្ឍកម្មវិធីសិក្សាដោយផ្អែកលើតម្រូវការទីផ្សារការងារ ដោយបញ្ចូលកម្មវិធីសហគ្រិនភាព និងផ្តោតការយកចិត្តទុកដាក់លើបំណិននៃការវិភាគ ការដោះស្រាយបញ្ហា ការធ្វើការងារជាក្រុម ការប្រាស្រ័យទាក់ទង។ល។ និងសូចនាករនៃស្តង់ដារកម្មវិធីសិក្សាអាទិភាពរបស់អាស៊ាន។ កែលម្អកម្មវិធីសិក្សាភាសាបរទេសនៅតាមគ្រឹះស្ថានឧត្តមសិក្សា ដើម្បីពង្រឹងសមត្ថភាពចំណេះដឹងភាសាអង់គ្លេសរបស់និស្សិតស្របតាមតម្រូវការជាក់ស្តែង។ រៀបចំក្របខណ្ឌសមត្ថភាពសម្រាប់ឧត្តមសិក្សា។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិនិងអន្តរជាតិ និងទស្សនកិច្ចសិក្សាស្តីពីអភិវឌ្ឍកម្មវិធីសិក្សា។
  - *កម្មវិធីកែលម្អវិធីសាស្ត្របង្រៀននិងរៀន* ៖ ណែនាំគរុកោសល្យច្នៃប្រឌិតសម្រាប់ការរៀន និងបង្រៀន តាមរយៈការស្រាវជ្រាវនិងទំនើបកម្មសម្ភារៈសិក្សា រួមបញ្ចូលទាំងបន្ទប់រៀន បន្ទប់ពិសោធន៍ និងបណ្ណាល័យ។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិនិងអន្តរជាតិ និងទស្សនកិច្ចសិក្សាស្តីពីវិធីសាស្ត្ររៀននិងបង្រៀន។
  - *កម្មវិធីស្រាវជ្រាវ និងផ្សព្វផ្សាយ* ៖ បង្កើតមូលនិធិស្រាវជ្រាវឧត្តមសិក្សា ។ ពង្រីកធនធានស្រាវជ្រាវ តាមរយៈការបកប្រែឯកសាររបស់អ្នកនិពន្ធល្បីៗតាមមុខជំនាញទៅជាភាសាខ្មែរ ការជាវឯកសារជាតិ និងអន្តរជាតិ និងការជំរុញការបោះពុម្ពឯកសារស្រាវជ្រាវជាភាសាខ្មែរ។ បង្កើតក្របខណ្ឌស្រាវជ្រាវសម្រាប់និស្សិត។ រៀបចំកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈដល់អ្នកត្រួតពិនិត្យនិក្ខេបបទ។ បង្កើតយន្តការត្រួតពិនិត្យនិក្ខេបបទ។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិនិងអន្តរជាតិ និងទស្សនកិច្ចសិក្សាស្តីពីការស្រាវជ្រាវ និងការអភិវឌ្ឍ។
  - *កម្មវិធីធានាគុណភាពផ្ទៃក្នុង* ៖ ជំរុញការបង្កើតរចនាសម្ព័ន្ធ និងស្តង់ដារធានាគុណភាពផ្ទៃក្នុងនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ជំរុញការរៀបចំយន្តការ និងដំណើរការស្វ័យវាយតម្លៃរបស់គ្រឹះស្ថានឧត្តមសិក្សាផ្អែកតាមស្តង់ដារដែលបានកំណត់ ជាពិសេសផ្តោតលើ

កម្មវិធីសិក្សាជាអាទិភាពរបស់អាស៊ាន។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិនិងអន្តរជាតិ និងទស្សនកិច្ចសិក្សាស្តីពីការធានាគុណភាពអប់រំឧត្តមសិក្សា ។

- *កម្មវិធីបង្កើតមហាវិទ្យាល័យអប់រំ* ៖ រៀបចំបង្កើតមហាវិទ្យាល័យអប់រំនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញចូលរួមសិក្ខាសាលា និងទស្សនកិច្ចសិក្សាស្តីពីបង្កើតមហាវិទ្យាល័យអប់រំ។
- *កម្មវិធីបង្កើតសាកលវិទ្យាល័យជាតិ* ៖ សិក្សាអំពីលទ្ធភាពបង្កើតសាកលវិទ្យាល័យជាតិ។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា គ្រឹះស្ថានឧត្តមសិក្សានិងអ្នកពាក់ព័ន្ធចូលរួមសិក្ខាសាលា និងទស្សនកិច្ចសិក្សាស្តីពីការបង្កើតសាកលវិទ្យាល័យជាតិ។
- *ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា* ៖ សិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដើម្បីវាយតម្លៃអំពីប្រសិទ្ធភាពការអប់រំ ទាក់ទងនឹងភាពមានការងារធ្វើ មិនមានការងារធ្វើ និងស្ថានភាពការងារ។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា។
- *ការជ្រើសរើសនិស្សិតចូលរៀន និងការបញ្ចប់ការសិក្សា* ៖ ពង្រឹងការជ្រើសរើសនិស្សិតចូលរៀន និងការបញ្ចប់ការសិក្សារបស់និស្សិតដោយផ្អែកលើគោលការណ៍ ដែលបានកំណត់។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាចូលរួមសិក្ខាសាលាស្តីពីការជ្រើសរើសនិស្សិតចូលរៀន និងការបញ្ចប់ការសិក្សារបស់និស្សិត។

- ***កម្មវិធីអភិវឌ្ឍសមត្ថភាព និងប្រព័ន្ធឧត្តមសិក្សា*** ៖
  - *កម្មវិធីអភិវឌ្ឍគោលនយោបាយសាធារណៈ* ៖ បង្កើតបទដ្ឋានថ្មីស្របតាមច្បាប់ស្តីពីការអប់រំ និងកែលម្អបទដ្ឋានដែលមានស្រាប់ទាក់ទងការបង្កើត ការគ្រប់គ្រង និងស្វ័យភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ រៀបចំវេទិកាឧត្តមសិក្សាប្រចាំឆ្នាំ។ បង្កើតយន្តការសម្របសម្រួលថ្នាក់ជាតិ ដើម្បីអភិវឌ្ឍអនុវិស័យឧត្តមសិក្សាប្រកបដោយប្រសិទ្ធភាព និងគុណភាព។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សានិងគ្រឹះស្ថានឧត្តមសិក្សាចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាល ថ្នាក់ជាតិនិងអន្តរជាតិ និងទស្សនកិច្ចសិក្សាស្តីពីការអភិវឌ្ឍគោលនយោបាយសាធារណៈ។ បង្កើតក្របខណ្ឌបុគ្គលិកលក្ខណៈ និងសមត្ថភាពរបស់និស្សិតដែលបញ្ចប់ការសិក្សាឱ្យស្របតាមតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍជាតិ។
  - *កម្មវិធីអភិវឌ្ឍសមត្ថភាព* ៖ បង្កើតមូលនិធិអាហារូបករណ៍កម្រិតក្រោយបរិញ្ញាបត្រតាមរយៈរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ។ លើកកម្ពស់សមត្ថភាពភាសាបរទេស និងកុំព្យូទ័រ

របស់មន្ត្រីនាយកដ្ឋានឧត្តមសិក្សា និងនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ។ បន្តអភិវឌ្ឍសមត្ថភាពបុគ្គលិក តាមរយៈចូលរួមសិក្ខាសាលានិងវគ្គសិក្សានិងការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រទាំងនៅក្នុងនិងក្រៅប្រទេស។ គ្រឹះស្ថានឧត្តមសិក្សាលើកកម្ពស់សមត្ថភាពរបស់បុគ្គលិក។ កែលម្អប្រព័ន្ធបៀវត្សនៅតាមគ្រឹះស្ថានឧត្តមសិក្សា ដើម្បីធានាការគាំទ្រដ៏មានប្រសិទ្ធភាពចំពោះបុគ្គលិកដែលមានសមត្ថភាព។ ពង្រឹងយន្តការជ្រើសរើសបុគ្គលិក និងប្រព័ន្ធលើកទឹកចិត្ត ដើម្បីទាក់ទាញនិងរក្សាទុកអ្នកមានសមត្ថភាពសម្រាប់បម្រើការងារនៅក្នុងអនុវិស័យឧត្តមសិក្សា។ បង្កើតវេទិកាដើម្បីប្រមូលអ្នកបញ្ចប់ការសិក្សាពីបរទេសនិងជនជាតិខ្មែរ ដែលមានបទពិសោធន៍បង្រៀនតាមសាកលវិទ្យាល័យនៅបរទេសសម្រាប់បម្រើការងារនៅក្នុងអនុវិស័យឧត្តមសិក្សា។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាចូលរួមសិក្ខាសាលា និងទស្សនកិច្ចសិក្សាស្តីពីការអភិវឌ្ឍសមត្ថភាពសម្រាប់ឧត្តមសិក្សា ។

- ***កម្មវិធីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានឧត្តមសិក្សា*** ៖ រៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា និងដំណើរការពេញលេញដើម្បីសម្រួលដល់ការកសាងផែនការនាពេលខាងមុខ។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិនិងអន្តរជាតិ និងទស្សនកិច្ចសិក្សាស្តីពីការរៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា។
- ***កិច្ចសហប្រតិបត្តិការក្នុងនិងក្រៅប្រទេស និងដៃគូអភិវឌ្ឍ*** ៖ ផ្លាស់ប្តូរបទពិសោធន និស្សិត សាស្ត្រាចារ្យ ការសិក្សាស្រាវជ្រាវ និងកម្មសិក្សា។ ពង្រឹងការគ្រប់គ្រងនិស្សិតក្នុងនិងក្រៅប្រទេស (អន្តេវាសិកដ្ឋាន)។
- ***ការអភិវឌ្ឍសម្ភារូបវន្ត*** ៖ កែលម្អហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានឧត្តមសិក្សារួមបញ្ចូលការបំពាក់មូលដ្ឋានសម្ភារៈ ការបង្កើតបន្ទប់ពិសោធន៍ និងបណ្ណាល័យ ដើម្បីបម្រើឱ្យការរៀន និងបង្រៀន និងការស្រាវជ្រាវ។
- ***ប្រព័ន្ធគ្រប់គ្រងឧត្តមសិក្សាផ្អែកលើលទ្ធផល*** ៖ កសាងផែនការ និងការពិនិត្យតាមដានដោយផ្អែកលើលទ្ធផល។ រៀបចំសាកល្បងនិងអនុវត្តប្រព័ន្ធគ្រប់គ្រងឧត្តមសិក្សាផ្អែកលើលទ្ធផល២០១៤-២០១៨។ ពង្រឹងការពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលដើម្បីបង្កើនភាពជាដៃគូរវាង អគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សា។ រៀបចំផែនការពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលប្រចាំឆ្នាំ។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ និងអន្តរជាតិស្តីពីការកសាងផែនការ និងការពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល។

## ៣.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

### ៣.៥.១ សាវតារ

ក្នុងកំឡុងឆ្នាំ ២០០៩-២០១៣ អនុវិស័យអប់រំក្រៅប្រព័ន្ធមានការរីកចម្រើន ជាពិសេសអត្រាអក្ខរកម្មយុវជនអាយុ ១៥-២៤ កើនដល់ ៩១,៥ ភាគរយ នៅឆ្នាំ ២០១១។

ចំនួនថ្នាក់អក្ខរកម្មបានថយចុះពី ២១៤១ ថ្នាក់នៅឆ្នាំ ២០០៩ មកត្រឹម ១៥០០ ថ្នាក់នៅឆ្នាំ ២០១១ (ថយចុះ ៣០ ភាគរយ)។ ចំនួនអ្នកសិក្សាបានថយចុះពី ៥២០៧៨ នាក់មកត្រឹម ៣៥៩៦៤ នាក់ (ថយចុះ ៣២ ភាគរយ)។ បរិមាណនេះស្មើនឹង ២,៨ ភាគរយនៃអនក្ខរជននៅឆ្នាំ ២០១១។ ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍បានកើនពី ១៥៤ កន្លែងក្នុងឆ្នាំ ២០០៩ ដល់ ៣២១ កន្លែងក្នុងឆ្នាំ ២០១២ ។ ចំនួនថ្នាក់បណ្តុះបណ្តាលជំនាញបានកើនឡើងពី ១៥៤ ថ្នាក់ទៅដល់ ៦៦៧ ថ្នាក់ ក្នុងនោះជំនាញសិប្បកម្ម ៣៥,៨ ភាគរយ ជំនាញអ៊ុតសក់និងតុបតែង ១៩,៥ ភាគរយ ភ្លេងនិងរបាំ ១៥,១ ភាគរយ ជំនាញម៉ាស៊ីន ១២,៧ ភាគរយ និងជំនាញដទៃទៀត។ ចំនួនសិស្សក្នុងកម្មវិធីចូលរៀនឡើងវិញបានថយចុះពី ២៦១៧៦ នាក់មកត្រឹម ២១៣៦៦ នាក់ ទាបជាងចំណុចដៅរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២២០០០ នាក់។

ក្របខ័ណ្ឌស្ថាប័ននិងគោលនយោបាយត្រូវបានពង្រឹង តាមរយៈការពិនិត្យឡើងវិញគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធនិងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធនិងការកសាងផែនទី ក៏ដូចជាការពិនិត្យឡើងវិញកម្មវិធីចូលរៀនឡើងវិញនិងការរៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធនិងកម្មវិធីសមមូល។

### ៣.៥.២ វត្ថុបំណងគោលនយោបាយ

- បង្កើនចំនួនអក្ខរជននិងការចូលរៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ សម្រាប់កុមារ យុវជនក្រៅសាលា និងអនក្ខរជនពេញវ័យ
- កុមារ យុវជនក្រៅសាលា និងអនក្ខរជនពេញវ័យទទួលបានចំណេះដឹង ជំនាញមុខរបរ បំណិនជីវិតពីសេវាអប់រំក្រៅប្រព័ន្ធ ដែលឆ្លើយតបនឹងតម្រូវការរបស់អ្នកសិក្សានិងសហគមន៍ ដើម្បីកែលម្អគុណភាពនៃជីវិតរស់នៅ
- ធានាប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលនៃកម្មវិធីអប់រំក្រៅប្រព័ន្ធ បានដំណើរការពេញលេញ។

### ៣.៥.៣ សកម្មភាពគោលនយោបាយ

- រៀបចំផែនការសកម្មភាពស្តីពីការពន្លឿនអក្ខរកម្ម នៅឆ្នាំ ២០១៤
- កែសម្រួលសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីចូលរៀនឡើងវិញ នៅឆ្នាំ ២០១៤
- កែសម្រួលសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ នៅឆ្នាំ ២០១៤
- រៀបចំសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ នៅឆ្នាំ ២០១៤

- រៀបចំសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសមមូលមធ្យមសិក្សាទុតិយភូមិ នៅឆ្នាំ ២០១៦
- កែសម្រួលសេចក្តីណែនា ស្តីពីការដឹកនាំនិងគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍នៅឆ្នាំ២០១៤
- រៀបចំសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីក្រោយអក្ខរកម្ម នៅឆ្នាំ ២០១៨
- រៀបចំប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលនៃកម្មវិធីអប់រំក្រៅប្រព័ន្ធ នៅឆ្នាំ ២០១៥
- កែសម្រួលសេចក្តីណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធនៅឆ្នាំ ២០១៤
- រៀបចំស្តង់ដារមជ្ឈមណ្ឌលសិក្សាសហគមន៍ នៅឆ្នាំ ២០១៦
- ផែនការការងាររបស់អនុក្រុមការងារបច្ចេកទេសអប់រំក្រៅប្រព័ន្ធត្រូវបានអនុម័តរៀងរាល់ឆ្នាំ
- រៀបចំសេចក្តីណែនាំស្តីពី ការរៀបចំប្រឡងដាច់ដោយឡែកសម្រាប់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ នៅឆ្នាំ ២០១៦
- កែសម្រួលសេចក្តីណែនាំស្តីពី ការគ្រប់គ្រងសាលាឯកជន នៅឆ្នាំ ២០១៤
- រៀបចំសេចក្តីណែនាំស្តីពី ការផ្តល់អាហារូបករណ៍ដល់អ្នកសិក្សាកម្មវិធីអប់រំក្រៅប្រព័ន្ធ នៅឆ្នាំ ២០១៤។

### ៣.៥.៤ យុទ្ធសាស្ត្រ

- ពង្រីកវិសាលភាពកម្មវិធីអក្ខរកម្ម ជាពិសេសតំបន់ដែលមានចំនួនអនក្ខរជនច្រើន និងតំបន់ជួបការលំបាក
- ពង្រីកនិងពង្រឹងដំណើរការរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ កម្មវិធីក្រោយអក្ខរកម្ម
- ពង្រឹងការគ្រប់គ្រងផ្អែកលើលទ្ធផលក្នុងអនុវិស័យអប់រំក្រៅប្រព័ន្ធ
- ផ្តល់យន្តការគាំទ្រការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ នៅតាមរោងចក្រ សហគ្រាស កសិដ្ឋាន
- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងគ្រឹះស្ថានសិក្សាឯកជន
- ពង្រឹងការប្រមូលព័ត៌មានទិន្នន័យ ស្ថិតិ ប្រជាជន និងអនក្ខរជនក្នុងភូមិ។

### ៣.៥.៥ សូចនាករផលសម្រេច (សាធារណៈនិងឯកជន)

- អត្រាអក្ខរកម្មមនុស្សពេញវ័យអាយុចាប់ពី ១៥-៤៥ ឆ្នាំ កើនពី ៨៧,០៥ ភាគរយ ដល់ ៩០,៥៥ ភាគរយ នៅឆ្នាំ ២០១៨
- ភាគរយប្រជាជនបានបញ្ចប់ថ្នាក់អក្ខរកម្មកើនដល់ ៨០ ភាគរយ នៅឆ្នាំ ២០១៨

- ចំនួនអ្នកសិក្សាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ កើនពី ៩០០០ នាក់ នៅឆ្នាំ ២០១៣ ដល់ ១២០០០ នាក់ នៅឆ្នាំ ២០១៨
- ភាគរយកុមារដែលបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញនិងបានបញ្ជូនទៅក្នុងប្រព័ន្ធវិញ កើនដល់ ៩៥ ភាគរយ នៅឆ្នាំ ២០១៨
- ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល កើនពី ៥០០០ នាក់ នៅឆ្នាំ ២០១៣ ដល់ ៧៣០០ នាក់ នៅឆ្នាំ ២០១៨
- រាជធានី ខេត្តទាំង ២៤ រៀបចំបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ នៅឆ្នាំ ២០១៤ និង រៀបចំរបាយការណ៍វិភាគប្រចាំឆ្នាំ នៅឆ្នាំ ២០១៧
- ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍កើនពី ៣៧១ ដល់ ៤៧១ និងបណ្ណាល័យកើនពី ៥៧ ដល់ ៧៣ នៅឆ្នាំ ២០១៨
- មជ្ឈមណ្ឌលសិក្សាសហគមន៍ ៣០ ភាគរយ មានស្តង់ដារ នៅឆ្នាំ ២០១៨។

### ៣.៥.៦ កម្មវិធីនិងសកម្មភាព

- ***កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ*** ៖ កែលម្អឯកសារបង្រៀននិងរៀន បំប៉នគ្រូ ផ្តល់សម្ភារៈ ជ្រើសរើសគ្រូកិច្ចសន្យា។ សាកល្បងវាស់វែងអក្ខរកម្មវិជ្ជាជីវៈ។ ផ្តល់ការអប់រំអក្ខរកម្មពីរភាសាសម្រាប់ជនជាតិដើមភាគតិច។
- ***កម្មវិធីក្រោយអក្ខរកម្ម*** ៖ ផ្តល់ថវិកាដំណើរការបណ្ណាល័យនិងមណ្ឌលអាន និងកសាងឯកសារក្រោយអក្ខរកម្ម។ សាកល្បងតេស្តថ្នាក់ក្រោយអក្ខរកម្មសម្រាប់អ្នកដែលបានបញ្ចប់ការសិក្សា។
- ***កម្មវិធីបំពេញវិជ្ជា*** ៖ ចេញវិញ្ញាបនបត្រ និងសញ្ញាបត្រ។
- ***កម្មវិធីចូលរៀនឡើងវិញ*** ៖ បង្កើនថវិកាឧបត្ថម្ភគ្រូ ផ្តល់ការគាំទ្រគណៈកម្មការប្រមូលសិស្ស ផ្តល់សម្ភារៈដំណើរការថ្នាក់ កែលម្អឯកសារបង្រៀននិងរៀន និងបំប៉នគ្រូ។
- ***កម្មវិធីសមមូល*** ៖ អភិវឌ្ឍកម្មវិធីសិក្សា ផ្សព្វផ្សាយ ផ្តល់សម្ភារៈ ជ្រើសរើសគ្រូកិច្ចសន្យា (សម្រាប់កម្រិតបឋមសិក្សា) ឧបត្ថម្ភប្រាក់ម៉ោង (សម្រាប់កម្រិតមធ្យមសិក្សា) និងបំប៉នគ្រូកម្មវិធីសមមូល។
- ***មជ្ឈមណ្ឌលសិក្សាសហគមន៍*** ៖ ផ្តល់ថវិកាដំណើរការ ជួលគ្រូជំនាញ ផ្តល់ថវិកាគាំទ្រគណៈកម្មការគ្រប់គ្រង។ សិក្សាពីតម្រូវការមុខជំនាញជារៀងរាល់ឆ្នាំ។ សាកល្បងផ្តល់ទុនសម្រាប់អ្នកបញ្ចប់ការសិក្សា។ រៀបចំបណ្តាញការងារនិងការសម្របសម្រួលក្នុងចំណោមអ្នកពាក់ព័ន្ធ។ អភិវឌ្ឍកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលជំនាញ។ ផ្សព្វផ្សាយសេចក្តីណែនាំនិងសៀវភៅប្រតិបត្តិមជ្ឈមណ្ឌលសិក្សាសហគមន៍។
- ***កម្មវិធីអភិវឌ្ឍសមត្ថភាពអប់រំក្រៅប្រព័ន្ធ*** ៖ តាមរយៈ ការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធ

និងសមត្ថភាពគ្រប់គ្រង និងការផ្តល់អាហារូបករណ៍ដល់អ្នកសិក្សា

- ***កម្មវិធីអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធ*** ៖ បំប៉នសមត្ថភាពមន្ត្រី និងអភិវឌ្ឍប្រព័ន្ធព័ត៌មានអប់រំក្រៅប្រព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- ***ការអភិវឌ្ឍសមត្ថភាពគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ*** ៖ ទស្សនកិច្ចសិក្សាលើកម្មវិធីអប់រំក្រៅប្រព័ន្ធ(ក្នុងនិងក្រៅខេត្ត)។ ពង្រីកប្រព័ន្ធផ្សព្វផ្សាយស្តីពីការងារអប់រំក្រៅប្រព័ន្ធ។ ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់អ្នកគ្រប់គ្រងបណ្ណាល័យអប់រំក្រៅប្រព័ន្ធ (កម្មវិធីក្រោយអក្ខរកម្ម)។ រៀបចំប្រជុំប្រចាំត្រីមាសសម្រាប់អ្នកគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍។ បំប៉នវិធីសាស្ត្របង្រៀនគ្រូនៅមជ្ឈមណ្ឌលសិក្សា សហគមន៍។ ប្រជុំគណៈកម្មការអប់រំក្រៅប្រព័ន្ធ និងអ្នកពាក់ព័ន្ធ។ ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដល់គ្រូកិច្ចសន្យា ក្នុងកម្មវិធីសមមូល។
- ***កម្មវិធីកែលម្អគុណភាពជីវិតរស់នៅ*** ៖ ដំណើរការរថយន្តចល័ត និងផ្សព្វផ្សាយការងារអប់រំក្រៅប្រព័ន្ធ ផ្តល់ការអប់រំអំពីសុខភាពបន្តពូជ សុខភាពផ្លូវភេទ រួមបញ្ចូលទាំងការអប់រំ បង្ការជំងឺអេដស៍ គ្រឿងញៀន ការអប់រំសុខភាពអនាម័យ សុវត្ថិភាពចំណីអាហារ អាហារូបត្ថម្ភ បារី គ្រឿងស្រវឹង ការអប់រំបង្ការជំងឺមិនឆ្លងនិងជំងឺឆ្លង ព្រមទាំងគ្រោះថ្នាក់ផ្សេងៗទៅក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ។
- ***ផ្តល់អាហារូបករណ៍ជាថវិកានិងអាហារដល់អ្នករៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ*** ៖ ផ្តល់ឱកាសនិងលើកទឹកចិត្តដល់អ្នកដែលស្វែងរកចំណេះដឹង និងជំនាញមុខរបរ។

- ***ការអភិវឌ្ឍសម្ភារូបវន្ត*** ៖ សាងសង់ និងបំពាក់សម្ភារៈមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងស្នូឪយោ រួមបញ្ចូលទាំងការបំពាក់សម្ភារៈអនាម័យ ទឹកស្អាត និងកន្លែងលាងសម្អាតដៃ ។

## ៣.៦ អនុវិស័យ ការអភិវឌ្ឍយុវជន

### ៣.៦.១ សាវតារ

ព្រះរាជាណាចក្រកម្ពុជាចាត់ទុកយុវជនជាធនធានគន្លឹះ និងមានតម្លៃបំផុតសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន និងការរក្សាសន្តិភាព ទាំងបច្ចុប្បន្ន ទាំងអនាគត។ នៅក្នុងបរិបទសង្គម វប្បធម៌ និងនយោបាយរបស់កម្ពុជា "យុវជន" ជាបុរសនិងស្ត្រីដែលមានសញ្ជាតិខ្មែរពីអាយុ ១៥ ដល់ ៣០ ឆ្នាំ នៅលីវឬរៀបការហើយ។ យោងតាមជំរឿនប្រជាជនរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ យុវជនមាន ៣៣ ភាគរយនៃចំនួនប្រជាជនសរុប។

ព្រះរាជក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន និងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ត្រូវបានអនុម័តនិងកំពុងបន្តរៀបចំផែនការសកម្មភាពជាតិស្តីពី ការអភិវឌ្ឍយុវជនកម្ពុជា។

ក្រសួងបានរៀបចំក្រុមប្រឹក្សាយុវជននិងកុមារនៅតាមសាលារៀនចំណោះទូទៅ ក្នុងនោះក្រុមប្រឹក្សាកុមារ ៦៩៧៨ មានសមាជិក ១៩៦១០២៧ នាក់ ស្រី ៤៩ ភាគរយ នៃចំនួនកុមារពីថ្នាក់ទី៤ ដល់ទី៩ និងក្រុមប្រឹក្សាយុវជន ៨១៦ មានសមាជិក ២៧៤៩៧៤ នាក់ ស្រី ៤៩ ភាគរយ នៃចំនួនយុវជនពីថ្នាក់ទី១០ ដល់ទី១២។

មជ្ឈមណ្ឌលយុវជននៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៩ បានដំណើរការ និងបានសម្របសម្រួលវគ្គបណ្តុះបណ្តាលជំនាញខ្លីៗលើមុខវិជ្ជាកាត់ដេរ ចម្លាក់ថ្មកែវ បណ្តុះផ្សិត ភ្លេងខ្មែរ អក្សរភ្លេង ជួសជុលទូរស័ព្ទដៃ និងកុំព្យូទ័រ មានសិក្ខាកាម ១១៩៥នាក់ ស្រី ៦១,៥ ភាគរយ។

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើយុវជន ដែលជាសសរទ្រូងប្រទេសជាតិដោយផ្តល់ការសិក្សាប្រកបដោយគុណភាព និងមានសមត្ថភាពអាចឈានចូលទៅក្នុងទីផ្សារការងារដោយងាយស្រួល។ ក្នុងនោះ ក៏នៅមានយុវជនមួយចំនួនពុំទាន់មានឱកាសទទួលបានការងារសមស្របនៅឡើយ។ រីឯយុវជនដែលមានចំណេះដឹងតិចតួច (ចំណេះដឹង និងបំណិនក្នុងការគិត) បានទទួលកម្រៃទាប ក្នុងនោះ ស្ត្រីមិនសូវទទួលបានការងារធ្វើដោយកម្រៃខ្ពស់នៅឡើយ។ លើសពីនេះ ពួកគេបានប្រឈមមុខនឹងការលំបាក ឬធ្លាក់ចូលក្នុងស្ថានភាពងាយរងគ្រោះ ដែលរួមមានការបោះបង់ការសិក្សា ការបាត់បង់ជម្រើសរបស់ខ្លួន ការសេពគ្រឿងញៀន ការសេពគ្រឿងស្រវឹង និងគ្រោះថ្នាក់នៅតាមកន្លែងធ្វើការ។ល។

### ៣.៦.២ វត្ថុបំណងគោលនយោបាយ

- ផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាពនិងសមធម៌
- អភិវឌ្ឍយុវជនឱ្យមានសុខភាពល្អផ្នែកផ្លូវកាយ និងផ្លូវចិត្ត

- លើកទឹកចិត្តយុវជនឱ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី ស្មារតីសហគ្រិនភាព និងភាពជាអ្នកដឹកនាំ។

### ៣.៦.៣ សកម្មភាពគោលនយោបាយ

- រៀបចំផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា នៅឆ្នាំ ២០១៤
- រៀបចំក្រុមប្រឹក្សាជាតិដើម្បីអភិវឌ្ឍយុវជននិងក្រុមប្រឹក្សាអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្រុក ខណ្ឌ នៅឆ្នាំ ២០១៤
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ក្រុមប្រឹក្សាជាតិដើម្បីអភិវឌ្ឍយុវជន នៅឆ្នាំ ២០១៤
- រៀបចំយន្តការសម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃការអនុវត្ត នៅឆ្នាំ ២០១៤
- រៀបចំលិខិតបទដ្ឋានស្តីពីការពង្រឹងយន្តការក្រុមប្រឹក្សាកុមារនិងយុវជននិងរៀបចំឯកសារពាក់ព័ន្ធ នៅឆ្នាំ ២០១៤
- រៀបចំ សេវាតម្រង់ទិសវិជ្ជាជីវៈនិងតម្រង់ទិសការសិក្សា នៅឆ្នាំ ២០១៤
- រៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌលយុវជន នៅឆ្នាំ ២០១៤
- កែសម្រួលសេចក្តីណែនាំស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលយុវជន នៅឆ្នាំ ២០១៤
- រៀបចំផែនការស្តីពីការចូលរួមរបស់យុវជនក្នុងសកម្មភាពស្ម័គ្រចិត្ត នៅឆ្នាំ ២០១៤
- រៀបចំនិយាមអប្បបរមាសម្រាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ នៅឆ្នាំ ២០១៥
- រៀបចំផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍចលនាកាយរឹទ្ធិជាតិកម្ពុជា នៅឆ្នាំ ២០១៤។

### ៣.៦.៤ យុទ្ធសាស្ត្រ

- អភិវឌ្ឍក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋាន និងយន្តការ
- លើកកម្ពស់ការបណ្តុះបណ្តាលជំនាញ និងការអភិឌ្ឍសមត្ថភាព
- បង្កើនការអប់រំជំនាញទន់ ស្មារតីសហគ្រិនភាព និងភាពជាអ្នកដឹកនាំដល់យុវជន
- លើកកម្ពស់ការចូលរួមលេងកីឡារបស់យុវជន
- លើកកម្ពស់ការយល់ដឹងរបស់យុវជនពីសិល្បៈ វប្បធម៌ បរិស្ថាន កសិកម្ម ទេសចរណ៍របស់ជាតិ និងតំបន់
- លើកកម្ពស់ការងារស្ម័គ្រចិត្តរបស់យុវជន
- លើកកម្ពស់ការអប់រំបំណិនជីវិតស្តីពីសុវត្ថិភាពសង្គម និងបុគ្គល។

### ៣.៦.៥ សូចនាករផលសម្រេច (សាធារណៈនិងឯកជន)

- ចំនួនយុវជនដែលទទួលបានការបណ្តុះបណ្តាលជំនាញខ្លីៗ កើនពី ២៧០០ នាក់នៅឆ្នាំ ២០១៣ ដល់ ៣៣០០ នាក់ នៅឆ្នាំ ២០១៨
- ចំនួនយុវជនដែលបានទទួលការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងសហគ្រិនភាព ៣០០ នាក់ក្នុង ១ ឆ្នាំ
- ចំនួនយុវជនដែលបានបង្កើតការងារដោយខ្លួនឯង ១០ នាក់ក្នុងមួយមជ្ឈមណ្ឌលក្នុងមួយឆ្នាំ
- ចំនួនយុវជនដែលទទួលការបណ្តុះបណ្តាលពីការងារស្ម័គ្រចិត្ត កើនពី ២៥០០ នាក់ នៅឆ្នាំ ២០១៣ ដល់ ៣៦០០ នាក់ នៅឆ្នាំ ២០១៨
- ចំនួនមជ្ឈមណ្ឌលយុវជន កើនពី ៩ នៅឆ្នាំ ២០១៣ ដល់ ២៤ នៅឆ្នាំ ២០១៨
- សិស្សពីថ្នាក់ទី ៤ ដល់ទី ៩ បានចូលរួមក្នុងក្រុមប្រឹក្សាកុមារ ១០០ ភាគរយ នៅឆ្នាំ ២០១៨
- សិស្សពីថ្នាក់ទី ១០ ដល់ទី ១២ បានចូលរួមក្នុងក្រុមប្រឹក្សាយុវជន ១០០ ភាគរយ នៅឆ្នាំ ២០១៨។

### ៣.៦.៦ កម្មវិធីនិងសកម្មភាព

- ***កម្មវិធីផ្តល់ជំនាញបច្ចេកទេស ៖***
    - ការអភិវឌ្ឍសម្ភារៈរូបវន្ត ៖ ជួសជុល បំពាក់ឧបករណ៍សម្ភារៈ និងសាងសង់ មជ្ឈមណ្ឌលយុវជន។
    - ការបណ្តុះបណ្តាលជំនាញ ៖ តាមរយៈមជ្ឈមណ្ឌលយុវជនរាជធានី ខេត្ត និងការសម្របសម្រួលជាមួយនឹងកម្មវិធីអប់រំក្រៅប្រព័ន្ធ។
        - បណ្តុះបណ្តាលជំនាញខ្លីៗដូចជា ៖ ភាសាបរទេស កុំព្យូទ័រ បច្ចេកវិទ្យាសារគមនាគមន៍និងព័ត៌មាន ជំនាញផ្នែកព័ត៌មាន កសិកម្ម សិប្បកម្ម ភាពជាអ្នកដឹកនាំ សហគ្រិនភាព ។ល។
        - កម្មវិធីអប់រំយុវជនបាត់បង់ឱកាស ៖ ការអប់រំអក្សរ លេខនព្វន្ត និងជំនាញដែលផ្សារភ្ជាប់ នឹងការរស់នៅជាក់ស្តែង ដល់យុវជនដែលជា អនក្ខរជន និងយុវជនបាត់បង់ឱកាស។
        - កម្មវិធីហាត់ការនៅតាមសហគ្រាសរដ្ឋនិងឯកជន ៖ សម្របសម្រួលការចុះកម្មសិក្សាដល់យុវជនដែលទទួលបានការបណ្តុះបណ្តាល។
        - កម្មវិធីផ្តល់ព័ត៌មានអំពីមុខរបរនិងការងារ ៖ សម្របសម្រួលការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីផ្តល់ព័ត៌មានដល់យុវជន។

▪ កម្មវិធីគាំទ្រការបង្កើតមុខរបរដោយខ្លួនឯង ៖ ការផ្តល់ការប្រឹក្សា និងដើមទុនសម្រាប់ការបង្កើតមុខរបរ។

- ***កម្មវិធីអភិវឌ្ឍជំនាញទន់*** ៖
  - ការងារក្លឹបសិក្សារបស់ក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជន ៖ គណិតវិទ្យា ភាសាខ្មែរ បំណិនជីវិត ស្វ័យសិក្សា។ល។
  - កម្មវិធីបោះជំរំ ៖ ការងារជាក្រុម ភាពជាអ្នកដឹកនាំ ផ្លាស់ប្តូរបទពិសោធ ចែករំលែកចំណេះដឹងពីគ្នាទៅវិញទៅមក ការរុករក ជំនាញហានលេខា ការងារសហគមន៍ ភាពជាម្ចាស់ផ្ទាល់ខ្លួន ការងារបរិស្ថាន និងការរស់នៅជាមួយធម្មជាតិ។ល។
  - កម្មវិធីទស្សនកិច្ចសិក្សា ៖ ផ្លាស់ប្តូរបទពិសោធ ចែករំលែកចំណេះដឹងពីគ្នាទៅវិញទៅមក ស្វែងយល់ពីវប្បធម៌ អរិយធម៌ ទំនៀមទំលាប់ប្រពៃណីជាតិ។
  - កម្មវិធីអភិវឌ្ឍចលនាកាយរឹទ្ធិ ៖ រៀនដោយការអនុវត្តជាក់ស្តែងនិងស្វ័យអភិវឌ្ឍដូចជាការបណ្តុះគំនិតចូលរួមក្នុងការងារសង្គម ការងារជាក្រុម ការរស់នៅជាក្រុម អភិវឌ្ឍបំណិន ការសង្គ្រោះបឋម និងការងារមនុស្សធម៌ ។ល។
- ***ការងារក្រុមប្រឹក្សាយុវជននិងកុមារ*** ៖ ផ្សព្វផ្សាយការយល់ដឹងពីមុខរបរនិងអប់រំបច្ចេកទេសវិជ្ជាជីវៈ ការបណ្តុះគំនិតលេងកីឡានិងអប់រំកាយសិក្សា ការបង្កើតសហករណ៍សិស្សក្នុងសាលារៀន ការរៀបចំកម្មវិធីសម្រាប់អនុវត្តការងារបីល្អ និងការបញ្ជ្រាបសហគ្រិនភាព។
- ***កម្មវិធីមិត្តអប់រំមិត្ត*** ៖ ការយល់ដឹងអំពីជំងឺអេដស៍ សុខភាពបន្តពូជ សុខភាពអនាម័យ សុខភាពគ្រួសារ ការយល់ដឹងពីគ្រឿងញៀន កាត់បន្ថយគ្រោះថ្នាក់ចរាចរ ។ល។
- ***កម្មវិធីយុវជនស្ម័គ្រចិត្ត*** ៖ បណ្តុះបណ្តាល និងបញ្ជ្រាបស្មារតីស្ម័គ្រចិត្ត ការងារស្ម័គ្រចិត្ត និងការបង្កើតបណ្តាញយុវជនស្ម័គ្រចិត្ត ។ល។
- ***ការពង្រឹងសកម្មភាពសមាគមនិស្សិត*** ៖ ការបង្កើតវេទិកាការងាររវាងយុវជននិងសហគ្រាស ការបញ្ជ្រាបសហគ្រិនភាព លើកកម្ពស់ការអប់រំបច្ចេកវិទ្យាព័ត៌មានវិទ្យា វិទ្យាសាស្ត្រ វប្បធម៌ និងកីឡា លើកកម្ពស់ការយល់ដឹង និងត្រៀមសម្រាប់សមាហរណកម្មអាស៊ាន ២០១៥ កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ និងកសាងបណ្តាញយុវជន ។

## ៣.៧ អនុវិស័យ ការអប់រំកាយនិងកីឡា

### ៣.៧.១ សារវិតារ

អប់រំកាយនិងកីឡាជាសមាសធាតុសំខាន់មួយរបស់វិស័យអប់រំ ក្នុងការលើកកម្ពស់សុខភាព រួមចំណែកជំរុញការសិក្សានិងការអភិវឌ្ឍប្រទេសជាតិ។

ក្រសួងបានរៀបចំសេចក្តីណែនាំស្តីពី ការហាត់អប់រំកាយនិងកីឡាក្នុងម៉ោងនិងក្រៅម៉ោងសិក្សា ការប្រកួតកីឡាថ្នាក់រាជធានី ខេត្ត ការប្រកួតជើងឯកទូទាំងប្រទេសគ្រប់ភូមិសិក្សា ការប្រកួតកីឡាមហាជនរាជធានី ខេត្ត ថ្នាក់ភូមិភាគ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ កសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡាក្នុងនិងក្រៅសាលារៀន និងបណ្តុះបណ្តាលធនធានមនុស្សឯកទេសអប់រំកាយនិងកីឡា។

ការអភិវឌ្ឍការងារអប់រំកាយនិងកីឡាសំដៅរួមចំណែកលើកកម្ពស់សុខុមាលភាពប្រជាជន ពង្រឹងសាមគ្គីភាព កីឡាកម្រិតខ្ពស់ និងត្រៀមលក្ខណៈសម្បត្តិឱ្យបានល្អ ដើម្បីចូលរួមនិងរៀបចំព្រឹត្តិការណ៍កីឡាធំៗជាលក្ខណៈអន្តរជាតិនានា។

បញ្ហាប្រឈមចំពោះមុខមានដូចជា កង្វះខាតធនធានមនុស្សលើការងារគ្រប់គ្រង ដឹកនាំ និងចូលរួមរៀបចំសម្រាប់ការប្រកួតជាលក្ខណៈជាតិនិងអន្តរជាតិ។ កង្វះខាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ឧបករណ៍ និងសម្ភារកីឡា សម្រាប់បម្រើឱ្យការហាត់ហ្វឹកហ្វឺននិងការប្រកួតជាលក្ខណៈជាតិនិងអន្តរជាតិ កង្វះខាតឯកសារ លិខិតបទដ្ឋានគតិយុត្តិក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា។ រចនាសម្ព័ន្ធនៃការប្រកួតមិនទាន់បានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនិងបរិបទនៃការប្រកួតកីឡានៅក្នុងតំបន់។ ការអនុវត្តសកម្មភាពអប់រំកាយនិងកីឡានៅតាមគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន មិនទាន់បានពេញលេញ និងល្អប្រសើរនៅឡើយ។ ជាទូទៅ ការចូលរួមរបស់កីឡាករកម្ពុជាក្នុងការប្រកួតនៅលើឆាកអន្តរជាតិមិនទាន់ទទួលបានលទ្ធផលល្អប្រសើរនៅឡើយ។

### ៣.៧.២ វត្ថុបំណងគោលនយោបាយ

- លើកកម្ពស់សិទ្ធិ ផ្តល់ឱកាស និងបណ្តុះបណ្តាលវប្បធម៌អប់រំកាយនិងកីឡាដល់ប្រជាជនគ្រប់រូប
- បង្កើនសិទ្ធផលកីឡាករ កីឡាការិនី ដើម្បីដណ្តើមយកជ័យជំនះក្នុងការប្រកួតកីឡាអន្តរជាតិនានា
- លើកកម្ពស់អភិបាលកិច្ចនិងការគ្រប់គ្រងក្នុងការអប់រំកាយនិងកីឡា។

### ៣.៧.៣ សកម្មភាពគោលនយោបាយ

- រៀបចំសេចក្តីណែនាំស្តីពី ការរៀបចំទីធ្លាសម្រាប់ការងារអប់រំកាយនិងកីឡា នៅឆ្នាំ ២០១៤
- រៀបចំសេចក្តីណែនាំស្តីពី ការងារបច្ចេកទេសអប់រំកាយនិងកីឡា នៅឆ្នាំ ២០១៤
- រៀបចំសេចក្តីណែនាំស្តីពី ការហាត់អប់រំកាយនិងកីឡានៅក្នុងម៉ោងសិក្សានិងក្រៅម៉ោងសិក្សា នៅឆ្នាំ ២០១៤

- រៀបចំសេចក្តីណែនាំស្តីពីការប្រកួតកីឡានៅតាមគ្រឹះស្ថានសិក្សា នៅឆ្នាំ ២០១៤
- រៀបចំគោលនយោបាយកីឡាជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា នៅឆ្នាំ ២០១៤
- រៀបចំច្បាប់ស្តីពីការគ្រប់គ្រងវិស័យកីឡាជាតិ នៅឆ្នាំ ២០១៦
- រៀបចំផែនការគោលស្តីពីការអភិវឌ្ឍកីឡាឆ្ពោះទៅឆ្នាំ ២០២៣ នៅឆ្នាំ ២០១៤
- រៀបចំលិខិតបទដ្ឋានគតិយុត្តិស្តីពីការផ្ទេរមុខងារអប់រំកាយនិងកីឡាដល់ថ្នាក់ក្រោមជាតិ នៅឆ្នាំ ២០១៥
- រៀបចំសេចក្តីណែនាំស្តីពីការការពារតម្លៃសីលធមិនិងវិជ្ជាជីវៈ ក្នុងការធ្វើសកម្មភាពអប់រំកាយនិងកីឡា នៅឆ្នាំ ២០១៥
- កែលម្អសេចក្តីណែនាំស្តីពីការចងក្រងក្លិប សមាគម សហព័ន្ធកីឡា នៅឆ្នាំ ២០១៥
- រៀបចំសេចក្តីណែនាំស្តីពីវិមជ្ឈការការងារកីឡាដល់សហព័ន្ធកីឡាជាតិ នៅឆ្នាំ ២០១៥។

### ៣.៧.៤ យុទ្ធសាស្ត្រ

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បំពាក់ឧបករណ៍ និងសម្ភារៈកីឡា
- ស្រាវជ្រាវនិងចងក្រងឯកសារស្តីពីការអប់រំកាយនិងកីឡា
- ពង្រឹងការផ្សព្វផ្សាយព័ត៌មានកីឡា
- លើកកម្ពស់តម្លៃសីលធមិ និងវិជ្ជាជីវៈអប់រំកាយនិងកីឡាសម្រាប់ទាំងអស់គ្នា
- ពង្រឹងសហប្រតិបត្តិការការងារកីឡាទាំងអង្គការសង្គមកីឡាជាតិ និងអន្តរជាតិ
- លើកកម្ពស់ការបណ្តុះបណ្តាល ការហាត់ហ្វឹកហ្វឺន និងការអភិវឌ្ឍសមត្ថភាព
- អភិវឌ្ឍក្របខណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្តិ និងយន្តការ។

### ៣.៧.៥ សូចនាករផលសម្រេច (សាធារណៈនិងឯកជន)

- ចំនួនគ្រូអប់រំកាយនិងកីឡាបណ្តុះបណ្តាលក្នុងមួយឆ្នាំ ១៥០ នាក់
- ទីលានកីឡាចំនួន ៤ (ពហុកីឡាដ្ឋានជាតិ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា កីឡដ្ឋានខេត្តសៀមរាប) ត្រូវបានកែលម្អ នៅត្រឹមឆ្នាំ ២០១៨
- គ្រឹះស្ថានមធ្យមសិក្សាចំនួន ១០ មានទីលានបាល់ទាត់ ១៥ មានទីលានបាល់បោះ និង ២០ មានទីលានបាល់ទះ នៅត្រឹម ២០១៨
- ចំនួនមេដាយមាសក្នុងការប្រកួតកីឡាស៊ីហ្គេម កើនពី ៤ ដល់ ២០ នៅឆ្នាំ ២០១៨។

### ៣.៧.៦ កម្មវិធីនិងសកម្មភាព

- ***ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បំពាក់ឧបករណ៍ និងសម្ភារៈកីឡា*** ៖ ជួសជុលនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តកីឡា បំពាក់ឧបករណ៍ និងសម្ភារៈកីឡានៅតាមគ្រឹះស្ថានសិក្សា និងនៅតាមរាជធានី ខេត្ត។
- ***ការអភិវឌ្ឍឯកសារនិងកម្មវិធីសិក្សាអប់រំកាយនិងកីឡា*** ៖
    - **ការងារកីឡាក្នុងគ្រឹះស្ថានសិក្សា** ៖ រៀបចំ ស្រាវជ្រាវ និងចងក្រងសៀវភៅ ឯកសារ និងកម្មវិធីសិក្សាអប់រំកាយនិងកីឡាសម្រាប់សិស្សនិងគ្រូ នៅតាមគ្រឹះស្ថានសិក្សា។ សៀវភៅសម្រាប់គ្រូនៅសាលាគរុកោសល្យនិងវិក្រឹតការរាជធានី ខេត្ត មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។
    - **ការងារកីឡាសម្រាប់ទាំងអស់គ្នា** ៖ រៀបចំ ស្រាវជ្រាវ ចងក្រងឯកសារស្តីពីបទបញ្ញាសម្រាប់ការប្រកួតកីឡាគ្រប់ប្រភេទ ឯកសារស្តីពីការហាត់ប្រាណដើម្បីសុខភាព និងចងក្រងឯកសារកីឡាប្រពៃណីជាតិ។
    - **ការងារកីឡាកម្រិតខ្ពស់** ៖ រៀបចំ ស្រាវជ្រាវ និងចងក្រងឯកសារវិទ្យាសាស្ត្រកីឡាសម្រាប់ហាត់និងបង្ហាត់ក្រុមជម្រើសជាតិ និងដំណើរការបណ្ណាល័យកីឡា។
    - **ការងារបណ្តុះបណ្តាលគ្រូ** ៖ រៀបចំ ស្រាវជ្រាវ និងចងក្រងសៀវភៅសម្រាប់គ្រូអប់រំកាយនិងកីឡា និងកម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយនិងកីឡា។
- ***ការផ្សព្វផ្សាយព័ត៌មានកីឡា*** ៖ ផលិតទស្សនាវដ្តីកីឡា បង្កើតវេបសាយកីឡា កម្មវិធីផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មាន និងប្រារព្ធទិវាអប់រំកាយនិងកីឡាប្រចាំឆ្នាំ។
- ***កិច្ចសហប្រតិបត្តិការ*** ៖
    - **ថ្នាក់ជាតិ** ៖ សហការជាមួយអង្គការសង្គមកីឡាក្នុងការបណ្តុះបណ្តាលថ្នាល គ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រម មន្ត្រីបង្គោល មន្ត្រីរដ្ឋបាលនិងបច្ចេកទេសក្នុងនិងក្រៅប្រទេស និងការប្រកួតកីឡាក្នុងនិងក្រៅប្រទេស។
    - **អន្តរជាតិ** ៖ ចុះអនុស្សារណៈយោគយល់ បញ្ជូនកីឡាករ កីឡាការិនី និងមន្ត្រីទៅបណ្តុះបណ្តាលក្រៅប្រទេស ការចែករំលែកបទពិសោធ និងព័ត៌មានវិទ្យាសាស្ត្រកីឡា។ ទទួលយកគ្រូបង្វឹកបរទេសមកបង្ហាត់កីឡាករ កីឡាការិនីជម្រើសជាតិកម្ពុជា
- ***ការបណ្តុះបណ្តាល ការហាត់ហ្វឹកហ្វឺន និងការអភិវឌ្ឍសមត្ថភាព*** ៖
    - បំប៉នការងារអប់រំកាយនិងកីឡាតាមគ្រឹះស្ថានសិក្សា ៖ បំប៉នគ្រូទទួលបន្ទុកអប់រំកាយនិងកីឡា ។

- បណ្តុះបណ្តាលគ្រូឯកទេសអប់រំកាយនិងកីឡា៖ បំប៉ននិងបណ្តុះបណ្តាលគ្រូឯកទេសអប់រំកាយនិងកីឡា។
- បំប៉នសមត្ថភាពមន្ត្រីជំនាញកីឡា ៖ បំប៉នសមត្ថភាពគ្រូបង្គោលអប់រំកាយនិងកីឡា មន្ត្រីរដ្ឋបាល មន្ត្រីគ្រប់គ្រង មន្ត្រីបច្ចេកទេស ក្នុងនិងក្រៅប្រទេស។
- អភិវឌ្ឍកីឡាកម្រិតខ្ពស់ ៖ បណ្តុះបណ្តាលកីឡាករ កីឡាការិនីកម្រិតខ្ពស់ឱ្យមានសិទ្ធផលខ្ពស់ និងមន្ត្រីជំនាញផ្សេងៗឱ្យឆ្លើយតបទៅនឹងតម្រូវការក្នុងតំបន់។

# ជំពូកទី ៤

# ផែនការហិរញ្ញប្បទាន

# ២០១៤-២០១៨

## ៤.១ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ៤.១.១ សាវតារ

អំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈវិស័យអប់រំមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ស្របនឹងបរិបទនៃកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ វឌ្ឍនភាពសំខាន់ៗរួមមាន ការរៀបចំផែនការសកម្មភាពរបស់ក្រសួងស្តីពីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ ការបណ្តុះបណ្តាលស្តីពីការធ្វើចំណាត់ថ្នាក់ថវិកា និងការកត់ត្រាចំណាយ ដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និង សាលារៀនទាំងអស់។ ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ អចលនទ្រព្យ ដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និង សាលារៀន ដែលបានជ្រើសរើស។

ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំនៅថ្នាក់ជាតិនិងនៅថ្នាក់រាជធានី ខេត្ត និងបន្តកែលម្អខ្លឹមសារនិងដំណើរការរៀបចំ។ ថវិកាកម្មវិធីមានប្រសិទ្ធភាពក្នុងការផ្សារភ្ជាប់ការប្រើប្រាស់ធនធានថវិកាទៅនឹងលទ្ធផល។ ក្រសួងអប់រំ យុវជន និងកីឡាទទួលបានការឯកភាពក្នុងការបង្កើនថវិកាកម្មវិធី តាមរយៈការរៀបចំប្រកាសលេខ ៥០៨ ។

ក្នុងជំហានទី ៣ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានលើកឡើងពីការលើកកម្ពស់ទំនាក់ទំនងរវាងថវិកា និង គោលនយោបាយ និង គណនេយ្យភាពក្នុងការអនុវត្ត តាមរយៈការពង្រឹង និងពង្រីកវិសាលភាពនៃការរៀបចំថវិកាកម្មវិធី និងកែលម្អការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងកែលម្អការប្រើប្រាស់ថវិកានិងការគ្រប់គ្រងសាច់ប្រាក់។

កន្លងមក ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យអប់រំមានបញ្ហាប្រឈមមួយចំនួនដូចជា ៖ ការផ្សារភ្ជាប់រវាងថវិកានិងគោលនយោបាយនៅទន់ខ្សោយ ថវិកាចំណាយលើវិស័យអប់រំនៅទាបជាងប្រទេសជិតខាង ថវិកាប្រចាំឆ្នាំមួយចំនួនមិនបានប្រើប្រាស់អស់ និងដំណើរការរបស់ប្រព័ន្ធមិនមានទំនាក់ទំនងគ្នាល្អទាំងខ្សែរយៈបណ្តោយនិងខ្សែទទឹង។

ក្នុងឆ្នាំ ២០១៤ ចំណាយសាធារណៈសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា មានប្រមាណ ១៣៤២ ពាន់លានរៀល ( ៣៣៥ លានដុល្លារ) ត្រូវជា ១៦.២ ភាគរយនៃថវិកាចំណាយចរន្តរបស់រាជរដ្ឋាភិបាល។ ចំណាយសម្រាប់បៀវត្សមានប្រមាណ ៧៥ ភាគរយនៃចំណាយចរន្តសរុប។ ថវិកាកម្មវិធីមានប្រមាណ ១៧២ ពាន់លានរៀល ត្រូវជា ១៣ ភាគរយនៃថវិកាចរន្ត។ ផ្អែកលើភាគរយនៃការចំណាយនៅឆ្នាំ ២០១២ ថវិកា ៨២ ភាគរយនៃថវិកាអប់រំត្រូវបានផ្តល់ដល់រាជធានី ខេត្ត និង ១៨ ភាគរយទៀតត្រូវបានប្រើប្រាស់នៅថ្នាក់ជាតិ។

ក្នុងឆ្នាំ ២០១៤ ដើម្បីកែលម្អយន្តការនានា ជាពិសេសក្នុងបរិបទនៃការគ្រប់គ្រងកម្មវិធីតាមបែបអនុវិស័យ និងផ្តោតលើលទ្ធផល ក្រសួងអប់រំ យុវជន និងកីឡានឹងគាំទ្រយ៉ាងខ្លាំងក្លានូវរាល់ការអនុវត្តសាកល្បង និងការដាក់ឱ្យអនុវត្តកំណែទម្រង់នានា សំដៅកសាងប្រព័ន្ធនិងអភិវឌ្ឍសមត្ថភាពដើម្បីឱ្យមានការរីកចម្រើនសម្រាប់រយៈពេលមធ្យមនិងរយៈពេលវែង។ កំណែទម្រង់ទាំងនោះរួមមានការគ្រោងថវិកាតាមអនុវិស័យ ដោយផ្តោតលើលទ្ធផលនិងផ្តោតលើកម្មវិធីវិនិយោគជាអាទិភាព។ ការធានាភាពជឿជាក់និងទាន់ពេលនៃការដកសាច់ប្រាក់សម្រាប់ការអនុវត្តតាមរយៈអង្គភាពថវិកា ការធ្វើវិមជ្ឈការថវិកាតាមរយៈការផ្ទេរមុខងារទៅឱ្យអាជ្ញាធរថ្នាក់មូលដ្ឋាន ការពិនិត្យតាមដានការអនុវត្តថវិកាប្រចាំត្រីមាសដើម្បីងាយស្រួលកែសម្រួលថវិកា ការពិនិត្យឡើងវិញកម្រិតប្រាក់បៀវត្សសម្រាប់អ្នកគ្រប់គ្រង និងមន្ត្រីរដ្ឋបាល ព្រមទាំងកសាងសមត្ថភាពមន្ត្រីអប់រំថ្នាក់ក្រុង ស្រុក ខណ្ឌ។ ការពិនិត្យឡើងវិញយន្តការគ្រប់គ្រងហិរញ្ញវត្ថុ និងតម្លៃឯកតានៅក្នុងថវិកាដំណើរការសាលារៀន។

### ៤.១.២ វត្ថុបំណងគោលនយោបាយ

- ធានាធនធានគ្រប់គ្រាន់ ដើម្បីអនុវត្តឱ្យបានពេញលេញផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- ធានាផលសម្រេចរបស់កម្មវិធីត្រូវបានផ្សារភ្ជាប់ទៅនឹងការប្រើប្រាស់ដោយប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធនៃធនធានដែលមាន
- ធានាថាសេវាអប់រំត្រូវបានផ្តល់គ្រប់គ្រាន់និងមានគុណភាពខ្ពស់។

### ៤.១.៣ យុទ្ធសាស្ត្រ

- ពង្រឹងទំនាក់ទំនងរវាងគោលនយោបាយនិងថវិកា តាមរយៈពង្រឹងការរៀបចំផែនការថវិកាផ្អែកលើលទ្ធផលនៅគ្រប់កម្រិត
- បង្កើនប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធនៅក្នុងគណនេយ្យភាពហិរញ្ញវត្ថុ និងដំណើរការគ្រប់គ្រង
- ពង្រឹងមូលដ្ឋានសម្រាប់ព្យាករណ៍និងប្រើប្រាស់ថវិកាអប់រំ តាមរយៈការពង្រីកវិសាលភាពនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុតាមប្រព័ន្ធកុំព្យូទ័រនៅគ្រប់កម្រិត
- ពង្រឹងយន្តការកសាងផែនការថវិកា និងប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុ។

### ៤.១.៤ សកម្មភាពគោលនយោបាយ

- ដាក់បញ្ចូលរាល់សកម្មភាពគាំទ្រដោយថវិកា នៅឆ្នាំ ២០១៥
- អង្គភាពថវិកានឹងត្រូវរៀបចំនៅតាមនាយកដ្ឋានជំនាញទាំងអស់ នៅឆ្នាំ ២០១៦
- សាកល្បងអនុវត្តនីតិវិធីសវនកម្មតាមថវិកាកម្មវិធីនៅឆ្នាំ២០១៤ និងអនុវត្តពេញលេញនៅឆ្នាំ ២០១៥

- ដាក់ឱ្យប្រើប្រាស់សៀវភៅនីតិវិធីអធិការកិច្ចនៅឆ្នាំ ២០១៤។

### ៤.១.៥ សូចនាករផលសម្រេច

- ការបញ្ចូលការកសាងផែនការផ្អែកលើលទ្ធផលទៅក្នុងការពិនិត្យឡើងវិញផែនការសកម្មភាពរបស់ក្រសួង និងនៅក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ
- ថវិកាគួរឱ្យជឿទុកចិត្តនិងប្រាកដនិយមប្រចាំឆ្នាំ ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំដែលបានអនុម័ត
- ចំណាយថវិកាឱ្យនៅសល់កម្រិតអប្បបរមា
- របាយការណ៍ហិរញ្ញវត្ថុត្រូវធ្វើឡើងឱ្យបានទាន់ពេលវេលា និងរួមបញ្ចូលនូវព័ត៌មាននិងការវិភាគសម្រាប់ធ្វើសេចក្តីសម្រេចលើការងារគ្រប់គ្រង។

### ៤.១.៦ កម្មវិធីនិងសកម្មភាព

- ***ការអភិវឌ្ឍសមត្ថភាពការងារគ្រប់គ្រងផែនការហិរញ្ញវត្ថុ*** ៖ កសាងសមត្ថភាពលើការធ្វើផែនការថវិកាផ្អែកលើលទ្ធផល ដំណើរការប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ បង្កើនការចូលរួមរបស់នាយកដ្ឋានហិរញ្ញវត្ថុនៅក្នុងដំណើរការរៀបចំថវិការបស់ថ្នាក់ក្រោមជាតិ កែលម្អស្វ័យភាពនៃដំណើរការគណនេយ្យនិងរបាយការណ៍ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ពិនិត្យតាមដានទៀងទាត់នៅគ្រប់អនុវិស័យ និងថ្នាក់ក្រោមជាតិ លើគណនេយ្យភាពហិរញ្ញវត្ថុនិងសូចនាករលទ្ធផល។
    - ការពង្រឹងទំនាក់ទំនងរវាងគោលនយោបាយនិងថវិកា តាមរយៈការបញ្ចូលសកម្មភាពគាំទ្រដោយថវិកាមិនមែនកម្មវិធីទៅជាថវិកាកម្មវិធី ១០០ ភាគរយ។ នាយកដ្ឋានជំនាញទាំងអស់នឹងត្រូវរៀបចំថវិកាសម្រាប់អង្គភាពតាមគោលវិធីថវិកាកម្មវិធី។ ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ។ ការរៀបចំប្រព័ន្ធព្យាករណ៍តម្រូវការហិរញ្ញវត្ថុសម្រាប់វិស័យអប់រំ រួមបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធន។
    - ការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុអប់រំ តាមរយៈការបង្កើតម៉ូដែលសម្រាប់ព្យាករណ៍ និងបែងចែកថវិកាសម្រាប់វិស័យអប់រំ។ ការបង្កើតម៉ូដែលគណនាចំណាយផ្តោតលើលទ្ធផលតាមអនុវិស័យ។
    - ការពង្រឹងមូលដ្ឋានសម្រាប់ព្យាករណ៍និងប្រើប្រាស់ថវិកាអប់រំ តាមរយៈការកែលម្អនីតិវិធីក្នុងការចំណាយនិងនិយ័តកម្មថវិកា។ ការកែលម្អនីតិវិធីក្នុងការដកសាច់ប្រាក់និងទូទាត់។ ការកែលម្អប្រព័ន្ធព័ត៌មានសម្រាប់បម្រើដល់ការព្យាករណ៍ចំណាយនិងការវិភាគ។

   - ការពង្រឹងយន្តការកសាងផែនការថវិកានិងប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុ តាមរយៈ ការអភិវឌ្ឍសមត្ថភាពនិងធនធាននៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។ ការកែលម្អកម្រិតបៀវត្សមន្ត្រីរដ្ឋបាល រួមបញ្ចូលទាំងនាយកសាលារៀន។

- ***ការពង្រឹងការងារសវនកម្មផ្ទៃក្នុង*** ៖ ប្រតិបត្តិការសវនកម្មនៅតាមសវនដ្ឋានថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ពិនិត្យនិងកែសម្រួលការងារផ្ទៃក្នុងនូវនិតិវិធីសវនកម្ម គោលការណ៍ បទដ្ឋាន ច្បាប់នានា ដែលពាក់ព័ន្ធនឹងដំណើរការសវនកម្ម។ រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានសវនកម្មផ្ទៃក្នុង និងអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងនីតិវិធីសវនកម្ម។
- ***អធិការកិច្ចរដ្ឋបាលនិងហិរញ្ញវត្ថុ*** ៖ អធិការកិច្ចលើដំណើរការនៃការគ្រប់គ្រងបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន។ ត្រួតពិនិត្យនិងលើកសំណើដោះស្រាយករណីទាំងឡាយពាក់ព័ន្ធនឹងការងាររដ្ឋបាលនិងហិរញ្ញវត្ថុ។

## ៤.២ ការព្យាករណ៍ថវិកាសម្រាប់វិស័យអប់រំ

ទិសដៅគោលនយោបាយរយៈពេលវែងនៃការផ្ដល់ហិរញ្ញប្បទានសម្រាប់វិស័យអប់រំ គឺគ្មានសិស្សណាម្នាក់មិនបានទទួលការអប់រំ ដោយសារតែគ្មានលទ្ធភាពបង់ប្រាក់ ទោះជាតាមផ្លូវការ ក្រៅផ្លូវការ ឬជាវិភាគទាននោះទេ។ គោលដៅមួយទៀតគឺ ការអនុវត្តយន្តការហិរញ្ញប្បទានប្រកបដោយសមធម៌ និងត្រឹមត្រូវ ដោយគិតទាំងការជួយគាំទ្រពីសំណាក់រាជរដ្ឋាភិបាល មាតាបិតាសិស្ស និងដៃគូអភិវឌ្ឍដទៃទៀត។ ជាមួយនោះ ព័ត៌មានហិរញ្ញវត្ថុត្រូវមានគ្រប់គ្រាន់ស្ដីពីចំណាយក្នុងវិស័យអប់រំ ដើម្បីផ្ដល់លទ្ធភាពដល់អ្នកពាក់ព័ន្ធក្នុងការពិនិត្យឡើងវិញលើការវិនិយោគនាពេលបច្ចុប្បន្ន និងពេលអនាគតប្រកបដោយប្រសិទ្ធភាព។ ម្យ៉ាងវិញទៀត ជំរុញឱ្យមានការចូលរួមពីសំណាក់រាជរដ្ឋាភិបាល មាតាបិតាសិស្ស ផ្នែកឯកជន និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងការផ្ដល់ហិរញ្ញប្បទានសម្រាប់ការអប់រំនៅគ្រប់កម្រិត។

នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ការព្យាករណ៍ចំណាយថវិកាសម្រាប់វិស័យអប់រំសម្រាប់រយៈពេលពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ បានកើនឡើងទៅដល់ ៣០១៥ ពាន់លានរៀល នៅក្នុងឆ្នាំ ២០១៨។

*តារាងទី៣ ៖ ចំណែកថវិកាសម្រាប់វិស័យអប់រំនិងការព្យាករណ៍ចំណាយសម្រាប់ឆ្នាំ២០១៤-២០១៨*

| ការប៉ាន់ស្មានធនធាន | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| កំណើន ផ.ស.គ (IMF projection) | 7.2% | 7.4% | 7.4% | 7.5% | 7.5% |
| ផ.ស.ស សរុប (គិតជា លានដុល្លារ) | 17,288 | 19,090 | 21,078 | 23,294 | 25,628 |
| ផ.ស.ស សរុប (គិតជា លានរៀល) | 69,152,000 | 76,360,000 | 84,312,000 | 93,176,000 | 102,512,000 |
| **ផសស នៅឆ្នាំ ២០០០** (គិតជា លានរៀល) | **68,618,000** | **75,636,000** | **83,422,000** | **92,143,000** | **101,548,000** |
| *គិតជា លានដុល្លារ* | *16,943* | *18,676* | *20,598* | *22,474* | *24,768* |
| **ចំណាយសរុបរបស់រាជរដ្ឋាភិបាល** | **8,258,703** | **8,833,509** | **9,708,630** | **10,684,753** | **11,729,804** |

| | | | | | |
|---|---|---|---|---|---|
| ភាគរយក្រសួង អ.យ.ក ធៀប ផ.ស.ស | 2.0% | 2.2% | 2.4% | 2.7% | 3.0% |
| ភាគរយក្រសួង អ.យ.ក ធៀបចំណាយរបស់រដ្ឋាភិបាល | 16.3% | 18.6% | 20.7% | 23.1% | 25.7% |
| **ថវិកាក្រសួង អ.យ.ក (NSDP 2014-2018)** | **1,342,049** | **1,642,042** | **2,010,286** | **2,464,679** | **3,015,043** |
| *គិតជា លានដុល្លារ* | *336* | *411* | *503* | *616* | *754* |
| **ផែនការវិនិយោគវិស័យអប់រំ (2014-2016)** | **430,093** | **462,371** | **261,821** | **0** | **0** |
| គម្រោងកំពុងបន្ត (2014-2016) | 201,703 | 200,069 | 95,399 | 0 | 0 |
| *គិតជា លានដុល្លារ* | *50* | *50* | *24* | *0* | *0* |
| គម្រោងកំពុងចរចា (2014-2016) | 228,390 | 262,302 | 166,422 | 0 | 0 |
| *គិតជា លានដុល្លារ* | *57* | *66* | *42* | *0* | *0* |

ប្រភព ៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ បានប្រមូលផ្តុំសកម្មភាពអភិវឌ្ឍទាំងអស់ទៅតាមអនុវិស័យចំនួន ៧ ។ នៅក្នុងដំណាក់កាលឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ ក្រសួងអប់រំ យុវជន និងកីឡា បន្តអនុវត្តកំណែទម្រង់ដែលកំពុងអនុវត្ត និងបន្ថែមនូវសកម្មភាពអភិវឌ្ឍមួយចំនួនទៀត សំដៅសម្រេចបានគោលនយោបាយទាំងបីរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ដូចនេះ តម្រូវការធនធានសរុបសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ នឹងកើនឡើងពី ១៧៨០ ពាន់លានរៀល នៅឆ្នាំ ២០១៤ ទៅដល់ ៣៣៣០ ពាន់លានរៀលនៅឆ្នាំ ២០១៨។ ក្នុងរយៈពេលដូចគ្នា តម្រូវការថវិកាចរន្តសរុបនឹងកើនឡើងពី ១៥៤៥ ពាន់លានរៀល ទៅដល់ ២៩២៤ ពាន់លានរៀល។ ចំពោះតម្រូវការថវិកាមូលធនសរុបនឹងកើនឡើងពី ២៣៣ ពាន់លានរៀលក្នុងឆ្នាំ ២០១៤ ទៅដល់ ៤០៦ ពាន់លានរៀលក្នុងឆ្នាំ២០១៨ ។ ទន្ទឹមនឹងការកើនឡើងខ្លាំងតម្រូវការថវិកាមូលធននៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ថវិកាមូលធនដែលដៃគូអភិវឌ្ឍបានប្តេជ្ញានៅក្នុងកម្មវិធី វិនិយោគសាធារណៈឆ្នាំ ២០១៤-២០១៦ នឹងថយចុះពីប្រមាណ ៤៣០ ពាន់លានរៀល នៅឆ្នាំ ២០១៤ មកនៅត្រឹម ២៦០ ពាន់លានរៀល នៅឆ្នាំ ២០១៦។ ការថយចុះនេះដោយសារការថយចុះនៃការគាំទ្រពីដៃគូអភិវឌ្ឍ តាមរយៈគម្រោងដែលកំពុងអនុវត្តមួយចំនួននឹងត្រូវបញ្ចប់នៅឆ្នាំ ២០១៥។ ប៉ុន្តែ ថវិការាជរដ្ឋាភិបាល ជាពិសេសចំណាយចរន្តមានការកើនឡើង។

*តារាងទី ៤ ៖ តម្រូវការធនធានសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ (គិតជាលានរៀល)*

| | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| ការអប់រំកុមារតូច | 128,571 | 145,149 | 164,549 | 187,547 | 213,911 |
| ការអប់រំបឋមសិក្សា | 840,341 | 943,513 | 1,091,687 | 1,285,246 | 1,523,921 |
| ការអប់រំមធ្យមសិក្សា | 525,029 | 650,973 | 764,245 | 924,643 | 1,121,084 |
| *មធ្យមសិក្សាបឋមភូមិ* | *377,340* | *467,031* | *519,781* | *596,247* | *662,918* |
| *មធ្យមសិក្សាទុតិយភូមិ* | *147,689* | *183,942* | *244,464* | *328,396* | *458,166* |

| | | | | | |
|---|---|---|---|---|---|
| ឧត្តមសិក្សា | 210,050 | 246,560 | 272,469 | 313,997 | 392,636 |
| ការអប់រំក្រៅប្រព័ន្ធ | 20,937 | 22,207 | 23,458 | 24,610 | 25,739 |
| ការអភិវឌ្ឍយុវជន | 10,343 | 11,941 | 12,253 | 12,573 | 13,018 |
| ការអប់រំកាយនិងកីឡា | 47,558 | 27,584 | 26,462 | 28,974 | 44,322 |
| **សរុប** | **1,782,828** | **2,047,928** | **2,355,123** | **2,777,590** | **3,334,631** |

## ៤.៣ ការព្យាករណ៍តម្រូវការហិរញ្ញវត្ថុ និងធនធានដែលមាន

ដើម្បីអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ឱ្យមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តខិតខំធ្វើការកាន់តែជិតស្និទ្ធថែមទៀតជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីធានាថាផែនការចំណាយរយៈពេលមធ្យមសម្រាប់វិស័យអប់រំ ស្របទៅនឹងក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាល ព្រមទាំងស្របតាមកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលកំពុងអនុវត្ត។

*តារាងទី ៥ ៖ តម្រូវការធនធាន និងធនធានដែលមាន (គិតជា លានរៀល )*

| គម្លាតថវិកា | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| **សរុបធនធានដែលមាន** | 1,772,142 | 2,104,413 | 2,272,107 | 2,464,679 | 3,015,043 |
| *គិតជា លានដុល្លារ* | *443* | *526* | *568* | *616* | *754* |
| **តម្រូវការថវិកាអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ** | 1,782,828 | 2,047,928 | 2,355,123 | 2,777,590 | 3,334,631 |
| *គិតជា លានដុល្លារ* | *446* | *512* | *589* | *694* | *834* |
| **គម្លាតថវិកា** | -10,687 | 56,485 | -83,016 | -312,911 | -319,588 |
| *គិតជា លានដុល្លារ* | *-3* | *14* | *-21* | *-78* | *-80* |

ក្នុងតារាងខាងលើបានបង្ហាញពីកង្វះថវិកាចរន្តប្រមាណ ៦៥០ ពាន់លានរៀល ក្នុងកំឡុងពេលពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ ខាងមុខ។ ក្នុងករណីនេះ ក្រសួងនឹងត្រូវស្វែងរកការជួយឧបត្ថម្ភលើចំណាយចរន្តពីសំណាក់ដៃគូអភិវឌ្ឍឬអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីបំពេញកង្វះខាតថវិកានេះ និងធានាផ្តល់ហិរញ្ញវត្ថុសម្រាប់កែទម្រង់វិស័យអប់រំប្រកបដោយចីរភាព។

ជារួម នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ កង្វះខាតហិរញ្ញប្បទានសរុបមានប្រហែល ៦៥០ ពាន់លានរៀល ( ១៦៣ លានដុល្លារអាមេរិក) ។

# ជំពូកទី ៥
# ការគ្រប់គ្រង និងការពិនិត្យតាមដាន
# ផែនការយុទ្ធសាស្ត្រវិស័យអប់រំ
# ២០១៤-២០១៨

## ៥.១ ការគ្រប់គ្រងនិងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ដែលដឹកនាំដោយគណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នឹងបន្តផ្តល់ជាក្របខណ្ឌការងារសម្រាប់ជំរុញសកម្មភាពនានានៃការងារវិមជ្ឈការនិងវិសហមជ្ឈការ។ ក្នុងអំឡុងឆ្នាំ ២០១៤-២០១៨ ការគ្រប់គ្រងនៅថ្នាក់ក្រោមជាតិនឹងជំរុញឱ្យមានការផ្លាស់ប្តូរ ដោយមានការផ្ទេរនូវមុខងារគ្រប់គ្រងនិងមុខងារអន្តរវិស័យ ទៅដល់ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគមន៍ និងសាលារៀន។ ក្នុងឆ្នាំ ២០១៤ នឹងមានការសាកល្បងផ្ទេរមុខងារមួយចំនួនទៅដល់អាជ្ញាធរមូលដ្ឋាន។ ការសាកល្បងនឹងវាយតម្លៃពីដំណើរការវិមជ្ឈការដែលល្អបំផុតដែលនឹងអាចត្រូវបានយកមកអនុវត្តនៅពេលខាងមុខ។

### ៥.១.១ ការគ្រប់គ្រងបុគ្គលិក

ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងអាទិភាពមួយក្នុងចំណោមក្រសួងអាទិភាពនានា ដែលត្រូវធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុនិងការគ្រប់គ្រងបុគ្គលិក។ ក្រសួងបានគ្រប់គ្រងមន្ត្រីរាជការ ៦០ ភាគរយនៃមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ បញ្ហាប្រឈមក្នុងពេលបច្ចុប្បន្ន គឺការបង្កើនក្របខណ្ឌគ្រូបង្រៀន។ ការកំណត់បរិមាណគ្រូបង្រៀនត្រូវជ្រើសរើសជារៀងរាល់ឆ្នាំ មិនអាចបំពេញសេចក្តីត្រូវការតាមនិយាមដែលបានកំណត់នៅឡើយទេ។ ម៉្យាងទៀត របាយគ្រូបង្រៀននៅតាមសាលារៀនក៏មានភាពខុសគ្នាខ្លាំងផងដែររវាងតំបន់ប្រជុំជន តំបន់ជនបទ ជាពិសេសតំបន់ជួបការលំបាក។

#### ៥.១.១.១ យុទ្ធសាស្ត្រ

- លើកកម្ពស់ជីវភាពបុគ្គលិកអប់រំ តាមរយៈការដំឡើងបៀវត្ស ការកែសម្រួលនិងសនិទានកម្មការលើកទឹកចិត្ត និងការបើកប្រាក់តាមប្រព័ន្ធធនាគារ។
- សនិទានកម្មតម្រូវការនិងការផ្គត់ផ្គង់បុគ្គលិកអប់រំទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងពង្រឹងយន្តការក្នុងការផ្ទេរបុគ្គលិក។
- លើកកម្ពស់ការអភិវឌ្ឍអាជីព តាមរយៈការបង្កើតរចនាសម្ព័ន្ធអាជីពច្បាស់លាស់ ការដំឡើងឋានន្តរសក្តិនិងថ្នាក់របស់បុគ្គលិកផ្អែកលើស្នាដៃការងារ និងកម្រិតបៀវត្ស។
- កែលម្អនីតិវិធីការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក លក្ខណៈវិនិច្ឆ័យសម្រាប់ការតែងតាំងមន្ត្រីគ្រប់គ្រង ដោយប្រើប្រាស់ប្រព័ន្ធវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំនិងប្រព័ន្ធក្រេឌីត និងជំរុញការបំពេញភារកិច្ចរបស់គណៈកម្មការវាយតម្លៃការងារបុគ្គលិក។
- អភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រង តាមរយៈការប្រើប្រាស់ប្រព័ន្ធក្រេឌីត។

### ៥.១.១.២ សកម្មភាពគោលនយោបាយ

- រៀបចំកំណែទម្រង់ប្រាក់បៀវត្សរយៈពេលមធ្យម ២០១៥-២០១៨ នៅឆ្នាំ ២០១៤
- កែសម្រួលអនុក្រឹត្យស្តីពីការកំណត់ប្រាក់ម៉ោងបន្ថែមនៅឆ្នាំ ២០១៥
- ដាក់ឱ្យអនុវត្តគោលការណ៍ថ្មីស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំនៅឆ្នាំ ២០១៥
- កែសម្រួលគោលការណ៍ស្តីពីការគ្រប់គ្រងការងារបុគ្គលិកនៅឆ្នាំ ២០១៤
- រៀបចំឯកសារស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់តែងតាំងមន្ត្រីគ្រប់គ្រងនៅឆ្នាំ ២០១៤
- អនុវត្តគោលការណ៍ស្តីពីប្រព័ន្ធវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំនៅឆ្នាំ ២០១៥
- អនុវត្តប្រព័ន្ធក្រេឌីតសម្រាប់វាយតម្លៃសមត្ថភាពបុគ្គលិកអប់រំនៅឆ្នាំ ២០១៥
- រៀបចំប្រព័ន្ធនិងផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំនៅឆ្នាំ ២០១៤
- អនុវត្តប្រព័ន្ធកិច្ចសន្យាការងារសម្រាប់មន្ត្រីគ្រប់គ្រងនៅឆ្នាំ ២០១៨។

### ៥.១.១.៣ សូចនាករផលសម្រេច

- បុគ្គលិកអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនឹងបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារនៅឆ្នាំ ២០១៤
- ភាគរយសាលារៀនចំណេះទូទៅដែលមានផលធៀបសិស្ស គ្រូ តូចឬធំជាងនិយាមកំណត់ ៥ ភាគរយ
- ចំនួនមន្ត្រីគ្រប់គ្រង (ចាប់ពីនាយកសាលារៀន ដល់អគ្គនាយក) បានឆ្លងកាត់ការបណ្តុះបណ្តាល ១០០០ នាក់ក្នុងមួយឆ្នាំ
- ស្ត្រី ១០ ភាគរយ ក្នុងដំណែងចាប់ពីនាយិការងឡើង។

### ៥.១.១.៤ កម្មវិធីនិងសកម្មភាព

- ***កំណែទម្រង់បៀវត្ស*** ៖ បង្កើនបៀវត្សមូលដ្ឋានរបស់បុគ្គលិកអប់រំអប្បបរមា ៤០ ម៉ឺនរៀល។ បង្កើនប្រាក់ឧបត្ថម្ភបន្ថែមដូចជា ប្រាក់ម៉ោងបន្ថែម ប្រាក់បង្រៀនពីរវេន និងប្រាក់បង្រៀនថ្នាក់គួប។ បង្កើនប្រាក់បៀវត្សរបស់គ្រូជាប់កិច្ចសន្យាឱ្យដល់ ១៨ ម៉ឺនរៀល។ សិក្សាគោលការណ៍ស្តីពីប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិកអប់រំ។ បុគ្គលិកអប់រំទាំងអស់នឹងបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ។
- ***តម្រូវការនិងការផ្គត់ផ្គង់គ្រូបង្រៀន*** ៖ កែលម្អនិយាមប្រើប្រាស់បុគ្គលិកអប់រំ។ ពិនិត្យនិងកែសម្រួលគោលការណ៍ពង្រាយគ្រូបង្រៀន (ទាំងគ្រូចាស់ និង គ្រូចេញថ្មី) និងគោលការណ៍ផ្លាស់ប្តូរទីកន្លែងធ្វើការរបស់បុគ្គលិកអប់រំក្នុងរាជធានី ខេត្ត និងឆ្លងរាជធានី ខេត្ត។ សិក្សាពីតម្រូវការចំនួនក្របខណ្ឌដែលត្រូវជ្រើសរើស។

- ***វាយតម្លៃការបំពេញការងារ*** ៖ រៀបចំនិងកែសម្រួលលក្ខណៈវិនិច្ឆ័យសម្រាប់តែងតាំងមន្ត្រីគ្រប់គ្រង និង អនុវត្តប្រព័ន្ធវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ។
- ***ការអភិវឌ្ឍអាជីព*** ៖ ដំឡើងឋានន្តរស័ក្ត តាមវេនជ្រើសរើសនិងអតីតភាពការងារ និងដំឡើងថ្នាក់តាមអតីតភាព២ឆ្នាំជាស្វ័យប្រវត្តិ។ រៀបចំការប្រឡងផ្ទៃក្នុងដើម្បីប្តូរប្រភេទក្របខណ្ឌ។ ផ្សព្វផ្សាយនិងអនុវត្តគោលការណ៍ស្តីពីការដំឡើងឋានន្តរសក្តិនិងថ្នាក់ជូនមន្ត្រីរាជការ។ រៀបចំនិងអនុវត្តប្រព័ន្ធក្រេឌីតសម្រាប់បុគ្គលិកអប់រំ។
- ***ការអភិវឌ្ឍសមត្ថភាពអ្នកគ្រប់គ្រងអប់រំ*** ៖ អភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រងនិងមន្ត្រីបច្ចេកទេសនៅតាមអង្គភាព អភិវឌ្ឍសមត្ថភាពមន្ត្រីដែលមានឧបនិស្ស័យជាអ្នកគ្រប់គ្រង និងអ្នកគ្រប់គ្រងអប់រំចាប់ពីនាយកសាលារៀនរហូតដល់អគ្គនាយកលើការងារគ្រប់គ្រងអប់រំ។

## ៥.១.២ ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន និងមន្ត្រីគ្រប់គ្រងអប់រំ

### ៥.១.២.១ សារតារ

ក្រសួងបានបណ្តុះបណ្តាលគ្រូបង្រៀន ដោយប្រើប្រាស់រូបមន្តបណ្តុះបណ្តាលចម្រុះតាមការចាំបាច់ រួមមានរយៈពេលខ្លី រយៈពេលវែង ផ្អែកទៅតាមតម្រូវការដែលបានគ្រោងទុក។

- គ្រូបឋមសិក្សា និងមត្តេយ្យសិក្សាបណ្តុះបណ្តាលរយៈពេល ២ ឆ្នាំ តាមរូបមន្ត ១២+២ ដោយជ្រើសរើសបេក្ខជន ចាប់ពីធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ និងតាមរូបមន្ត ៩+២ សម្រាប់ខេត្តដាច់ស្រយាលនិងតំបន់ជួបការលំបាក ដោយជ្រើសរើសបេក្ខជនចាប់ពីជាប់មធ្យមសិក្សាបឋមភូមិឡើងទៅ។
- គ្រូមធ្យមសិក្សាបឋមភូមិបណ្តុះបណ្តាលរយៈពេល ២ ឆ្នាំ តាមរូបមន្ត ១២+២ ដោយជ្រើសរើសបេក្ខជន ចាប់ពីជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ។
- គ្រូបង្រៀនកម្រិតឧត្តមបណ្តុះបណ្តាលតាមរូបមន្តបរិញ្ញាបត្រ+១។

ការងារវិក្រឹតការមានបីរូបភាព ការងារវិក្រឹតការនៅនឹងកន្លែង (ការប្រជុំក្រុមបច្ចេកទេសនៅថ្ងៃព្រហស្បតិ៍) ការងារវិក្រឹតការមិនរៀបរយរយៈពេលខ្លីតាមការចាំបាច់របស់ក្រសួង និងការងារវិក្រឹតការរៀបរយ (មានផែនការកម្មវិធីច្បាស់លាស់នៅតាមសាលាគរុកោសល្យ)។ ការងារវិក្រឹតការមិនទាន់ត្រូវបានអនុវត្តជាលក្ខណៈប្រព័ន្ធច្បាស់លាស់នៅឡើយ។

### ៥.១.២.២ វត្ថុបំណងគោលនយោបាយ

- ការបណ្តុះបណ្តាលគ្រូបឋមសិក្សានិងមត្តេយ្យសិក្សាតាមរូបមន្ត ៩+២ ត្រូវបញ្ចប់ ហើយជំនួសដោយរូបមន្តបណ្តុះបណ្តាល ១២+២ ដោយជ្រើសរើសបេក្ខជនចាប់ពីជាប់សញ្ញាបត្រមធ្យមសិក្សា

ទុតិយភូមិឡើងទៅ។ គ្រូមធ្យមសិក្សាបឋមភូមិរក្សាទុកនូវរូបមន្តបណ្តុះបណ្តាល ១២+២ និងគ្រូបង្រៀនកម្រិតឧត្តមបណ្តុះបណ្តាលបរិញ្ញាបត្រ+១ នៅត្រឹមឆ្នាំ ២០១៨។

- ចាប់ពីឆ្នាំ ២០២០ ការបណ្តុះបណ្តាលគ្រូបឋមសិក្សា មត្តេយ្យសិក្សានិងមធ្យមសិក្សាបឋមភូមិត្រូវអនុវត្តតាមរូបមន្ត ១២+៤ ឬ បរិញ្ញាបត្រ+១ ។ ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមត្រូវប្តូរពីបរិញ្ញាបត្រ+១ ទៅបរិញ្ញាបត្រជាន់ខ្ពស់+១។
- ចាប់ពីឆ្នាំ ២០២០ គ្រូថ្មីគ្រប់ភូមិសិក្សាដែលចេញពីគ្រឹះស្ថានបណ្តុះបណ្តាលមានសញ្ញាបត្រយ៉ាងទាបចាប់ពីបរិញ្ញាបត្រឡើងទៅ។

### ៥.១.២.៣ យុទ្ធសាស្ត្រ

- កែលម្អក្របខណ្ឌការងារស្តីពីការបណ្តុះបណ្តាលគ្រូបង្រៀន
- អភិវឌ្ឍសមត្ថភាពគ្រូបង្រៀន
- អភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស
- អភិវឌ្ឍសម្ភាររូបវន្តអប់រំសម្រាប់ការបណ្តុះបណ្តាលនិងការអភិវឌ្ឍសមត្ថភាព។

### ៥.១.២.៤ សកម្មភាពគោលនយោបាយ

- រៀបចំប្រព័ន្ធបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀននៅឆ្នាំ ២០១៥
- រៀបចំប្រព័ន្ធគ្រប់គ្រងនិងវាយតម្លៃការងារបណ្តុះបណ្តាលគ្រូបង្រៀននៅឆ្នាំ ២០១៤។

### ៥.១.២.៥ សូចនាករផលសម្រេច

- ភាគរយគ្រូបង្រៀននៅមត្តេយ្យសិក្សានិងបឋមសិក្សាដែលបានឆ្លងកាត់ការបណ្តុះបណ្តាលតាមរូបមន្ត ១២+២ កើនដល់ ១០០ ភាគរយនៅឆ្នាំ ២០១៨
- ភាគរយគ្រូបង្រៀនគ្រប់កម្រិតបានទទួលវិក្រឹតការក្នុង ១ ឆ្នាំ ៥ ភាគរយ ចាប់ពីឆ្នាំ ២០១៦។

### ៥.១.២.៦ កម្មវិធីនិងសកម្មភាព

- ***ការអភិវឌ្ឍការបណ្តុះបណ្តាលគ្រូបង្រៀននៅគ្រប់កម្រិត*** ៖ គ្រូបង្រៀនមត្តេយ្យសិក្សានិងបឋមសិក្សា ត្រូវបានបណ្តុះបណ្តាលតាមរូបមន្ត ១២+២។ គ្រូមធ្យមសិក្សាបឋមភូមិនិងគ្រូមធ្យមសិក្សាទុតិយភូមិរក្សារូបមន្តបណ្តុះបណ្តាលដដែល។កម្មវិធីនិងឯកសារបណ្តុះបណ្តាលត្រូវបានកែលម្អ។
- ***ការអភិវឌ្ឍការងារវិក្រឹតការគ្រូបង្រៀននៅគ្រប់កម្រិត*** ៖ រៀបចំផែនការវិក្រឹតការទៀងទាត់ ដើម្បីលើកកម្ពស់សមត្ថភាពគ្រូបង្រៀនជាប្រចាំ។ គ្រូបង្រៀនគ្រប់ភូមិសិក្សាដែលចេញពីសាលាគរុកោសល្យត្រូវវិលមកទទួលការបំប៉នបង្កើនសមត្ថភាពជារៀងរាល់ ៥ ឆ្នាំម្តងនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ។

- ***ការអភិវឌ្ឍមជ្ឈមណ្ឌលបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន*** ៖ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូប្រែក្លាយទៅជាមជ្ឈមណ្ឌលបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន ស្របតាមស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ អភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំនិងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន ស្របតាមលក្ខណៈវិនិច្ឆ័យកំណត់។ រៀបចំប្រព័ន្ធគ្រប់គ្រងនិងវាយតម្លៃការងារបណ្តុះបណ្តាលគ្រូបង្រៀន។

### ៥.១.៣ ការគ្រប់គ្រងហិរញ្ញវត្ថុនិងថវិកា

នៅឆ្នាំ ២០១៤ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១៥-២០១៧ នឹងមានគោលនយោបាយចំនួនពីរ (ការចូលរៀននិងគុណភាព) និង កម្មវិធី ៧ (តាមអនុវិស័យ)។ សូចនាករសម្រាប់កម្មវិធីនីមួយៗនឹងក្លាយជាសូចនាករស្នូលសម្រាប់កម្មវិធីនោះ។ ថវិកាកម្មវិធីនាពេលបច្ចុប្បន្ននឹងរួមបញ្ចូលការចំណាយទាំងអស់ លើកលែងតែការចំណាយមូលធន នឹងក្លាយទៅជាថវិកាចរន្តពេញលេញរួមទាំងបៀវត្សនិងការចំណាយផ្សេងទៀត។ កម្រិតនៃការទទួលខុសត្រូវនៅកម្រិតរដ្ឋបាលនីមួយៗនឹងអាស្រ័យលើល្បឿននៃកម្មវិធីនៃដំណើរការវិមជ្ឈការនិងវិសហមជ្ឈការ។

### ៥.១.៤ ការគ្រប់គ្រងកម្មវិធី

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ អនុវត្តតាមគោលនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី ៥ ដោយផ្ទេរមុខងារ ផ្ទេរធនធានមនុស្ស និងផ្ទេរធនធានហិរញ្ញវត្ថុ ជាបណ្តើរៗទៅថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងសាលារៀនឱ្យស្របតាមក្របខណ្ឌច្បាប់គ្រប់គ្រងរដ្ឋបាលដែនដី ក្របខណ្ឌយុទ្ធសាស្ត្រវិមជ្ឈការនិងវិសហមជ្ឈការ កម្មវិធីជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យអប់រំ។

- ***ក្រសួងអប់រំ យុវជន និងកីឡា*** ៖ ក្រសួងអប់រំ យុវជន និងកីឡាមានការទទួលខុសត្រូវនិងការត្រួតពិនិត្យទិដ្ឋភាពបច្ចេកទេសនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ រដ្ឋមន្ត្រីនិងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ជួបប្រជុំយ៉ាងទៀងទាត់ តាមរយៈគណៈកម្មការគ្រប់គ្រងកម្មវិធី ដើម្បីពិនិត្យឡើងវិញនូវវឌ្ឍនភាពរបស់វិស័យនិងរៀបចំរបាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំ។ របាយការណ៍សន្និបាតអប់រំមានទំនាក់ទំនងនឹងក្របខ័ណ្ឌពិនិត្យតាមដានរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

- ***អនុវិស័យ*** ៖ អនុវិស័យនីមួយៗនឹងត្រូវដឹកនាំដោយរដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការមួយរូប។ អគ្គនាយកឬអគ្គនាយករងមួយរូបនឹងដើរតួនាទីជាជនបង្គោលក្នុងអនុវិស័យ ដើម្បីជាជំនួយដល់រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការ។ អនុវិស័យនីមួយៗនឹងត្រូវដំណើរការការងារ តាមរយៈក្រុមការងារតាមអនុវិស័យ ដែលរួមបញ្ចូលទាំងនាយកដ្ឋានជំនាញពាក់ព័ន្ធនិងនាយកដ្ឋានទទួលបន្ទុកអនុវត្តក្របខណ្ឌគោលនយោបាយនិងយុទ្ធសាស្ត្រ។ រចនាសម្ព័ន្ធនិងតួនាទីរបស់អនុវិស័យនឹងត្រូវបានកែសម្រួល ដើម្បីឱ្យស្របនឹងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ លក្ខខណ្ឌ

យោងជាមូលដ្ឋានរបស់អនុវិស័យនីមួយៗនឹងត្រូវរៀបចំ ដោយរួមបញ្ចូលទាំងការរៀបចំផែនការការងាររយៈពេលមធ្យមនិងផែនការប្រចាំឆ្នាំ។ នាយកដ្ឋានផែនការនឹងដើរតួជាអ្នកសម្របសម្រួលក្នុងការរៀបចំអនុវិស័យ។

- ***នាយកដ្ឋានជំនាញ*** ៖ ផ្តល់ការគាំទ្រដល់បុគ្គលិកថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្ត ការពិនិត្យតាមដាន និងរាយការណ៍នៃការអនុវត្តកម្មវិធីរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរាជធានី ខេត្ត។
- ***មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត*** ៖ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត រៀបចំ និងពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត។ វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត ត្រូវបានរាយការណ៍ក្នុងសន្និបាតថ្នាក់រាជធានីខេត្ត។ ថ្នាក់រាជធានី ខេត្តនឹងគ្រប់គ្រងគ្រឹះស្ថានអប់រំមធ្យមសិក្សា និងស្ថាប័នបណ្តុះបណ្តាលគ្រូបង្រៀន រួមបញ្ចូលទាំងការងារវិមជ្ឈការ។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្តជាប្រធាននៃគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នា។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត រៀបចំថវិកាអប់រំថ្នាក់រាជធានី ខេត្តសម្រាប់បង្ហាញទៅគណៈអភិបាលរាជធានី ខេត្ត។
- ***ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ*** ៖ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ រៀបចំផែនការការងារប្រចាំឆ្នាំដោយផ្អែកលើផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត និងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស។ ក្រុង ស្រុក ខណ្ឌនឹងគ្រប់គ្រងគ្រឹះស្ថានអប់រំបឋមសិក្សាដែលនឹងរួមបញ្ចូលទាំងការងារវិមជ្ឈការ។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ រៀបចំថវិកាអប់រំស្រុកសម្រាប់បង្ហាញទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាប្រធានគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ស្រុក។ ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌផ្តល់ការគាំទ្រក្នុងការអនុវត្ត ការត្រួតពិនិត្យ និងរបាយការណ៍នៃផែនការស្រុកនៅកម្រិតសាលារៀន។
- ***ក្រុមប្រឹក្សាឃុំ សង្កាត់*** ៖ ក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់គ្រងហិរញ្ញវត្ថុ កម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូច (មត្តេយ្យសិក្សាសហគមន៍ និងអប់រំតាមខ្នងផ្ទះ) ។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាប្រធានគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ ឃុំ សង្កាត់។
- ***គណៈកម្មការទ្រទ្រង់សាលារៀន*** ៖ ដោយមានការគាំទ្រពីគណៈកម្មការទ្រទ្រង់សាលារៀនសាលារៀនបានរៀបចំផែនការអភិវឌ្ឍសាលា និងរៀបចំចំណាយថវិកាតាមគណនីសម្រាប់មូលនិធិកម្រិតសាលារៀន (ថវិកាកម្មវិធី និងប្រភពផ្សេងទៀតនៃមូលនិធិ ដូចជា ថវិកាកែលម្អសាលារៀន វឌ្ឍនភាពនៃការត្រួតពិនិត្យ និងរៀបចំរបាយការណ៍សម្រាប់ការិយាល័យអប់រំយុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។

## ៥.២ ការពិនិត្យតាមដាននិងវាយតម្លៃ

ដើម្បីឱ្យការពិនិត្យតាមដាននិងការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ មានប្រសិទ្ធភាព គោលបំណងនៃការពិនិត្យតាមដាននិងវាយតម្លៃនិងសំណុំនៃគោលការណ៍មួយចំនួនត្រូវបានកំណត់ដូចខាងក្រោម ៖

- **ការពិនិត្យតាមដានផលប៉ះពាល់ ៖** ផែនការយុទ្ធសាស្ត្រវិស័យអប់រំនឹងមានការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៅឆ្នាំ ២០១៦ និងពិនិត្យឡើងវិញចុងក្រោយក្នុងឆ្នាំ ២០១៨ ដើម្បីវាយតម្លៃផលប៉ះពាល់នៃកម្មវិធីទាំងមូល។ ការវាយតម្លៃពាក់កណ្តាលអាណត្តិនិងចុងក្រោយនឹងត្រូវចូលរួមយោបល់ តាមរយៈរបាយការណ៍វាយតម្លៃឯករាជ្យ។ ការពិនិត្យឡើងវិញនឹងត្រូវគ្រប់គ្រងដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងត្រូវពិនិត្យឡើងវិញនូវហេតុផលនៃគុណភាពនិងប្រសិទ្ធភាពកម្មវិធី ដែលរួមចំណែកសម្រេចបានផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិនិងចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០ ។
- **ការពិនិត្យតាមដានការបំពេញការងារផែនការយុទ្ធសាស្ត្រវិស័យអប់រំ**
    - *សន្និបាតអប់រំថ្នាក់ជាតិប្រចាំឆ្នាំ*
        - **ការកំណត់ពេលវេលានិងអ្នកចូលរួម៖** សន្និបាតអប់រំត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំនៅក្នុងខែកុម្ភៈ ឬខែមីនា។ អ្នកចូលរួមមកពីវិស័យអប់រំទាំងមូល និងពីគ្រប់កម្រិតទាំងអស់រួមមាន៖ ថ្នាក់កណ្តាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន ក្រសួងពាក់ព័ន្ធ វិស័យឯកជន ដៃគូអភិវឌ្ឍ និងភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាល។
        - **គោលបំណង ៖** អ្នកចូលរួមសន្និបាតនឹងពិនិត្យឡើងវិញនូវការបំពេញការងារដែលបានអនុវត្តឆ្លើយតបទៅនឹងផលសម្រេច លទ្ធផល និងដំណើរការក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ និងវិស័យជាក់លាក់ដែលបានកំណត់ក្នុងឆ្នាំកន្លងទៅ និងកំណត់ទិសដៅសម្រាប់ឆ្នាំបន្ទាប់។ សន្និបាតអប់រំផ្តល់ជាកាលានុវត្តភាពសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា បុគ្គលិកថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ក្រសួងពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍនានា ពិភាក្សាពីការបំពេញការងារ កំណត់ពីបញ្ហាប្រឈមនិងវិស័យជាក់លាក់សម្រាប់ឆ្នាំខាងមុខ និងឯកភាពលើសកម្មភាពចាំបាច់មួយចំនួន។ សន្និបាតអប់រំផ្តល់ជាធាតុចូលសម្រាប់កែលម្អផែនការយុទ្ធសាស្ត្រវិស័យអប់រំ។
        - **ធាតុចូលនិងផលសម្រេច ៖** ក្រុមការងារអន្តរវិស័យនីមួយៗផ្តល់ធាតុចូល ដែល

មានការវិភាគលម្អិតលើការបំពេញការងារតាមអនុវិស័យ ទៅក្នុងរបាយការណ៍សន្និបាត។ ធាតុចូលទាំងនេះមានសារៈសំខាន់ ក្នុងការពិនិត្យឡើងវិញការបំពេញការងារតាមគោលនយោបាយរបស់អនុវិស័យនីមួយៗ យុទ្ធសាស្ត្រ និងកម្មវិធីធៀបទៅនឹងគោលដៅ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងម៉ាទ្រីកគោលនយោបាយ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការការងារផ្សេងៗនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ការវិភាគនឹងរួមបញ្ចូលទាំងទិដ្ឋភាពនៅកម្រិតសាលារៀននិងក្រុង ស្រុក ខណ្ឌ ដែលទទួលបានពីសន្និបាតថ្នាក់រាជធានី ខេត្ត ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងប្រព័ន្ធព័ត៌មានគុណភាពអប់រំ ការស្រាវជ្រាវនិងការសិក្សា ការវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្ស របាយការណ៍ពិនិត្យតាមដាន និងទិន្នន័យពាក់ព័ន្ធឬព័ត៌មានដទៃទៀត។ ផលសម្រេចរបស់សន្និបាតគឺជាធាតុចូលសម្រាប់កែលម្អផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងទិសដៅសម្រាប់ឆ្នាំសិក្សាបន្ទាប់។

- ដំណើរការពិនិត្យតាមដាននិងវាយតម្លៃ ការគ្រប់គ្រង និងការរៀបចំឧបករណ៍ពិនិត្យតាមដានគឺជាការទទួលខុសត្រូវរបស់នាយកដ្ឋានផែនការ។ អនុវិស័យនីមួយៗនឹងត្រូវរៀបចំរបាយការណ៍របស់ខ្លួនតាមទម្រង់ដែលបានរៀបចំ។

○ ***សន្និបាតអប់រំថ្នាក់រាជធានី ខេត្ត***

- សន្និបាតអប់រំថ្នាក់រាជធានី ខេត្ត ត្រូវបានប្រារព្ធឡើងរយៈពេលមួយឬពីរថ្ងៃក្នុងខែមករា មុនពេលសន្និបាតថ្នាក់ជាតិ។
- ចាប់ពីឆ្នាំ ២០១៤ រាជធានី ខេត្តនីមួយៗនឹងចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានីខេត្ត ដែលមានទម្រង់ប្រហាក់ប្រហែលផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិ (តាមអនុវិស័យ)។ របាយការណ៍សន្និបាតអប់រំថ្នាក់រាជធានី ខេត្ត នឹងរួមបញ្ចូលទាំងរបាយការណ៍តាមអនុវិស័យ។ សន្និបាតរាជធានីខេត្តវិភាគពីទិន្នន័យកម្រិតថ្នាក់រាជធានី ខេត្ត និងរាយការណ៍ស្តីពីការបំពេញការងារនៃកម្មវិធី និងអនុកម្មវិធីនៃរាជធានី ខេត្តទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត ផែនការប្រតិបត្តិប្រចាំឆ្នាំ និងរបាយការណ៍របស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ រួមបញ្ចូលទាំងរបាយការណ៍ថវិកាកម្មវិធីនិងមិនមែនកម្មវិធី ព្រមទាំងមូលនិធិដទៃទៀតនៅសាលារៀននិងការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក ខណ្ឌ។
- របាយការណ៍រាជធានី ខេត្តផ្តល់ជាមូលដ្ឋានសម្រាប់កែលម្អនិងកែតម្រូវផែនការការងារប្រចាំឆ្នាំនិងជាធាតុចូលដល់សន្និបាតថ្នាក់ជាតិ។

- ការពិនិត្យតាមដានវឌ្ឍនភាព
    - **ក្រុង ស្រុក ខណ្ឌ ៖** ការពិនិត្យតាមដាន ត្រូវធ្វើឡើងដើម្បីគាំទ្រនៅកម្រិតសាលារៀនស្តីពីការអនុវត្តសកម្មភាព គោលនយោបាយក៏ដូចជា សកម្មភាពនានារបស់អនុកម្មវិធីត្រូវបានអនុវត្តជាទៀងទាត់។ ការិយាល័យ អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌទទួលខុសត្រូវលើការពិនិត្យតាមដានប្រភេទនេះ ដោយសហការជាមួយគណៈកម្មការទ្រទ្រង់សាលារៀន និង គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នានៅថ្នាក់ឃុំ សង្កាត់។
    - **សាលារៀននិងគណៈកម្មការទ្រទ្រង់សាលា ៖** ដោយមានការគាំទ្រពីគណៈកម្មការទ្រទ្រង់សាលា សាលារៀនរៀបចំនិងអនុវត្តផែនការអភិវឌ្ឍសាលារៀននិងផ្តល់របាយការណ៍ស្តីពីការចំណាយថវិកាកម្មវិធីទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។ នៅក្នុងសប្តាហ៍ទីពីរបន្ទាប់ពីពិធីបើកបវេនកាល សាលារៀនត្រូវបំពេញនិងបញ្ជូនបន្តពីព័ត៌មានជំរឿនអំពីសាលារៀន ទៅការិយាល័យប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំថ្នាក់ជាតិ។ ទិន្នន័យជំរឿនសង្ខេបស្តីពីការចុះឈ្មោះចូលរៀន ការបោះបង់ ការផ្ទេរ ត្រូវបានប្រមូលនៅពាក់កណ្តាលឆ្នាំសិក្សានិងចុងឆ្នាំសិក្សា នឹងត្រូវបញ្ជូនបន្តទៅទៅការិយាល័យប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំថ្នាក់ជាតិ។ ការពិនិត្យតាមដាន ព័ត៌មានត្រឡប់ និងជំនួយត្រូវបានផ្តល់ដោយក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ។

| ប្រភេទពិនិត្យតាមដាន | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|
| ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ<br>ការពិនិត្យឡើងវិញចុងអាណត្តិ | ២០១៦<br>២០១៨ | ក្រុមការងារ |
| សន្និបាតអប់រំប្រចាំឆ្នាំ (ថ្នាក់ជាតិនិងរាជធានី ខេត្ត) | រៀងរាល់ឆ្នាំ | គណៈកម្មការសន្និបាត |
| វឌ្ឍនភាពតាមអនុវិស័យ | ២ ដងក្នុង ១ ឆ្នាំ | ក្រុមការងារអនុវិស័យ |
| វឌ្ឍនភាពកម្មវិធី អនុកម្មវិធី | ៤ ដងក្នុង ១ ឆ្នាំ | អគ្គនាយកដ្ឋាន |

## ៥.៣ នីតិវិធីក្នុងការពិភាក្សា

### ៥.៣.១ អង្គវិបស្សនាអប់រំប្រចាំឆ្នាំចន្លោះខែតុលានិងខែមករា

អង្គវិបស្សនាអប់រំប្រចាំឆ្នាំ ជាឱកាសរួមគ្នាក្រោមអធិបតីភាពរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មន្ត្រីជាន់ខ្ពស់ពីក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍ និងតំណាងនៃអង្គការមិនមែនរដ្ឋាភិបាល។ អង្គវិបស្សនាបានផ្តល់នូវឱកាសសម្រាប់ឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៅក្នុងវិស័យអប់រំ និងសម្រាប់ការពិចារណាអំពីអាទិភាពរួមសម្រាប់ឆ្នាំខាងមុខ។ ឯកសារពិភាក្សាក្នុងអង្គវិបស្សនា ត្រូវបានរៀបចំមុនពេល

កិច្ចប្រជុំដោយក្រុមការងារបច្ចេកទេសវិស័យអប់រំ ឯកសារស្រាវជ្រាវដែលរៀបចំដោយអនុវិស័យ ឬនាយកដ្ឋាន និងឯកភាពដោយក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ។ ផលសម្រេចនៃអង្គវិបស្សនានឹងប្រើជាធាតុចូលសម្រាប់របាយការណ៍សន្និបាតអប់រំ ។

### ៥.៣.២ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ

វត្ថុបំណងទូទៅនៃការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំគឺ ដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនិងភាពជាដៃគូ ក្នុងការគាំទ្រដល់ការសម្រេចផែនការយុទ្ធសាស្ត្រវិស័យអប់រំនិងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្របទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបី និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ តួនាទីក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំគឺ លើកកម្ពស់ការតម្រឹមនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផ្តល់ព័ត៌មានស្តីពីមូលនិធិភាពជាដៃគូនិងគាំទ្រដល់ដំណើរការថវិកា រួមបញ្ចូលទាំងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ធានាឱ្យបាននូវភាពស៊ីចង្វាក់គ្នានៃកម្មវិធីអភិវឌ្ឍសមត្ថភាពជាមួយនឹងផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាព ពិនិត្យឡើងវិញនិងរាយការណ៍ពីប្រសិទ្ធិភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅក្នុងឱកាសសន្និបាតអប់រំ និងអង្គវិបស្សនា។

### ៥.៣.៣ ក្រុមការងារបច្ចេកទេសចម្រុះថ្នាក់រាជធានី ខេត្ត

ក្រុមការងារបច្ចេកទេសចម្រុះថ្នាក់រាជធានី ខេត្ត គាំទ្រដល់ការធ្វើផែនការ ការគ្រោងថវិកា និងការរាយការណ៍អំពីសកម្មភាពរបស់រាជធានី ខេត្តនៅក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត។ ក្រុមការងារក៏ផ្តល់ធាតុចូលដើម្បីធ្វើការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រថវិកា (ជាពិសេសថវិកាកម្មវិធី) និង ផែនការការងារប្រចាំឆ្នាំដោយផ្អែកលើផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត និងដើម្បីរៀបចំឯកសារតាមអនុវិស័យ និងសន្និបាតអប់រំប្រចាំឆ្នាំ។

## ៥.៤ ការអភិវឌ្ឍភាពដឹកនាំនិងការគ្រប់គ្រងសម្រាប់វិស័យអប់រំ

### ៥.៤.១ សេចក្តីផ្តើម

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ បានបញ្ជាក់ពីសារៈសំខាន់នៃការកសាងធនធានមនុស្សនៅក្នុងក្រសួង ដើម្បីផ្តល់ការរៀនសូត្រដល់កុមារកម្ពុជាឱ្យមានប្រសិទ្ធភាពក្នុងបរិបទវិមជ្ឈការនិងវិសហមជ្ឈការ។ ការអភិវឌ្ឍសមត្ថភាពឱ្យមានប្រសិទ្ធភាពគឺត្រូវដាក់ចេញជាយុទ្ធសាស្ត្រ ដើម្បីសម្រេចបាននូវការចូលរៀនប្រកបដោយសមធម៌ និងប្រកបដោយគុណភាពសម្រាប់កុមារគ្រប់រូប និងផ្តោតជាចម្បងលើសាលារៀន ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ជាពិសេសកន្លែងជួបការលំបាកឬមិនទាន់សម្រេចបានតាមចំណុចដៅ។

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការគោលអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំឆ្នាំ ២០១៣-២០១៥។ ផែនការគោលអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំបង្ហាញថា វិស័យអប់រំមានសមត្ថភាព

យ៉ាងពេញលេញនិងស៊ីចង្វាក់គ្នា ដែលគាំទ្រដោយយន្តការដ៏មានប្រសិទ្ធភាពសម្រាប់កិច្ចសហការ ប្រព័ន្ធមុខងារក្នុងការធ្វើផែនការនិងការគ្រប់គ្រងធនធានមនុស្សមានសមត្ថភាព។

ផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ បានកំណត់ផលសម្រេចជាយុទ្ធសាស្ត្រចំនួន ៧ ដូចខាងក្រោម៖

- ផលសម្រេចជាយុទ្ធសាស្ត្រទី ១ ៖ ពង្រឹងសមត្ថភាពរបស់ថ្នាក់ដឹកនាំ អ្នកគ្រប់គ្រងជាន់ខ្ពស់ និងប្រធានអង្គភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងពង្រឹងភាពស៊ីចង្វាក់គ្នានិងការសម្របសម្រួលការងាររបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ផលសម្រេចជាយុទ្ធសាស្ត្រទី ២ ៖ ពង្រឹងសមត្ថភាពនិងប្រព័ន្ធសម្រាប់ធ្វើការវិភាគ រៀបចំផែនការពិនិត្យតាមដាន ពិនិត្យឡើងវិញ និងវាយតម្លៃនៅគ្រប់កម្រិតទាំងអស់
- ផលសម្រេចជាយុទ្ធសាស្ត្រទី ៣ ៖ ពង្រឹងសមត្ថភាពដើម្បីគាំទ្រនិងអនុវត្តច្បាប់ស្តីពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងវិស័យអប់រំ
- ផលសម្រេចជាយុទ្ធសាស្ត្រទី ៤ ៖ ពង្រឹងសមត្ថភាពនិងប្រព័ន្ធ ដើម្បីធ្វើការគ្រប់គ្រង អភិវឌ្ឍ និងផ្តល់ការលើកទឹកចិត្តដល់ធនធានមនុស្សប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និងសមធម៌ និងដើម្បីឱ្យការងាររដ្ឋបាល ការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងគមនាគមន៍ និងការគ្រប់គ្រងព័ត៌មាន អាចដំណើរការទៅបានប្រកបដោយភាពស័ក្តិសិទ្ធិ
- ផលសម្រេចជាយុទ្ធសាស្ត្រទី ៥ ៖ ពង្រឹងសមត្ថភាពនិងប្រព័ន្ធ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ និងការធ្វើសវនកម្ម
- ផលសម្រេចជាយុទ្ធសាស្ត្រទី ៦ ៖ ពង្រឹងអភិបាលកិច្ចល្អ និងការធានាគុណភាព ជាពិសេសផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងការងារដឹកនាំ និងសម្រេចចិត្ត
- ផលសម្រេចជាយុទ្ធសាស្ត្រទី ៧ ៖ ពង្រឹងសមត្ថភាពរបស់វិទ្យាស្ថានជាតិអប់រំ និងគ្រឹះស្ថានឧត្តមសិក្សាដែលពាក់ព័ន្ធនៅក្នុងការរៀបចំការបណ្តុះបណ្តាលអំពីការគ្រប់គ្រងការអប់រំ និងគាំទ្រដល់ការស្រាវជ្រាវនិងការសិក្សា ដែលមានគុណភាពខ្ពស់នៅទូទាំងវិស័យអប់រំទាំងមូល។

### ៥.៤.២ វត្ថុបំណងគោលនយោបាយ

- បង្កើតវប្បធម៌នៃភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង ដែលបំផុសនិងជំរុញបុគ្គលិក ផ្តល់ជាបទពិសោធសម្រាប់កុមារកម្ពុជាគ្រប់រូបប្រកបដោយគុណភាពនិងភាពឆ្លើយតប ស្របទៅនឹងបំណងប្រាថ្នារបស់ប្រទេសជាតិ
- ធានាថារចនាសម្ព័ន្ធស្ថាប័នបានលើកកម្ពស់សេវាគ្រប់គ្រងឱ្យមានភាពស័ក្តិសិទ្ធនិងប្រសិទ្ធភាព

- គុណភាពនៃភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងត្រូវបានបង្កើតឡើង និងកែតម្រូវតាមរយៈលទ្ធផលនៃការពិនិត្យតាមដាននិងការវាយតម្លៃប្រកបដោយប្រសិទ្ធភាព។

### ៥.៩.៣ យុទ្ធសាស្រ្ត

- ផ្តល់កម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំជាក់លាក់ដល់បុគ្គលិកជាន់ខ្ពស់
- បន្តអភិវឌ្ឍវិទ្យាស្ថានជាតិអប់រំ ដើម្បីផ្តល់ការបណ្តុះបណ្តាលជំនាញគ្រប់គ្រងនិងរដ្ឋបាលអប់រំប្រកបដោយគុណភាពនិងភាពឆ្លើយតប ដល់បុគ្គលិកអប់រំថ្នាក់ជាតិ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ
- ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការរាជធានី ខេត្ត ដើម្បីរៀបចំស្ថាប័ន និងអភិវឌ្ឍការគ្រប់គ្រងនៅសាលារៀន
- ប្រើប្រាស់ធាតុចូលពីអ្នកឯកទេសថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីកសាងជំនាញឯកទេសជាក់លាក់សំដៅរួមចំណែកដល់ការអនុវត្តគំនិតផ្តួចផ្តើមថ្មី និងអភិវឌ្ឍកម្មវិធីប្រចាំឆ្នាំ
- ជំរុញការអនុវត្តការវាយតម្លៃប្រសិទ្ធផលរបស់បុគ្គលិកនិងគោលនយោបាយអភិវឌ្ឍបុគ្គលិក
- អនុវត្តកម្មវិធីដែលនឹងរួមចំណែកដល់ផលសម្រេចផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាព។

### ៥.៩.៤ កម្មវិធីនិងសកម្មភាព

- ការសិក្សាអំពីវប្បធម៌នៃការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ។ ការរៀបចំស្ថាប័នដែលស្របនឹងបរិបទវិមជ្ឈការនិងវិសហមជ្ឈការ និងតម្រូវការការងារចាំបាច់ដើម្បីអនុវត្ត ។
- ការអភិវឌ្ឍបុគ្គលិកនៃវិទ្យាស្ថានជាតិអប់រំ កម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល។
- កម្មវិធីអភិវឌ្ឍការគ្រប់គ្រងនៅតាមសាលារៀន នៅក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលាគរុកោសល្យនិងវិក្រឹតការរាជធានី ខេត្ត។
- កម្មវិធីវាយតម្លៃនិងអភិវឌ្ឍបុគ្គលិក រួមទាំងការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ និងការរួមបញ្ចូលរាល់សកម្មភាពនានារបស់មូលនិធិភាពជាដៃគូសម្រាប់ការអភិវឌ្ឍសមត្ថភាព ទៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង។
- ការពិនិត្យឡើងវិញគោលនយោបាយអភិវឌ្ឍសមត្ថភាព និងពង្រីកផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាព។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ ៖ ការព្យាករណ៍ចំនួនសិស្ស និងតម្រូវការអប់រំ

តារាងទី ១ ៖ ចំណោលប្រជាជនក្នុងវ័យសិក្សា

| ចំណោលប្រជាជន | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| | | | | | |
| អាយុ 3 – 5 | 872,820 | 892,657 | 915,159 | 937,999 | 957,554 |
| អាយុ 3 – 5 (ស្រី) | 428,443 | 438,346 | 449,714 | 461,312 | 471,157 |
| អាយុ 6-11 | 1,709,710 | 1,719,119 | 1,736,598 | 1,759,925 | 1,785,697 |
| អាយុ 6-11 (ស្រី) | 837,521 | 843,254 | 852,852 | 865,162 | 878,399 |
| អាយុ 12-14 | 925,431 | 893,709 | 864,127 | 839,885 | 826,214 |
| អាយុ 12-14 (ស្រី) | 452,197 | 437,086 | 422,670 | 410,646 | 403,920 |
| អាយុ 15-17 | 1,015,726 | 991,113 | 960,989 | 928,609 | 897,659 |
| អាយុ 15-17 (ស្រី) | 494,572 | 483,661 | 469,668 | 454,292 | 439,513 |
| អាយុ 18-22 | 2,491,571 | 2,519,607 | 2,534,077 | 2,692,285 | 2,678,733 |
| អាយុ 18-22 (ស្រី) | 1,137,145 | 1,145,962 | 1,150,285 | 1,307,673 | 1,302,729 |

តារាងទី ២ ៖ ចំណោលចំនួនសិស្សតាមភូមិសិក្សា

| ចំណោលសិស្ស | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| | | | | | |
| **ការអប់រំកុមារតូច** | **327,257** | **373,764** | **423,281** | **474,880** | **526,437** |
| សាធារណៈ | 143,434 | 156,935 | 171,387 | 186,341 | 200,926 |
| ឯកជន | 28,914 | 31,847 | 34,985 | 38,252 | 41,488 |
| សហគមន៍ | 95,179 | 116,848 | 139,833 | 163,886 | 188,268 |
| តាមផ្ទះ និងខ្នងផ្ទះ | 59,729 | 68,135 | 77,076 | 86,401 | 95,755 |
| **ការអប់រំបឋមសិក្សា** | **2,038,602** | **2,015,409** | **2,011,538** | **2,028,462** | **2,063,189** |
| *បឋមសិក្សា (ស្រី)* | *985,896* | *979,742* | *982,338* | *994,748* | *1,016,145* |
| តំបន់ប្រជុំជន | 312,086 | 320,944 | 335,678 | 356,273 | 383,253 |
| តំបន់ជនបទ | 1,726,516 | 1,694,464 | 1,675,861 | 1,672,189 | 1,679,936 |
| **មធ្យមសិក្សាបឋមភូមិ** | **558,572** | **597,616** | **637,605** | **682,713** | **722,144** |
| *មធ្យមសិក្សាបឋមភូមិ (ស្រី)* | *272,765* | *290,588* | *309,086* | *329,984* | *346,891* |
| តំបន់ប្រជុំជន | 113,233 | 115,701 | 117,408 | 121,112 | 123,852 |
| តំបន់ជនបទ | 445,339 | 481,915 | 520,197 | 561,601 | 598,292 |
| **មធ្យមសិក្សាទុតិយភូមិ** | **299,435** | **305,627** | **325,822** | **357,087** | **406,875** |
| *មធ្យមសិក្សាទុតិយភូមិ (ស្រី)* | *134,481* | *137,453* | *148,172* | *161,881* | *184,340* |
| តំបន់ប្រជុំជន | 94,951 | 91,215 | 91,400 | 91,439 | 93,801 |

| | | | | | |
|---|---|---|---|---|---|
| តំបន់ជនបទ | 204,484 | 214,411 | 234,422 | 265,648 | 313,074 |
| **ឧត្តមសិក្សា** | **262,091** | **289,947** | **318,143** | **346,548** | **375,160** |
| *ឧត្តមសិក្សា (ស្រី)* | *106,787* | *119,499* | *132,985* | *147,162* | *161,879* |
| និស្សិតអាហារូបករណ៍ | 5,733 | 7,226 | 8,610 | 10,899 | 15,036 |
| **ការអប់រំក្រៅប្រព័ន្ធ** | | | | | |
| អក្ខរកម្មវិជ្ជាជីវៈ | 42,306 | 46,537 | 51,191 | 56,310 | 61,941 |
| *ស្រី* | *26,459* | *29,105* | *32,015* | *35,217* | *38,739* |
| ក្រោយអក្ខរកម្ម | 100,394 | 101,848 | 103,346 | 104,888 | 106,477 |
| មជ្ឈមណ្ឌលសិក្សាសហគមន៍ | 13,841 | 15,917 | 18,305 | 21,051 | 24,208 |
| *ស្រី* | *7,236* | *8,231* | *9,361* | *10,645* | *12,104* |
| កម្មវិធីចូលរៀនឡើងវិញ | 28,564 | 29,881 | 28,486 | 24,085 | 15,906 |
| *ស្រី* | *13,684* | *14,367* | *13,728* | *11,604* | *7,620* |
| កម្មវិធីសមមូល | 5,648 | 5,561 | 5,078 | 4,167 | 2,700 |
| *ស្រី* | *2,280* | *2,365* | *2,267* | *1,943* | *1,308* |

តារាងទី ៣ ៖ ចំណោលតម្រូវការសាលារៀន និងថ្នាក់

| ចំនួនសាលារៀន | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| | | | | | |
| **ការអប់រំកុមារតូច** | **5,785** | **6,278** | **6,788** | **7,305** | **7,804** |
| សាធារណៈ | 2,668 | 2,739 | 2,815 | 2,890 | 2,955 |
| សហគមន៍ | 3,117 | 3,538 | 3,973 | 4,415 | 4,850 |
| **ការអប់រំបឋមសិក្សា** | **6,902** | **6,951** | **7,073** | **7,302** | **7,606** |
| តំបន់ប្រជុំជន | 680 | 729 | 797 | 887 | 1,003 |
| តំបន់ជនបទ | 6,222 | 6,222 | 6,276 | 6,415 | 6,603 |
| **មធ្យមសិក្សាបឋមភូមិ** | **1,630** | **1,735** | **1,844** | **1,966** | **2,069** |
| តំបន់ប្រជុំជន | 207 | 207 | 207 | 212 | 215 |
| តំបន់ជនបទ | 1,423 | 1,528 | 1,637 | 1,754 | 1,854 |
| **មធ្យមសិក្សាទុតិយភូមិ** | **432** | **451** | **498** | **566** | **668** |
| **ការអប់រំក្រៅប្រព័ន្ធ** | | | | | |
| អក្ខរកម្មវិជ្ជាជីវៈ (សាធារណៈ) | 1,371 | 1,510 | 1,663 | 1,831 | 2,017 |
| ក្រោយអក្ខរកម្ម | | | | | |
| បណ្ណាល័យ | 56 | 61 | 65 | 71 | 76 |
| បន្ទប់អាន | 229 | 229 | 229 | 229 | 229 |

| | | | | | |
|---|---|---|---|---|---|
| មជ្ឈមណ្ឌលសិក្សាសហគមន៍ | 361 | 381 | 401 | 421 | 441 |
| ថ្នាក់ចូលរៀនឡើងវិញបឋមសិក្សា (សាធារណៈ) | 1,678 | 1,706 | 1,581 | 1,301 | 837 |
| ថ្នាក់សមមូល (សាធារណៈ) | 390 | 425 | 462 | 486 | 522 |

តារាងទី ៤ ៖ ចំណោលតម្រូវការគ្រូបង្រៀនតាមភូមិសិក្សា

| ចំនួនគ្រូបង្រៀន | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| | | | | | |
| **ការអប់រំកុមារតូច** | | | | | |
| *តម្រូវការគ្រូថ្មី (សាធារណៈ)* | *450* | *499* | *539* | *564* | *562* |
| សាធារណៈ | 4,653 | 5,126 | 5,636 | 6,169 | 6,698 |
| សហគមន៍ | 4,065 | 4,908 | 5,777 | 6,661 | 7,531 |
| **ការអប់រំបឋមសិក្សា** | **47,232** | **47,760** | **48,637** | **50,497** | **52,948** |
| *តម្រូវការគ្រូថ្មី* | *1,503* | *1,961* | *2,336* | *3,375* | *4,040* |
| តំបន់ប្រជុំជន | 9,619 | 9,619 | 9,619 | 10,179 | 10,950 |
| តំបន់ជនបទ | 37,613 | 38,141 | 39,018 | 40,318 | 41,998 |
| **មធ្យមសិក្សាបឋមភូមិ** | **27,067** | **27,067** | **27,067** | **27,451** | **27,824** |
| *តម្រូវការគ្រូថ្មី* | *909* | *909* | *909* | *1,306* | *1,309* |
| តំបន់ប្រជុំជន | 7,715 | 7,715 | 7,715 | 7,715 | 7,715 |
| តំបន់ជនបទ | 19,352 | 19,352 | 19,352 | 19,736 | 20,109 |
| **មធ្យមសិក្សាទុតិយភូមិ** | **10,160** | **10,629** | **11,684** | **13,264** | **15,668** |
| *តម្រូវការគ្រូថ្មី* | *203* | *681* | *1,289* | *1,845* | *2,717* |

## ឧបសម្ព័ន្ធទី ២ ៖ សូចនាករតាមអនុវិស័យ

| | ការអប់រំកុមារតូច | 2013-14 | 2014-15 | 2015-16 | 2016-17 | 2017-18 |
|---|---|---|---|---|---|---|
| 1 | ភាគរយកុមារអាយុ ៥ ឆ្នាំបានចូលរៀន | 62% | 66% | 71% | 75% | 80% |
| 2 | ភាគរយកុមារអាយុ ៤ ឆ្នាំបានចូលរៀន | 28% | 33% | 37% | 41% | 45% |
| 3 | ភាគរយកុមារអាយុ ៣ ឆ្នាំបានចូលរៀន | 23% | 27% | 32% | 36% | 40% |
| 4 | ភាគរយសេវាអប់រំកុមារតូចដែលគោរពតាមស្តង់ដារគុណភាព | 20% | 40% | 60% | 80% | 90% |
| 5 | ភាគរយសេវាអប់រំកុមារតូចដែលបានអនុវត្តតេស្តទៀងទាត់ដើម្បីវាស់សមត្ថភាពកុមារអាយុ ៥ ឆ្នាំ ជាទៀងទាត់ | 20% | 40% | 60% | 70% | 80% |
| 6 | ភាគរយកុមារក្នុងសេវាគាំពារនិងអភិវឌ្ឍកុមារតូច ដែលមានស្ថានភាពអាហារូបត្ថម្ភ | 20% | 40% | 60% | 80% | 90% |
| 7 | ភាគរយកុមារនៅតាមសាលាមត្តេយ្យសិក្សាសាធារណៈ ទទួលបានថ្នាំទម្លាក់ព្រូន | 90% | 90% | 90% | 90% | 90% |
| | **ការអប់រំបឋមសិក្សា** | **2013-14** | **2014-15** | **2015-16** | **2016-17** | **2017-18** |
| 1 | ភាគរយសាលាកុមារមេត្រី កម្រិតមធ្យមនិងកម្រិតអភិវឌ្ឍ | 80% | 85% | 90% | 95% | 100% |
| 2 | អត្រាពិតចូលរៀនថ្មី | 98% | 100% | 100% | 100% | 100% |
| | អត្រាពិតចូលរៀនថ្មី (ស្រី) | 98% | 100% | 100% | 100% | 100% |
| 3 | អត្រាពិតនៃការសិក្សា | 97% | 98% | 99% | 99% | 100% |
| | អត្រាពិតនៃការសិក្សា (ស្រី) | 97% | 98% | 99% | 99% | 100% |
| 4 | អត្រាបោះបង់ការសិក្សា | 5% | 4% | 3% | 2% | 1% |
| | អត្រាបោះបង់ការសិក្សា (ស្រី) | 5% | 4% | 3% | 2% | 1% |
| 5 | អត្រាត្រួតថ្នាក់ | 4% | 3% | 3% | 3% | 2% |
| | អត្រាត្រួតថ្នាក់ (ស្រី) | 4% | 3% | 3% | 3% | 2% |
| 6 | អត្រាបញ្ចប់ការសិក្សា | 98.4% | 100% | 100% | 100% | 100% |
| | អត្រាបញ្ចប់ការសិក្សា (ស្រី) | 98.1% | 100% | 100% | 100% | 100% |
| 7 | ភាគរយសិស្សថ្មីថ្នាក់ទី ១ ដែលបានឆ្លងកាត់មត្តេយ្យសិក្សា | 80% | 85% | 90% | 95% | 100% |
| 8 | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ | 89% | 90% | 91% | 93% | 94% |
| | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅម.បឋមភូមិ (ស្រី) | 89% | 90% | 92% | 93% | 94% |
| 9 | ភាគរយសាលាបឋមសិក្សាមាន | | | | | |
| | បង្គន់អនាម័យនិងទឹកស្អាត | 87% | 87% | 87% | 87% | 87% |
| | កន្លែងសម្អាតដៃ | 60% | 60% | 60% | 60% | 60% |
| | ប្រអប់សង្គ្រោះបឋម | 70% | 70% | 70% | 70% | 70% |
| | **ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស** | **2013-14** | **2014-15** | **2015-16** | **2016-17** | **2017-18** |
| 1 | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 13% | 11% | 8% | 6% | 3% |
| | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី) | 13% | 11% | 8% | 6% | 3% |
| 2 | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 60% | 67% | 74% | 81% | 87% |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី) | 60% | 66% | 73% | 80% | 86% |

| | | | | | | |
|---|---|---|---|---|---|---|
| 3 | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | 29% | 31% | 34% | 38% | 45% |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ (ស្រី) | 27% | 28% | 32% | 36% | 42% |
| 4 | អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ | 81% | 83% | 84% | 86% | 88% |
| | អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ (ស្រី) | 82% | 83% | 85% | 86% | 88% |
| 5 | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 44% | 52% | 57% | 67% | 76% |
| | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី) | 45% | 52% | 57% | 67% | 76% |
| 6 | ភាគរយសិស្សមធ្យមសិក្សាបឋមភូមិទទួលអាហារូបករណ៍ | 9% | 9% | 9% | 9% | 9% |
| 7 | ចំនួនគ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីសាលាកុមារមេត្រី | 55% | 60% | 65% | 70% | 75% |
| 8 | សាលាមធ្យមសិក្សាមានបង្គន់អនាម័យនិងទឹកស្អាត | | | | | |
| | មធ្យមសិក្សាបឋមភូមិ | 90% | 90% | 90% | 90% | 90% |
| | មធ្យមសិក្សាទុតិយភូមិ | 100% | 100% | 100% | 100% | 100% |
| 9 | ចំនួនវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស | 3 | 4 | 5 | 6 | 7 |
| 10 | ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស | 984 | 1,238 | 1,492 | 1,746 | 2,000 |
| | ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស (ស្រី) | 316 | 387 | 458 | 529 | 600 |
| | **ឧត្តមសិក្សា** | **2013-14** | **2014-15** | **2015-16** | **2016-17** | **2017-18** |
| 1 | ភាគរយនិស្សិតអាហារូបករណ៍រដ្ឋចូលរៀនឆ្នាំទី ១ | 5% | 8% | 11% | 13% | 15% |
| 2 | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ ឆ្នាំ) | 13% | 15% | 17% | 20% | 23% |
| 3 | សាស្ត្រាចារ្យដែលមានគុណវុឌ្ឍិនៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ កើន ១០០០ នាក់ និងបណ្ឌិត ២៥០ នាក់ | | | | | |
| | បរិញ្ញាបត្រជាន់ខ្ពស់ក្នុងស្រុក<br>បណ្ឌិតក្នុងស្រុក<br>បរិញ្ញាបត្រជាន់ខ្ពស់នៅបរទេស<br>បណ្ឌិតនៅបរទេស | 50<br>20<br>50<br>20 | 70<br>30<br>70<br>20 | 80<br>30<br>80<br>20 | 100<br>30<br>100<br>20 | 200<br>40<br>200<br>20 |
| 4 | ភាគរយនិស្សិតបញ្ចប់ការសិក្សាក្នុងកម្មវិធីអាទិភាពអាស៊ាន | 87% | 88% | 89% | 91% | 92% |
| 5 | ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ | 70% | 72% | 74% | 77% | 80% |
| 6 | ភាគរយនៃគ្រឹះស្ថានឧត្តមសិក្សារៀបចំផែនការថវិកាប្រចាំឆ្នាំ | 10% | 20% | 40% | 60% | 80% |
| 7 | ភាគរយនៃគ្រឹះស្ថានឧត្តមសិក្សាសម្រេចបានតាមស្តង់ដារធានាគុណភាពផ្ទៃក្នុង | 10% | 20% | 30% | 40% | 50% |
| 8 | ថវិកាសម្រាប់អនុវិស័យឧត្តមសិក្សា | 4% | 8% | 12% | 16% | 20% |
| | **ការអប់រំក្រៅប្រព័ន្ធ** | **2013-14** | **2014-15** | **2015-16** | **2016-17** | **2017-18** |
| 1 | អត្រាអក្ខរកម្មមនុស្សពេញវ័យអាយុចាប់ពី១៥-៤៥ ឆ្នាំ | 87.05% | 88.45% | 89.15% | 89.85% | 90.55% |
| 2 | ភាគរយប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | 69% | 72% | 74% | 77% | 80% |
| 3 | ចំនួនអ្នកសិក្សាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ | 13,841 | 15,917 | 18,305 | 21,051 | 24,208 |
| 4 | ភាគរយកុមារដែលបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញនិងបានបញ្ជូនទៅក្នុងប្រព័ន្ធ | 95% | 95% | 95% | 95% | 95% |
| 5 | ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល | 5,709 | 6,243 | 6,692 | 7,076 | 7,317 |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | រាជធានីខេត្តរៀបចំបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | 5 | 10 | 15 | 20 | 24 |
| 7 | ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍ | 371 | 391 | 421 | 441 | 471 |
| 8 | មជ្ឈមណ្ឌលសិក្សាសហគមន៍មានស្តង់ដារ | 5% | 10% | 15% | 20% | 30% |
| | **ការអភិវឌ្ឍយុវជន** | **2013-14** | **2014-15** | **2015-16** | **2016-17** | **2017-18** |
| 1 | ចំនួនយុវជនដែលទទួលបានការបណ្តុះបណ្តាលជំនាញខ្លីៗ | 2700 | 2900 | 3000 | 3100 | 3300 |
| 2 | ចំនួនយុវជនដែលបានទទួលការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងសហគ្រិនភាព | 300 | 300 | 300 | 300 | 300 |
| 3 | ចំនួនយុវជនដែលបានបង្កើតការងារដោយខ្លួនឯង ក្នុងមួយមជ្ឈមណ្ឌលក្នុងមួយឆ្នាំ | 10 | 10 | 10 | 10 | 10 |
| 4 | ចំនួនយុវជនដែលទទួលការបណ្តុះបណ្តាលពីការងារស្ម័គ្រចិត្ត | 2500 | 2700 | 3000 | 3300 | 3600 |
| 5 | ចំនួនមជ្ឈមណ្ឌលយុវជន | 9 | 15 | 18 | 20 | 24 |
| 6 | ភាគរយសិស្សថ្នាក់ទី ៤-៩ ចូលរួមក្នុងក្រុមប្រឹក្សាកុមារ | 99% | 99% | 100% | 100% | 100% |
| 7 | ភាគរយសិស្សថ្នាក់ទី១០-១២ ចូលរួមក្នុងក្រុមប្រឹក្សាយុវជន | 89% | 94% | 96% | 98% | 100% |
| | **ការអប់រំកាយនិងកីឡា** | **2013-14** | **2014-15** | **2015-16** | **2016-17** | **2017-18** |
| 1 | ចំនួនគ្រូអប់រំកាយនិងកីឡាបណ្តុះបណ្តាលក្នុងមួយឆ្នាំ | 150 | 150 | 150 | 150 | 150 |
| 2 | ទីលានកីឡាចំនួន ៤ (ពហុកីឡាដ្ឋានជាតិ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា កីឡដ្ឋានខេត្តសៀមរាប) ត្រូវបានកែលម្អ | | | | | |
| 3 | គ្រឹះស្ថានមធ្យមសិក្សាចំនួន ១០ មានទីលានបាល់ទាត់ ១៥ មានទីលានបាល់បោះ និង ២០ មានទីលានបាល់ទះ | | | | | |
| 4 | ចំនួនមេដាយមាសក្នុងការប្រកួតកីឡាស៊ីហ្គេម | 4 | 8 | 12 | 16 | 20 |

## ឧបសម្ព័ន្ធទី ៣ ៖ ការព្យាករណ៍តម្រូវការហិរញ្ញវត្ថុ

តារាងទី ១ ៖ ការព្យាករណ៍ចំណាយសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨

| ការព្យាករណ៍ចំណាយ (ចរន្តនិងមូលធន) (គិតជាលានរៀល) | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| ការអប់រំកុមារតូច | 128,571 | 145,149 | 164,549 | 187,547 | 213,911 |
| ការអប់រំបឋមសិក្សា | 840,341 | 943,513 | 1,091,687 | 1,285,246 | 1,523,921 |
| ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | 525,029 | 650,973 | 764,245 | 924,643 | 1,121,084 |
| *មធ្យមសិក្សាបឋមភូមិ* | *377,340* | *467,031* | *519,781* | *596,247* | *662,918* |
| *មធ្យមសិក្សាទុតិយភូមិ* | *147,689* | *183,942* | *244,464* | *328,396* | *458,166* |
| ឧត្តមសិក្សា | 210,050 | 246,560 | 272,469 | 313,997 | 392,636 |
| ការអប់រំក្រៅប្រព័ន្ធ | 20,937 | 22,207 | 23,458 | 24,610 | 25,739 |
| ការអភិវឌ្ឍយុវជន | 10,343 | 11,941 | 12,253 | 12,573 | 13,018 |
| ការអប់រំកាយនិងកីឡា | 47,558 | 27,584 | 26,462 | 28,974 | 44,322 |
| **សរុប** | **1,782,828** | **2,047,928** | **2,355,123** | **2,777,590** | **3,334,631** |
| **ការព្យាករណ៍ចំណាយ (ចរន្តនិងមូលធន) (គិតជាលាន ដុល្លារ)** | **2014** | **2015** | **2016** | **2017** | **2018** |
| ការអប់រំកុមារតូច | 32 | 36 | 41 | 47 | 53 |
| ការអប់រំបឋមសិក្សា | 210 | 236 | 273 | 321 | 381 |
| ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | 131 | 163 | 191 | 231 | 280 |
| *មធ្យមសិក្សាបឋមភូមិ* | *94* | *117* | *130* | *149* | *166* |
| *មធ្យមសិក្សាទុតិយភូមិ* | *37* | *46* | *61* | *82* | *115* |
| ការអប់រំឧត្តមសិក្សា | 53 | 62 | 68 | 78 | 98 |
| ការអប់រំក្រៅប្រព័ន្ធ | 5 | 6 | 6 | 6 | 6 |
| ការអភិវឌ្ឍយុវជន | 3 | 3 | 3 | 3 | 3 |
| ការអប់រំកាយនិងកីឡា | 12 | 7 | 7 | 7 | 11 |
| **សរុប** | **446** | **512** | **589** | **694** | **834** |

តារាងទី ២ ៖ ការបែងចែកធនធានតាមអនុវិស័យ

| គិតជាភាគរយ | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| ការអប់រំកុមារតូច | 7.2% | 7.1% | 7.0% | 6.8% | 6.4% |
| ការអប់រំបឋមសិក្សា | 47.1% | 46.1% | 46.4% | 46.3% | 45.7% |
| ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | 29.4% | 31.8% | 32.5% | 33.3% | 33.6% |
| *មធ្យមសិក្សាបឋមភូមិ* | *21.2%* | *22.8%* | *22.1%* | *21.5%* | *19.9%* |
| *មធ្យមសិក្សាទុតិយភូមិ* | *8.3%* | *9.0%* | *10.4%* | *11.8%* | *13.7%* |
| ឧត្តមសិក្សា | 11.8% | 12.0% | 11.6% | 11.3% | 11.8% |
| ការអប់រំក្រៅប្រព័ន្ធ | 1.2% | 1.1% | 1.0% | 0.9% | 0.8% |

| | | | | | |
|---|---|---|---|---|---|
| ការអភិវឌ្ឍយុវជន | 0.6% | 0.6% | 0.5% | 0.5% | 0.4% |
| ការអប់រំកាយនិងកីឡា | 2.7% | 1.3% | 1.1% | 1.0% | 1.3% |
| **សរុប** | **100%** | **100%** | **100%** | **100%** | **100%** |

## តារាងទី ៣ ៖ ការប៉ាន់ស្មានធនធានដែលមាន

| ការប៉ាន់ស្មានធនធាន | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| កំណើន ផ.ស.គ (IMF projection) | 7.2% | 7.4% | 7.4% | 7.5% | 7.5% |
| ផ.ស.ស សរុប (គិតជា លានដុល្លារ) | 17,288 | 19,090 | 21,078 | 23,294 | 25,628 |
| ផ.ស.ស សរុប (គិតជា លានរៀល) | 69,152,000 | 76,360,000 | 84,312,000 | 93,176,000 | 102,512,000 |
| **ផសស នៅឆ្នាំ ២០០០** (គិតជា លានរៀល) | **68,618,000** | **75,636,000** | **83,422,000** | **92,143,000** | **101,548,000** |
| *គិតជា លានដុល្លារ* | *16,943* | *18,676* | *20,598* | *22,474* | *24,768* |
| **ចំណាយសរុបរបស់រាជរដ្ឋាភិបាល** | **8,258,703** | **8,833,509** | **9,708,630** | **10,684,753** | **11,729,804** |
| ភាគរយក្រសួង អ.យ.ក ធៀប ផ.ស.ស | 2.0% | 2.2% | 2.4% | 2.7% | 3.0% |
